# អំណាន

## ផាអំណាច



កុំភ្លេចសៀវភៅ

បើស្រឡាញ់ខ្លួនឯង

បើស្រឡាញ់គ្រួសារ

បើស្រឡាញ់សង្គមជាតិ

ឡាំ លីម

# អំណាន

## ជាអំណាច

កុំភ្លេចសៀវភៅ

បើស្រឡាញ់ខ្លួនឯង

ស្រឡាញ់គ្រួសារ

ស្រឡាញ់សង្គមជាតិ

ដាក់ជូនជាសៀវភៅឌីជីថល (eBook) ឱ្យទាញយកអាន
លើកទី១ ដោយសេរីតាមបណ្ដាញសង្គម នៅថ្ងៃសុក្រ
១៥កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ត្រូវនឹងថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩
ជាថ្ងៃសីល និងពេញបូណ៌មី

ទំព័រសរុបមានចំនួន ២៨៥ទំព័រ
ដែលមានទំហំអក្សរ ១២

ប្រភពរូបភាព៖ pinterest

រាល់ការបោះពុម្ពផ្សាយធ្វើអាជីវកម្មជាទង្វើខុសច្បាប់

រក្សាសិទ្ធិគ្រប់បែបយ៉ាង © គ.ស ២០១៩

ដោយម្ចាស់ស្នាដៃ **ឡាំ លីម**

# មាតិកាអត្ថបទ

## ហេតុអ្វីត្រូវអានសៀវភៅនេះ?

## អារម្ភកថា

## ការសុំអធ្យាស្រ័យ


| | |
|---|---|
| បើឱ្យជ្រើសរើស | 2 |
| ហេតុអ្វីត្រូវអាន ហើយអានយ៉ាងម៉េច? | 5 |
| អានចំណេញ ឬអានខាត? | 8 |
| វិនិយោគលើសៀវភៅ? | 13 |
| សៀវភៅជាមិត្តល្អ? | 17 |
| សៀវភៅបេះដូង ឬសៀវភៅខួរក្បាល? | 22 |

ហេតុផលឃោរឃៅ មនោសញ្ចេតនា... 27
ត្រូវចេះជ្រើសរើសសៀវភៅអាន 31
ក្បួនខ្លះៗនៃការអានឱ្យមានប្រសិទ្ធិភាព 35
អានដោយការពិចារណា ជាងការខឹងសម្បារ 53
ត្រូវអានយកចេះ កុំអានយកចប់ 57
ចេះអាន គឺត្រូវចេះបន្សុទ្ធ 59
មិនមែនគ្រាន់តែអាន 61
អំណាន និងសមាធិ 68
ការអានទ្រឹស្តី និងការធ្វើជាក់ស្តែង 71
គ្រូបង្រៀនអានសៀវភៅ 77
ខឹងគោវាយរទេះ 82
ជំនាញគិតសំខាន់ជាងជំនាញជឿ 85

ទាសករគំនិត 88

ចេះត្រឹមតែចាំ និងចេះគិតពិចារណា 90

បើនាងចេះអាន 96

សៀវភៅ និងជាតិ 99

នឹកអ្នកណា ? 105

សៀវភៅទស្សនៈ 111

អានដោយពុំគិត 116

លួចញញឹម 118

អក្សរជួយសង្គម 121

តើនាងជានរណា ? 131

ចរិតអ្នករៀន 134

អំណាចទឹកខ្មៅ 137

កម្ទេចសៀវភៅ គឺកម្ទេចជាតិ 142
ការរៀន និងការគិត 147
អ្នកនិពន្ធជួយជាតិបែបណា ? 151
តម្លៃទឹកខ្មៅស្ថិតត្រង់សច្ចៈ 156
តិចមែន តែមានគុណភាព 159
ប្រឹងអានយកចំណេះ រើសមេដឹកនាំល្អ 164
ប្រវត្តិសាស្ត្រត្រូវសរសេរដោយអព្យាក្រិត្យ 166
កុំចង់សប្បាយក្នុងពេលខ្លួនក្រ 169
បដិវត្តន៍ផ្នត់គំនិតឆ្នាំថ្មី 172
ត្រូវប្រឹងរៀនដើម្បីជួយអ្នកដទៃ 174
ទុក្ខធំនៃសង្គម គឺមានមនុស្សអវិជ្ជាច្រើន 178
ដួងព្រលឹងសិល្បៈ 181

អំណាចនៃការហ្វឹកហាត់ 184
ចេះគិត ពុំប្រាកដថាគិតត្រូវ 186
ស្អាតហើយឆ្លាត 191
ខ្ទីខួរក្បាលអ្នកចេះ 196
តើខ្ញុំជាអ្នកចេះ ឬអ្នកចែក ? 201
អ្នកចេះជំនាញដែលពូកែអាន 207
សរុបថាខ្ញុំនៅក្មេង 210
សៀវភៅភាពជាអ្នកដឹកនាំដែលគួរអាន 212
ពិការអ្វីអាចពិការបាន តែកុំពិការចិត្តគំនិត 214
វិជ្ជា២សម្រាប់យុវជន និងទីប្រឹក្សា១ 218
អំណាន និងសំណេរ 223
រឿងសៀវភៅឈឺចាប់ 227

ថ្ងៃដូរកូនកំលោះ 240

ដើម្បីក្លាយទៅជាអ្នកនិពន្ធ? 255

អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកជា 261

អ្នកនិពន្ធវ័យក្មេង? 271

តើយកចំណេះពីអំណានទៅធ្វើអ្វី? 282

**អំពីស្នាដៃខ្ញុំ**

**អំពីខ្ញុំ**

សៀវភៅនេះមិនមែនជាសៀវភៅ Free ទេ តែជា សៀវភៅដែលអ្នកអានត្រូវកំណត់តម្លៃដោយខ្លួនឯង (no price tag but not FREE) ដ្បិតបើអានបាន យល់ច្រើន គឺវានឹងក្លាយទៅជាសៀវភៅដែល មានតម្លៃ ។ ប៉ុន្តែ បើអានមិនយល់ទេ គឺគ្មានតម្លៃ ឡើយ ប្រៀបដូចជាបានទិញសៀវភៅអានច្រើនបែប ណាក៏ដោយ ចំណាយលុយអស់ច្រើនប៉ុនណាក៏ដោយ ចំណាយពេលវេលាអានច្រើនប៉ុនណាក៏ដោយ ក៏ នៅតែគ្មានតម្លៃដែរ ឱ្យតែអានមិនយល់ ។

## ហេតុអ្វីត្រូវអានសៀវភៅនេះ?

បណ្ណារក្សមិនដែលអានសៀវភៅ គឺនឹងមិនដឹងជំរុញអ្នកដទៃឱ្យអានយ៉ាងដូចម្ដេច? គ្រូបង្រៀនមិនដែលអានសៀវភៅ គឺនឹងមិនដឹងជាត្រូវជំរុញសិស្សឱ្យអានសៀវភៅយ៉ាងដូចម្ដេច? ម្ដាយឪពុកមិនដែលអានសៀវភៅ គឺនឹងមិនដឹងជាត្រូវជំរុញឱ្យកូនអានសៀវភៅយ៉ាងដូចម្ដេច? មិត្តភក្តិមិនដែលអានសៀវភៅ គឺនឹងមិនដឹងជាត្រូវជំរុញឱ្យមិត្តដទៃអានសៀវភៅយ៉ាងដូចម្ដេច? អ្នករៀបចំកម្មវិធីអំណានតាមសហគមន៍មិនដែលអានសៀវភៅ គឺនឹងមិនដឹងត្រូវជំរុញយុវជនចូលរួមឱ្យអានសៀវភៅយ៉ាងដូចម្ដេច?

សៀវភៅនេះនឹងជូនជាគំនិតខ្លះៗ អំពីទិដ្ឋភាពនៃការអាន និងការសរសេរ ។

ពេលណាមានអ្នកសួរពីរបៀបអានសៀវភៅ គឺយើងប្រហែលជានឹងអាចឆ្លើយបានខ្លះៗពីវិធីសាស្ត្រនៃការអានដ្បិតបើយើងបានអានសៀវភៅនេះ ។ ខ្ញុំសូមលើកទឹកចិត្តឱ្យបងប្អូនអ្នកអានព្យាយាមអានសៀវភៅនេះដដែលៗ ហើយត្រូវធ្វើយ៉ាងណាដើម្បីអាចចងចាំនូវគំនិតល្អខ្លះពីសៀវភៅ ។ កាលណាបើបានចងចាំ និងយល់ពីគោលគំនិតល្អៗខ្លះពីសៀវភៅហើយ នោះនឹងធ្វើឱ្យយើងអាចនិយាយចែករំលែកអំពីការអានដល់អ្នកដទៃបាន ។ អ្វីៗក៏ដោយបើត្រឹមតែមួយរស់ខ្លួនឯង គឺមិនសូវពិបាកប៉ុន្មានទេ តែការចេះរស់នៅជួយយកអាសាអ្នកដទៃ គឺមិនសូវស្រួល

ប៉ុន្មានឡើយ ដ្បិតយើងត្រូវមានទំនួលខុសត្រូវច្រើន ។

ការអានសៀវភៅក៏អ៊ីចឹងដែរ បើយើងអានយល់សម្រាប់តែខ្លួនឯង គឺពុំចាំបាច់អានច្រើន ពុំចាំបាច់អានដដែលៗរហូតដល់ចាំច្បាស់លាស់ទេ តែគ្រាន់តែអានល្មមៗ ត្រឹមតែយល់សើៗ គឺបានហើយ ។ ជាទូទៅ ចំណេះដឹងខ្លះ វាតម្រូវឱ្យយើងចងចាំ និងចាំបានច្បាស់ល្អ ពីព្រោះបើចាំបានច្បាស់ល្អ ហើយយល់ថែមទៀត គឺស្មើនឹងចេះ ។ បើយើងចេះច្បាស់ វាក៏អាចធ្វើឱ្យយើងចេះបន្តច្នៃគំនិតទៅរករបៀបគិតផ្សេងមួយបែបទៀតដែរ ។ លើសពីនេះ អត្ថបទខ្លះ វាអាចជាអត្ថបទដែលយើងធ្លាប់អានរួចហើយ តែបើអាចគួរតែអានម្ដងទៀត ។ យើងជាអ្នកជំនាន់មុន បើស្រឡាញ់សង្គម គឺប្រហែលជាត្រូវយកទំនួលខុសត្រូវមក

ដាក់នឹងខ្លួនច្រើនបន្តិចហើយ។ ការងារខ្លះ គឺគ្មាននរណាមកពឹងពាក់ទេ តែដោយសេចក្ដីស្រឡាញ់ វាធ្វើឱ្យយើងស្ម័គ្រចិត្តធ្វើដោយគ្មានលក្ខខណ្ឌ។

## អារម្ភកថា

ការអាន គឺជាផ្នែកមួយនៃជីវិត ។ សង្គមមួយដែលខ្លាំង គឺជាសង្គមដែលមានប្រជាជនអានច្រើន និងនិយមចូលចិត្តការសិក្សារៀនសូត្រជាប្រចាំ ។ ពេលខ្លះ កុំថាដល់យើងប្រឹងអានដើម្បីសង្គម តែបើបានប្រឹងអានដើម្បីអនាគតខ្លួនឯង គឺអាចហៅបានថាស្រឡាញ់សង្គមពិតទៅហើយ ។ យើងចំណាយលុយទិញឡេលាបមុខ លាបស្បែក ដើម្បីឱ្យរូបរាងស្រស់ស្អាត សាច់សខ្ចី មុខម៉ត់រលោងស្អាត ។ មិនត្រឹមតែប៉ុណ្ណោះ យើងចំណាយលុយទិញកាហ្វេញ៉ាំស្ទើររាល់ថ្ងៃ ។ អ្វីៗទាំងនេះ គឺជាកិច្ចការបំពេញតម្រូវការសម្បក

កាយ ។ រីឯចំពោះការអានក៏អ៊ីចឹងដែរ វាគឺផ្នែកមួយនៃការចិញ្ចឹមព្រលឹងរបស់យើង ។ រាងកាយត្រូវការអាហារ ហើយខួរក្បាលត្រូវការអាហារគំនិត ។

អ្នកដែលអាន គឺជាមនុស្សដែលរស់ តែអ្នកដែលមិនអាន គឺតែងតែស្លាប់រាល់ថ្ងៃ ។ មានឧបសគ្គជាច្រើនដែលរារាំងយើងមិនឱ្យចូលចិត្តអានសៀវភៅ តែបើមិនព្រមជម្នះឱ្យឈ្នះទេ គឺយើងនឹងជួបឧបសគ្គដែលលំបាកជាងការអានទៅទៀត ។ អ្នកដែលមិនអាន គឺប្រៀបដូចជាមនុស្សដែលឥតវិញ្ញាណ ។ យើងតែងតែនិយាយថា "ការអានគឺជាថ្នាំងងុយគេងដ៏មានប្រសិទ្ធភាព ដ្បិតឱ្យតែពេលណាយើងកាន់សៀវភៅអាន គឺដឹងតែយើងមានអារម្មណ៍ងងុយគេងភ្លាម ។ ប៉ុន្តែ បើយើងមិនមានចិត្តអត់ធ្មត់ប្រឹងអានឱ្យបានច្រើនទេ

គឺយើងនឹងគេងលក់រហូតហើយ”។ អ្នកខ្លះបានសួរខ្ញុំថា “តើត្រូវធ្វើយ៉ាងណា ទើបធ្វើឱ្យយើងចង់អានសៀវភៅ?” បើមែនទែនទៅ គឺគ្មានយន្តការណាមួយដែលជំរុញឱ្យយើងចង់អានសៀវភៅទេ តែអ្វីដែលយើងត្រូវដឹង គឺថា “ត្រូវអាន រៀនអានបង្កើតទម្លាប់នៃការអាន”។

“**អំណានជាអំណាច**” គឺជាសៀវភៅឌីជិថល (eBook) ដែលខ្ញុំបានដកស្រង់អត្ថបទទាក់ទងនឹងការអាន របៀបអាន និងទស្សនៈខ្លះៗអំពីការអានចេញពីសៀវភៅ “ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ”, សៀវភៅ “ប្រតិទិនទស្សនៈ ២២២ថ្ងៃ” និងអត្ថបទដែលសរសេរបន្ថែមភាគច្រើន។ បងប្អូនខ្លះនឹងអាចឆ្ងល់ថា “បើដកស្រង់អ៊ីចឹង តើខ្លឹមសារមិនដដែលៗហើយទេ?” សៀវភៅឌីជិថលនេះ បើតាម

គោលបំណងរបស់ខ្ញុំ គឺរៀបចំឡើងមិនមែនសម្រាប់បងប្អូនអ្នកអានដែលធ្លាប់បានអានសៀវភៅ "ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ" និងសៀវភៅ "ប្រតិទិនទស្សនៈ ២២២ថ្ងៃ" ទេ ។ ប៉ុន្តែខ្ញុំរៀបចំឡើងក្នុងគោលបំណងជួយសម្រួលខ្លះៗដល់អ្នកដែលគ្មានថវិកាទិញសៀវភៅពីរក្បាលមុនរបស់ខ្ញុំមកអាន ។ ចំពោះអត្ថប្រយោជន៍ផ្សេងទៀត គឺខ្ញុំនិយាយជាទូទៅក្នុងវង្វង់នៃប្រធានបទអំពី "ការអាន" ។

សៀវភៅនេះ គឺវាអាចជួយបន្ថែមចំណេះដឹងដល់បងប្អូនអ្នកអាន ដែលចង់ដឹងពីវិធីសាស្ត្រនៃការអានឱ្យមានប្រសិទ្ធិភាពខ្ពស់ និងទទួលផលបានច្រើន ។ បណ្តុំនៃគំនិតទស្សនៈ និងការយល់ឃើញដែលបានរៀបរាប់ក្នុងសៀវភៅនេះគឺសុទ្ធតែកើតចេញពីបទពិសោធនៃការអានរបស់ខ្ញុំផ្ទាល់

តែម្តង ព្រមទាំងបទពិសោធនៃការដឹកនាំវេទិកាអំណាន តាំងពីឆ្នាំ២០១៧ មកម្ល៉េះ ។ លើសពីនេះ វាក៏នឹងមានការបង្ហាញខ្លះ ៗ ពីទិដ្ឋភាពនៃចរន្តសំណេរនៅក្នុងសង្គមយើងសព្វថ្ងៃផងដែរ ។ សៀវភៅនេះ គឺគ្រាន់តែជាការចែករំលែកបទពិសោធខ្លះ ៗ អំពីសំណេរ និងអំណានដល់អ្នកដែលចង់ចាប់ផ្តើមអានសៀវភៅ ឬអ្នកដែលចង់ស្វែងយល់ពីការអានមួយកម្រិតថែមទៀត ។

អ្នកដែលគួរអានសៀវភៅឌីជិថលនេះ គឺគួរតែជាបណ្ណារក្ខ អ្នកដែលចូលចិត្តអាន អ្នកដែលជាអ្នករៀបចំកម្មវិធីបណ្តុះការអានដល់យុវជន និងអ្នកដែលចង់ចែករំលែកចំណេះដឹងអំពីការអានសៀវភៅដល់មនុស្សជុំវិញខ្លួន ។ បើស្រឡាញ់នរណាម្នាក់ មិនថាជាក្តីស្រឡាញ់បែប

ប្រុសស្រី ជាក្តីស្រឡាញ់ក្នុងន័យគ្រួសារ ជាក្តីស្រឡាញ់ក្នុងនាមមិត្តភក្តិ ជាក្តីស្រឡាញ់ក្នុងនាមជាបងប្អូន មិនថាជាក្តីស្រឡាញ់ក្នុងន័យណាទេ ឬសូម្បីតែមនុស្សដែលបងប្អូនមិនចូលចិត្ត គឺសូមប្រគល់សៀវភៅនេះជូនដល់បុគ្គលខាងលើ ។ ជាចុងក្រោយ ខ្ញុំសុំអធ្យាស្រ័យទុកជាមុន ដ្បិតខ្ញុំដឹងច្បាស់ណាស់ថាទស្សនៈអំពីការអាននិងចរន្តនៃការសរសេរដែលមានក្នុងសៀវភៅនេះ គឺនឹងធ្វើឱ្យមានការប៉ះពាល់ដល់អារម្មណ៍បងប្អូនខ្លះ ។

## ការសុំអធ្យាស្រ័យ

ខ្ញុំពិតជាបានបោះបង់ចោលនូវអារម្មណ៍ភ័យខ្លាចដែលត្រូវអ្នកដទៃស្អប់ ឬមិនចូលចិត្ត ។ ខ្ញុំបានបោះបង់ចោលនូវអារម្មណ៍រំជើបរំជួល ពេលណាត្រូវបានអ្នកដទៃសរសើរ ។ អត្ថបទក្នុងសៀវភៅនេះ ខ្ញុំជឿថាមានការប៉ះពាល់អារម្មណ៍ដែលអាចនាំឱ្យអ្នកអានឈឺចាប់ ឬមិនសប្បាយចិត្តខ្លះ តែសូមដកការស្អប់ស្រឡាញ់ចេញ ហើយប្រឹងអានដោយប្រើការត្រិះរិះពិចារណាវិញ ។

ចេតនារបស់ខ្ញុំក្នុងការដាក់សៀវភៅនេះឱ្យទាញយក

អានដោយឥតគិតថ្លៃ គឺគ្មានអ្វីផ្សេងក្រៅតែអំពីចិត្តចង់ចែករំលែកចំណេះដឹងទាក់ទងនឹងការអាន និងទិដ្ឋភាពខ្លះៗអំពីការសរសេរទេ ។ បើបងប្អូនបានអានដោយពិចារណាគ្រប់ជ្រុងជ្រោយហើយ ហើយនៅតែឃើញថាគំនិតដែលខ្ញុំចែករំលែកនេះនៅតែខុសដដែល គឺចាត់ទុកថាខ្ញុំពិតជាខុសមែនទៅចុះ ។ ផ្ទុយទៅវិញ បើយល់ថាគំនិតដែលមានក្នុងអត្ថបទណាមួយត្រឹមត្រូវ ក៏សូមកុំភ្លេចយកទៅអនុវត្ត និងចែករំលែកដល់បងប្អូនអ្នកអានដទៃផ្សេងទៀតផង ។

*ចរិតមិនសូវចូលចិត្តទើសរឿងដែលត្រូវទើស ទើបយើងចេះតែខុសគៗជំនាន់ ។ មិនទើសលើកទី១ នាំឱ្យខុសម្ដង ។ មិនទើសលើកទី២ នាំឱ្យខុស២ដង ។ មិនទើសលើកទី៣គឺខុសនឹងក្លាយទៅជាត្រូវរហូត ។*

# កាន់សៀវភៅ គឺស្មើនឹងគិតជាតិ

បើយើងបោះបង់សៀវភៅចោល
គឺស្មើនឹងលែងខ្វល់ពីជាតិ

ផ្សព្វផ្សាយវប្បធម៌អំណាន គឺជាកាតព្វកិច្ច

របស់យុវជនជំនាន់នេះ

បង្ហាញគំរូនៃការអានសៀវភៅដល់ក្មេងៗ
គឺជាតួនាទីរបស់យុវជនជំនាន់នេះ

បើយើងដាក់ជី ស្រោចទឹក និងគាំទ្រ

យុវនិពន្ធមានឆន្ទៈពិតប្រាកដក្នុងជំនាន់នេះ

គឺស្មើនឹងដាំដើមអ្នកនិពន្ធអាជីពឱ្យចេញជាផ្លែផ្កា

សម្រាប់១០ ទៅ២០ឆ្នាំក្រោយ ។




មនុស្សខ្លះ ដែលពុំសូវបានអាន គឺពួកគេស្លាប់ស្ទើររៀងរាល់ថ្ងៃ ពីព្រោះគេជួបបញ្ហាជីវិតរាល់ថ្ងៃ ហើយគេត្អូញត្អែរនឹងជីវិតរាល់ថ្ងៃ ។ ចំណេះដឹងច្រើន តែងនាំឱ្យមានបញ្ហានៃជីវិតកាន់តែតិច ហើយចំណេះដឹងតិច គឺនឹងធ្វើឱ្យបញ្ហានៃជីវិតនឹងកាន់តែកើនច្រើនឡើង ។

# ១

## បើឱ្យជ្រើសរើស

បើឱ្យជ្រើសរើសរវាងចំណេះដឹង និងអារម្មណ៍អណ្ដែតអណ្ដូង (ដ្រាម៉ា) គឺមនុស្សភាគច្រើននឹងបោះបង់ចំណេះដឹងចោល រួចហើយជ្រើសរើសយកភាពអណ្ដែតអណ្ដូង ។ បើឱ្យជ្រើសរើសយកការពិតនិងការបោកប្រាស់ គឺថាមនុស្សនឹងរើសយកការបោកប្រាស់ សំខាន់ឱ្យតែសប្បាយៗ ។ បើឱ្យជ្រើសរើសសៀវភៅដែលខ្លួនត្រូវអាន និងសៀវភៅដែលខ្លួនចូលចិត្តអាន គឺថាមនុស្សនឹងរើសយកសៀវភៅដែលខ្លួនចូលចិត្តអាន ។ នេះហើយដែលហៅថារបៀបរស់នៅ

"បំពេញតែតណ្ហានៃខ្លួន" ។

ចង់ជួយខ្លួនឯង ចង់ជួយគ្រួសារ ចង់ជួយជាតិ ប៉ុន្តែបើបានដើរឱ្យតែផុតរឿងខ្លួនឯង គឺល្អណាស់ទៅហើយ ។ ដំណើរជីវិតដែលរស់នៅ "បម្រើតែតណ្ហានៃខ្លួន" បែបនេះ បើទោះបីជាកើត១០០ជាតិទៀត ក៏ស្រាយខ្លួនពីការជាប់ជំពាក់នេះមិនបានផង ។ បើជួបសៀវភៅដែលអាន ពិបាកយល់ គឺត្រូវចេះតស៊ូអានឱ្យយល់ គិតឱ្យដល់ ពាល់ឱ្យត្រូវ។ បើជួបរឿងលំបាកក្នុងជីវិត គឺត្រូវចេះប្រឹងប្រែងយកឈ្នះឱ្យខានតែបាន ឬបើយ៉ាងហោចណាស់ បានប្រឹងប្រែងឱ្យអស់ពីសមត្ថភាពខ្លួនឯងសិន ។ ត្រូវរៀនចេះធ្វើជា មនុស្សដែលអាចតស៊ូនឹងការលំបាក និងយកឈ្នះនូវសេចក្តីឈឺចាប់ ។ ការតស៊ូរបៀបនេះ ទើបវាអាចធ្វើឱ្យ

អំណានជាអំណាច

យើងរីកចម្រើនទៅមុខបាន ។

# ៣

## ហេតុអ្វីត្រូវអាន ហើយអានយ៉ាងម៉េច?

គ្រប់អ្នកដឹកនាំពូកែសុទ្ធតែជាអ្នកពូកែអាន តែគ្រប់អ្នកអានទាំងអស់មិនមែនសុទ្ធតែអាចក្លាយទៅជាអ្នកដឹកនាំទេ ។ ប៉ុន្តែយ៉ាងហោចណាស់ ការអានក៏គង់នឹងអាចប្រាប់យើងទាំងអស់គ្នាឱ្យដឹងថា តើមេដឹកនាំប្រភេទណាដែលយើងគួរដើរតាមដែរ ។ នេះហៅថាអំណានដើម្បីសង្គម ។ ដើម្បីធ្វើឱ្យសង្គមមួយមានភាពអន់ថយ គេពុំចាំបាច់ដុតកម្ទេចសៀវភៅចោលទេ តែគ្រាន់តែពង្វក់ចិត្តមនុស្សកុំឱ្យចង់អាន គឺគ្រប់គ្រាន់ក្នុងការបំផ្លាញប្រទេសទាំងមូលឱ្យ

អន្តរាយបានហើយ ។

ក្នុងមាតុភូមិណាក៏ដោយ គ្រប់គ្នាគួរតែប្រគល់ទឹកដីរបស់ខ្លួន និងប្រជាជនរបស់ខ្លួន ឱ្យទៅប្រទេសដទៃដែលកំពុងឈ្លានពានខ្លួន បើខ្លួនគ្មានសមត្ថភាពការពារ ឬគ្មានសមត្ថភាពអភិវឌ្ឍឱ្យចម្រើនរុងរឿងទេ ដ្បិតប្រទេសដទៃប្រហែលជាមានសមត្ថភាពធ្វើឱ្យរីកចម្រើន ។ នេះហើយគឺជាមូលហេតុដែលយើងត្រូវប្រឹងប្រឹងអាន ។ អានសៀវភៅខ្លះ អានដើម្បីជួយជាតិ ។ រីឯអានសៀវភៅខ្លះទៀតអានដើម្បីជួយខ្លួនឯង ។ បើមែនទែនទៅ ការជួយជាតិ និងជួយខ្លួនឯង គឺមិនសូវខុសគ្នាប៉ុន្មានទេ ។ ចុះតើយើងត្រូវអានយ៉ាងដូចម្ដេច? កុំធ្វើជាទាសករនៃគំនិតរបស់ស្មេរ ។

យើងចំណាយពេលវេលាអានសៀវភៅដូចគ្នា និង

ចំនួនក្បាលសៀវភៅដូចគ្នា តែការជ្រួតជ្រាបទទួលបាន ចំណេះដឹងពីសៀវភៅ គឺវាពុំដូចគ្នាឡើយ ។ អ្នកអានខ្លះមាន សមត្ថភាពពិចារណាខ្ពស់ជាងអ្នកនិពន្ធ ។ គំនិតអ្នកនិពន្ធខ្លះ ជាគំនិតសាមញ្ញ តែបើកម្រិតសមត្ថភាពនៃអ្នកអានខ្ពស់ វានឹងធ្វើឱ្យគំនិតសាមញ្ញផ្តុំសាច់ផ្តុំឈាមក្លាយទៅជាគំនិត អស្ចារ្យ ។ ដូច្នេះហើយ ទើបបានជាយើងជាអ្នកអានត្រូវតែ កុំគិតងាប់ក្រឡាជាមួយគំនិតអ្នកនិពន្ធណាឱ្យសោះ ដ្បិត បើងាប់ក្រឡា គឺស្មើនឹងងាប់បញ្ញា ហើយបើងាប់បញ្ញា គឺ ស្មើនឹងក្លាយទៅជាកញ្ជះនៃគំនិតអ្នកនិពន្ធ ។ អ្នកខ្សត់នូវ ការពិចារណា គឺច្រើនតែធ្លាក់ខ្លួនក្នុងទាសភាពនៃគំនិត ។ ឥរិយាបថបែបនេះ វាពុំធ្វើឱ្យយើងរីកចម្រើនឡើយ ។

# ៣

## អានចំណេញ ឬអានខាត?

អ្នកចំណាយលុយលើសៀវភៅដែលចំណេញគឺបើទិញមកហើយ ត្រូវតែអាន ។ អ្នកដែលចំណេញពេលវេលាលើការអានសៀវភៅ គឺបើអានហើយ ត្រូវតែចេះ ។ អ្នកដែលចំណេញលើចំណេះពីសៀវភៅគឺបើចេះហើយ ត្រូវតែយកមកអនុវត្តជាក់ស្តែង ។ អ្នកដែលចំណេញលើការអនុវត្តន៍ជាក់ស្តែង បើអនុវត្តហើយ គឺត្រូវតែទទួលបានលទ្ធផលល្អ ។អ្នកដែលទទួលផលល្អពិតប្រាកដគឺទទួលជោគជ័យតែគ្មានចិត្តអំនួត ។ចុះអ្នកណាដែលខាតលើការអានសៀវភៅ?

អ្នកទិញសៀវភៅហើយ តែមិនអាន គឺជាការខាតបង់លើការវិនិយោគលុយ ។ អ្នកអានហើយ តែមិនយល់ គឺជាការខាតបង់ពេលវេលា ។ អ្នកយល់ហើយ តែមិនព្រមធ្វើតាមអ្វីដែលត្រូវធ្វើ គឺជាការខាតបង់គំនិតល្អ ។ អ្នកដែលធ្វើហើយ តែមិនបានផលល្អ គឺជាការខាតបង់សកម្មភាព ។ អ្នកធ្វើបានល្អហើយ តែមានចិត្តអំនួត គឺជាការខាតបង់ចរិតលក្ខណៈល្អ ។ បើបាត់បង់ចរិតលក្ខណៈល្អហើយ គឺស្មើនឹងការខាតបង់អ្វី ៗ ស្ទើរតែទាំងអស់នៃជីវិត ។

កូនអ្នកមានខ្លះ អានសៀវភៅតាមតែចិត្តចង់ និងតាមតែការចូលចិត្ត ។ អ៊ីចឹងហើយ ទើបបានជាកូនអ្នកមានខ្លះចាស់ហើយប៉ុន្តែនៅតែក្មេងខ្ចី ។កូនអ្នកមានខ្លះអានសៀវភៅរកតែសប្បាយ ៗ មិនខ្វល់ខ្វាយអ្វី ៗ ទាំងអស់ ។ អ៊ីចឹងហើយ

ទើបបានជាកូនអ្នកមានខ្លះ ខ្វះរសជាតិជីវិត និងស្គាល់ត្រឹមតែសុខ ៗ រហូត ។ ការរស់នៅក្នុងជីវិតជាមនុស្សនេះ បើបានភ្លក្សគ្រប់រសជាតិនៃជីវិត គឺជារឿងដ៏សំខាន់មានអត្ថន័យបំផុត ។ កូនអ្នកក្រ គឺត្រូវបែងចែកឱ្យដាច់រវាងសៀវភៅដែលខ្លួនចូលចិត្តអាន និងសៀវភៅដែលខ្លួនត្រូវតែអាន ។ តើយើងមានលុយប៉ុន្មានដើម្បីទិញសៀវភៅដែលខ្លួនចូលចិត្តអាន? លុយតិច ចំណាយឱ្យត្រូវ គឺនឹងទទួលផលច្រើនប្រៀបដូចជាអ្នករៀនតិច តែចេះច្រើន ។

ខ្ញុំលើកឡើងបែបនេះ គឺសម្រាប់តែស្ថានភាពកូនអ្នកស្រែកសិករប៉ុណ្ណោះ ។ សម្រាប់អ្នកមានលុយច្រើនជីវភាពខ្ពស់បើចង់រស់នៅបែបណាក៏បានដែរ ។ ប៉ុន្តែសម្រាប់កូនអ្នកស្រែ បើបណ្តែតបណ្តោយខ្លួនឱ្យដូចកូនអ្នកមាន គឺ

ប្រាកដជាធ្លាក់ជ្រោះហើយ ។ ពាក្យខ្មែរពោលប្រដៅទុកថា "ឃើញដំរីជុះ កុំជុះតាមដំរី" ។ កុំអានសៀវភៅតាមតែចិត្តចង់ តាមតែតណ្ហា តែត្រូវអានសៀវភៅណាដែលត្រូវអានមានប្រយោជន៍គួរអាន ដ្បិតលុយ១ម៉ឺនរៀល ឬ២ម៉ឺនរៀល ឬ៤ម៉ឺនរៀល គឺមិនមែនតិចទេ ហើយក៏មិនច្រើនប៉ុន្មានដែរ តែសំខាន់មើលមកស្ថានភាពជីវភាពគ្រួសារខ្លួនឯងឱ្យបានច្បាស់ថា " តើគ្រួសារខ្ញុំឬខ្ញុំ គឺជាអ្នកមាន ឬអ្នកក្រ" ។

អំណានជាអំណាច




អក្សរមួយឃ្លានិងសម្ដីមួយម៉ាត់ វាគឺជាអ្នកឆ្លាក់ខួរក្បាលមនុស្ស ។

# ៤

## វិនិយោគលើសៀវភៅ?

អ្នកដែលទិញសៀវភៅហើយ តែមិនឆាប់ប្រឹងអានឱ្យចប់ អានឱ្យយល់ អានឱ្យចេះ គឺស្មើនឹងបានយកលុយទៅវិនិយោគខាត ។ សៀវភៅតម្លៃ ២០០០០រៀល តែបើយើងអានមិនយល់ អានមិនចេះ គឺស្មើនឹងខាតប្រាក់កាស ។ ក្នុងលក្ខខណ្ឌមួយទៀត អានសៀវភៅម្តង ចេះបាន៣០%, អានពីរដង ចេះបាន៦០% ហើយអានបីដង ចេះបាន៩០% ហើយបើបានអានច្រើនដងរហូតដល់ចេះ គឺស្មើនឹងការវិនិយោគចំណេញ ។

បទពិសោធនៃអំណានរបស់ខ្ញុំកន្លងមក និងរហូតមកដល់ពេលឥឡូវនេះ, សៀវភៅមួយក្បាល គឺខ្ញុំត្រូវអានយ៉ាងហោចណាស់ឱ្យបាន៣ដងចប់ដែរ ដ្បិតខ្ញុំបានប្ដេជ្ញាចិត្តថាត្រូវតែប្រើប្រាស់លុយដែលប្រឹងរកដោយលំបាកឱ្យបានផលចំណេះ និងមានប្រសិទ្ធិភាពខ្ពស់បំផុត ។ ពេលយើងទិញសៀវភៅមួយក្បាលមកអាន តែបែរជាអានមិនចេះ អានមិនយល់ មិនព្រមអាន មិនព្រមប្រឹងឱ្យមែនទែន គឺស្មើនឹងខាតលុយដែលប្រឹងទាំងញើសឈាម ឬខាតលុយម៉ាក់ប៉ា ។

លើសពីនេះ យើងក៏មិនទទួលបានផលចំណេញពីចំណេះចេះដឹងដែរ ។ នេះមានន័យថា "លុយក៏អស់ ចំណេះក៏អត់" រហូតដល់ចុងក្រោយ ខាតលុយ ខ្សត់ចំណេះ ចេះ

មិនទៅមុខ ជីវិតមិនរីកចម្រើន ។ សូមយើងចាំថា “លុយគឺជាមធ្យោបាយប្រើប្រាស់ក្នុងការរស់នៅ ហើយលុយក៏មិនសូវងាយស្រួលរកប៉ុន្មានដែរ” ។ អ្នកអានដែលឆ្លាត គឺត្រូវពិចារណាឱ្យច្បាស់លាស់មែនទែនពីបញ្ហាទិញសៀវភៅទុកចោល មិនព្រមអាន ឬអានបានតិចដង ឬអានមិនចេះ ។

ខ្ញុំសូមលើកទឹកចិត្តឱ្យប្រឹងអានឱ្យចប់ អានឱ្យចេះខ្លះ បើទោះបីជាសៀវភៅខ្លះមិនល្អយ៉ាងណា ឬសៀវភៅគ្រាស់យ៉ាង ឬសៀវភៅអានពិបាកយល់យ៉ាងណាក៏ដោយ ។ ក្នុងនាមយើងជាអ្នកអាន និងក្នុងនាមយើងជាអ្នកវិនិយោគលើការទិញសៀវភៅអាន សូមកុំទិញសៀវភៅទុកចោលឱ្យសោះ ជាពិសេសគឺបងប្អូនអ្នកស្រែចម្ការដែលមិនសូវមានលុយកាក់គ្រប់គ្រាន់ ។ របៀបនៃការវិនិយោគលើសៀវភៅ

របស់ខ្ញុំកន្លងមក គឺមានប្រសិទ្ធិភាពខ្ពស់  ដ្បិតមិនត្រឹមតែខ្ញុំអានយល់ទេ តែរហូតដល់យល់ស៊ីជម្រៅ ព្រមទាំងអាចសរសេរ កត់ត្រាចំណាំ និងវិភាគលើគំនិតបានយ៉ាងសមរម្យទៀតផង ។ ចុងក្រោយ សៀវភៅទិញរួចហើយ ត្រូវតែអានតែបើមិនអានទេ គឺខាតបង់ ខាតលុយកាក់ និងមិនចេះពីរបៀបចាយវាយលុយលើការវិនិយោគលើសៀវភៅ ។

# ៥

## សៀវភៅជាមិត្តល្អ?

ខ្ញុំចេះតែឆ្ងល់មនុស្សខ្លះ ទាល់តែពេលជួបទុក្ខ ទើបរត់ទៅរកដំណោះស្រាយ ។ ពេលសុខ ចេះតែសប្បាយដាច់បង្ហៀរ តែដល់ពេលទុក្ខវិញ ក៏ប្រឹងរត់យ៉ាងវេទនា ។ ពាក្យខ្មែរលោកថា "ការពារប្រសើរជាងព្យាបាល" ។ ពេលសុខពេលស្រួល តែបែរមិនត្រៀមសម្ភារៈប្រយុទ្ធ ក្រែងលោអាសន្នអន់ក្រមកញ្ជាំញីដោយប្រការណាមួយ តែដល់ពេលទុក្ខ ទើបប្រឹង ។ អាល់ប៊ឺត អាស្តាញ (Albert Einstein) ដែលជារូបវិទូសតវត្សរ៍ទី២០ និយាយថា "មនុស្សឆ្លាត

តែងដោះស្រាយបញ្ហា តែអច្ឆរិយបុគ្គល តែងការពារបញ្ហាកុំឱ្យកើតឡើង" ។

សុភាសិតចិនលើកឡើងថា "ពេលក្រ កុំអស់សង្ឃឹម ហើយពេលមាន កុំភ្លើតភ្លើន" ។ មនុស្សជាច្រើន មិនមែនស្លាប់ដោយសារតែខ្លួនខ្សោយ ឬមិនមែនខ្លាំងដោយសារតែខ្លួនខ្លាំងទេ ។ ប៉ុន្តែ មនុស្សស្លាប់ដោយសារតែបាក់ទឹកចិត្ត បាត់សតិដឹង ភ្លេចទប់ស្មារតីពេលជួបបញ្ហាធំ ហើយមនុស្សខ្លាំង គឺខ្លាំងដោយសារតែមានសតិដឹងជាប់ជានិច្ច ។ តើដឹងសតិរបៀបយ៉ាងម៉េច? សតិដឹង គឺដឹងថា "ក្នុងលាភមានគ្រោះ ឬក្នុងគ្រោះមានលាភ" ។ គ្មានជ័យជម្នះណាដែលនឹងឋិតថេរទេ ដរាបណាបើយើងភ្លេចខ្លួន ។ ខ្មែរយើងមានមេរៀនអំពីរឿង "វៃ និងស្រមោច" ។

ខ្ញុំតែងឮពាក្យថា "ចូរប្រើសន្តិភាពឱ្យមានប្រសិទ្ធភាព"។ ពាក្យនេះ គឺចង់ដាស់តឿនក្រើនរម្លឹកដល់មនុស្សទាំងឡាយណាដែលមានស្ថានភាពល្អ ឱ្យចេះប្រើប្រាស់ពេលវេលាល្អ មកបង្កើតប្រយោជន៍ដល់ខ្លួនឯងនិងត្រៀមខ្លួន ដ្បិតអនាគតយើងមិនអាចដឹងថា "តើមានរឿងហេតុអាក្រក់អ្វីកើតឡើងដោយយថាហេតុណាមួយឡើយ"។ ចំពោះការរៀន ការសិក្សា ឬការអានសៀវភៅក៏ដូចគ្នាដែរ។ អ្នកខ្លះនិយាយថា "សៀវភៅគឺជាមិត្ត" តែខ្ញុំយល់ថា "សៀវភៅខ្លះកំដរអ្នកខ្លះ បានត្រឹមតែពេលកើតទុក្ខប៉ុណ្ណោះ តែដល់ពេលសុខស្រួល ក៏ចិត្តដាច់បោះបង់សៀវភៅចោល"។

មិត្តល្អ កំដរគ្នាដល់ថ្ងៃស្លាប់។ បើស្រឡាញ់ខ្លួនឯងយើងគួរតែទម្លាប់ចាប់កាន់សៀវភៅអានជាដរាប ដោយ

កុំយកមកអានម្តងម្កាលពេលខ្លួនឯកោ ។ សៀវភៅ ផ្តល់ចំណេះដឹងច្រើនដល់មនុស្ស ។ ចំណេះដឹងច្រើន បញ្ហាជីវិតមិនសូវមានទេ តែបើចំណេះដឹងតិចវិញ បញ្ហាជីវិតវានឹងកើនឡើងច្រើនសម្បើមណាស់ ។ ចូរយើងប្រឹងអានដើម្បីទុកចំណេះដឹងដោះស្រាយបញ្ហាពេលអាសន្ន តែកុំដល់បញ្ហាកើតឡើងហើយ រត់ទៅរកសៀវភៅមកអានឱ្យសោះ ។

ពេលខ្លះរត់មិនទាន់ដល់កន្លែងរក្សាទុកដំណោះស្រាយផង ក៏អាចដាច់ខ្យល់ស្លាប់ក៏មានដែរ ។ ខ្ញុំហ៊ានធានាថា ចំណេះដឹងវានឹងធ្វើឱ្យយើងចេះរស់នៅ ។ ពេលដល់ដំណាក់កាលដែលយើងចេះរស់នៅពិតប្រាកដហើយ ចំណេះដឹងវានឹងក្លាយទៅជាសំរាម ។ ខ្ញុំនិយាយថា “ចំណេះដឹងជាសំរាម” ដ្បិតពេលណាមួយ យើងបានជ្រាបពីចំណេះដឹង

ខាងចិត្តវិញ្ញាណស៊ីជម្រៅ យើងនឹងទទួលស្គាល់ថា សេចក្តីសុខគឺនៅនឹងចិត្ត តែមិនមែននៅនឹងក្បាលដែលមានទិន្នន័យច្រើនហូរហៀរទេ ។

# ៦

## សៀវភៅបេះដូង ឬសៀវភៅខួរក្បាល?

“សៀវភៅខ្លះនិពន្ធឡើងសម្រាប់ប្រភេទអ្នកអានដែលប្រើបេះដូង ហើយសៀវភៅខ្លះទៀតនិពន្ធឡើងសម្រាប់ប្រភេទអ្នកអានដែលប្រើខួរក្បាល” ។

ខួរក្បាលមានគតិបណ្ឌិតរបស់ខួរក្បាល ហើយបេះដូងមានគតិបណ្ឌិតរបស់បេះដូង ។ តើអ្វីទៅជាគតិបណ្ឌិតរបស់ខួរក្បាលហើយអ្វីទៅជាគតិបណ្ឌិតរបស់បេះដូង? គតិបណ្ឌិតរបស់ខួរក្បាល គឺចាស់គំនិត (ខួរក្បាលមានចំណេះដឹង) ហើយគតិបណ្ឌិតរបស់បេះដូង គឺចាស់ចិត្ត (បេះដូងមានការ

លត់ដំ) ។ ខ្មែរយើងនិយាយថា "ចាស់ចិត្ត ចាស់គំនិត" ។

បេះដូងមានលក្ខណៈអស្ចារ្យជាងខួរក្បាលនៅត្រង់ថា "បេះដូងអាចពាល់ត្រូវនូវអារម្មណ៍គ្រប់បែបយ៉ាង" ។ អារម្មណ៍ល្អ ដោយសារមានខួរក្បាលគិតល្អ តែអារម្មណ៍នឹងវក់វី នៅពេលខួរក្បាលវក់វី ។ ក្នុងអត្ថិភាពជាមនុស្សនៅលើផែនដីនេះ គ្មានបុគ្គលណាម្នាក់ឆ្កួតវង្វេងដោយសារតែខ្លួនមានចំណេះដឹងច្រើននោះទេ តែមនុស្សភាគច្រើនឆ្កួតវង្វេងដោយសារតែគ្រប់គ្រងបេះដូងខ្លួនឯងមិនបាន ។

សុភាសិតខ្មែរពោលថា "កម្ពិលអៀនប្រៀន បួសហើយមិនរៀន បន្ទោសថាខ្លៅ" ។ យុវជនដែលចង់ដើរទៅមុខលឿនជាងអ្នកដទៃ និងចង់ខ្លាំងជាងអ្នកដទៃ ត្រូវអានសៀវភៅដែលអាចផ្ដល់ចំណេះដឹងដល់ខួរក្បាលឱ្យច្រើន ។

ពេលដែលមានចំណេះដឹងជ្រៅជ្រះ យើងនឹងយល់ច្បាស់ថា តាមពិតការរស់ដោយបញ្ញា និងរស់ដោយមានគោលការណ៍ គឺមានតម្លៃជាអមតៈ ។

ផ្ទុយទៅវិញ ក្នុងស្ថានភាពជាយុវវ័យ បើយើងបណ្តោយឱ្យបេះដូងគ្រប់គ្រងខ្លួនប្រាណបានទាំងស្រុង គឺមានន័យថា យើងជាមនុស្សដែលរវល់ចង់រវល់ស្រោយ ។ ពាក្យថា "រវល់ចង់រវល់ស្រោយ" នៅទីនេះ គឺខ្ញុំចង់មានន័យថាចិត្តយើងវក់វីនឹងរឿងទុក្ខ រឿងសោក រឿងសប្បាយ និងមានអារម្មណ៍រវើរវាយ ដែលវានឹងធ្វើឱ្យយើងគ្មានពេលរៀនសូត្ររហូតដល់ដើរថយក្រោយ ឬដើរយឺត ឬដើរមិនទៅមុខ ។

យុវជនដែលចេះគ្រប់គ្រងចិត្តខ្លួនឯងបានទាំងខ្លួននៅវ័យក្មេង គឺជាមនុស្សអស្ចារ្យខ្លាំងបំផុត ។ យុវជនបែបនេះ

ហៅថា “មនុស្សចាស់ទុំ”។ មនុស្សចាស់ទុំមានន័យថា ពុំរំជើបរំជួលនឹងរឿងរ៉ាវគ្រប់យ៉ាងដែលបានកើតឡើងចំពោះខ្លួនឡើយ។ បើខ្លួនមានចំណេះដឹង ក៏គ្មានចិត្តអំនួតដែរ។ បើខ្លួនចាញ់ប្រៀបអ្នកដទៃ ក៏ពុំអស់សង្ឃឹមដែរ។ បើខ្លួនជោគជ័យ ក៏ពុំដាច់បង្អៀវដែរ។ ចិត្តនឹងន ចិត្តមានជំហរ ចិត្តស្ងប់ ចិត្តដែលអត់ធ្មត់ ចិត្តដែលប្រឹងប្រែងដើរទៅមុខជាមួយនឹងបុព្វហេតុនៃជីវិតត្រឹមត្រូវ។

*“There is a wisdom of the head, and a wisdom of the heart.” – Charles Dickens*



*ការងារសំខាន់ៗ និងការងារចាំបាច់ជាច្រើននាពេលខាងមុខ វាលំបាក ជាងការអានសៀវភៅ ៤០០ ទៅ៥០០ទំព័រ ។*

# ៧

## ហេតុផលឃោរឃៅ មនោសញ្ចេតនាល្ងង់ខ្លៅ

ហេតុផលនៅនឹងបុរស ហើយមនោសញ្ចេតនានៅនឹងនារី ។ មនុស្សប្រុសខ្លះចិត្តរឹង តែមិនឃោរឃៅទេ ។ រីឯមនុស្សស្រីខ្លះវិញមានចិត្តទន់ តែពេលខ្លះឃោរឃៅបំផុត ។ មនុស្សស្រីខ្លះ ពេលខ្លះក្លាយទៅជាមនុស្សឆោតល្ងង់ ដ្បិតដោយសារប្រើតែបេះដូងសុទ្ធសាធ ដោយខ្វះបញ្ញាពីខួរក្បាល ។

មនុស្សប្រុសខ្លះ ពេលខ្លះប្រើហេតុផលល្បិចកិច្ច ដ្បិតដោយសារប្រើតែខួរក្បាលសុទ្ធសាធដោយខ្វះមនោសញ្ចេតនា

ពីបេះដូង ។ ជីវិតនឹងប្រែក្លាយទៅជាឈឺចាប់ នៅពេលណា ដែលយើងខ្វះលំនឹង ថ្លឹងមិនស្មើរវាងខួរក្បាលនិងបេះដូង ។ ក្នុងសង្គម មានមនុស្សដែលទទួលបានការអប់រំខាងផ្នែក ខួរក្បាលជាច្រើន ហើយក៏មានមនុស្សដែលខ្វះការអប់រំ ខាងផ្នែកបេះដូងជាច្រើនផងដែរ ។

សញ្ញាបត្រ វាពុំបានកំណត់ពីសេចក្ដីសុខនៃជីវិត ឬ កំណត់ការអប់រំពិតដ៏ត្រឹមត្រូវទេ ។ ភាពឆោតល្ងង់ក្នុងរឿង មនោសញ្ចេតនា វាធ្វើឱ្យមនុស្សរងការឈឺចាប់ខ្លោចផ្សា ។ យើងគួរតែនាំគ្នាឈោងចាប់វិជ្ជាជាមុន ដ្បិតវិជ្ជាគឺជាគ្រឿង ការពារកុំឱ្យបេះដូងរងគ្រោះថ្នាក់ ។ ចុងក្រោយនៃជីវិត គឺជា រឿងបេះដូង ។ អ្នកខ្លះមើលឃើញខ្ញុំថាជាអ្នកខួរក្បាល និយម ហេតុផលនិយម គ្មានមនោសញ្ចេតនា តែខ្ញុំឱ្យតម្លៃ

មនោសញ្ចេតនា និងសេចក្ដីស្រឡាញ់ ជាងចំណេះហេតុផលក្នុងខួរក្បាល ។

អ្នកឆ្លាតខ្លះ អ្នកចេះខ្លះ គឺជាអ្នកឆ្លាតខាងផ្លូវខុស និងចេះខាងផ្លូវអាក្រក់ ។ ចំណេះតែងមានមុខពីរ ។ អ្នកខ្លះមានចំណេះកប់ពពក តែធ្វើសេចក្ដីល្អពុំបានប៉ុនក្រចកជើងមនុស្សដែលមានបេះដូងល្អបរិសុទ្ធផង ។ ឧទាហរណ៍ក្នុងរឿងស្នេហា បើចង់បែកគ្នាពីនរណាម្នាក់ គឺមិនខ្វះទេហេតុផល វិធីសាស្ត្រ និងល្បិចបែកទេ ដ្បិតខួរក្បាលមានសមត្ថភាពរកឧបាយកល ។

អ្នកដែលគ្មានមនោសញ្ចេតនា គឺប្រៀបដូចជាម៉ាស៊ីនអ៊ីចឹងហើយបើរស់នៅជាមនុស្សម៉ាស៊ីនគឺយើងគួរស្លាប់ទៅវិញល្អជាង ។ រីឯអ្នកដែលរស់នៅគ្មានបញ្ញា ប្រើមនោសញ្ចេតនា

ដោយខ្វះបញ្ញា ឬប្រើមនោសញ្ចេតនាខុសកាលៈទេសៈ ឬខុសមនុស្ស គឺនឹងរស់នៅប្រៀបដូចជាមនុស្សស្លាប់ ឬស្លាប់ទាំងខ្លួននៅរស់ ហើយជីវិតបែបនេះ គឺរស់នៅវេទនាជាងស្លាប់ ។ ជីវិតបែបនេះ គឺជាជីវិតដែលរស់នៅកំដរ និងធ្វើជាឧបករណ៍សម្រាប់អ្នកឆ្លាតបោកប្រាស់ប៉ុណ្ណោះ ។ និយាយដោយខ្លី ខ្ញុំនៅតែលើកទឹកចិត្តឱ្យប្រឹងរៀនសូត្រសិន ក្រេបវិជ្ជា ធ្វើមនុស្សល្អ ។

# ៨

## ត្រូវចេះជ្រើសរើសសៀវភៅអាន

អាហារជាច្រើនប្រភេទបានដាក់លើតុឱ្យអ្នកទទួលទានជ្រើសរើស តែបើយើងចូលចិត្តញ៉ាំអាហារបែបណា វាជាជម្រើសរបស់យើងទេ ។ សាច់ឈាមស្អាត ឬមិនស្អាត ឬធ្វើឱ្យយើងធាត់ឬស្គម វាអាស្រ័យលើអាហារដែលយើងញ៉ាំ ។ ចំពោះសៀវភៅក៏ដូច្នោះដែរ ។ កុំយល់ថាការអានសៀវភៅតាមចិត្តចង់ អាចផ្តល់ចំណេះដឹងពិតប្រាកដដល់យើងឱ្យសោះ ដ្បិតគ្រប់យ៉ាង វាត្រូវការភាពមានវិន័យត្រឹមត្រូវ ការជ្រើសរើសសៀវភៅត្រឹមត្រូវ និងការព្យាយាមត្រូវជា

ប្រក្រតី ។ ខ្ញុំចេះពីវិធីផ្សំថ្នាំព្យាបាលរោគ ហើយពេលជាសះស្បើយ ក៏នឹងធ្វើឱ្យមនុស្សមានសុខភាពផ្លូវចិត្តល្អ និងផ្លូវគំនិតរឹងមាំ ។ ប៉ុន្តែវិធីផ្សំថ្នាំ ខ្ញុំបានប្រាប់រួចហើយ ហើយថ្នាំក៏បានផ្សំរួចហើយដែរ តែអ្នកជំងឺព្រមលេបឬមិនលេប នោះវាជារឿងរបស់អ្នកជំងឺ ។ ព្រះអាទិត្យតែងតែរះជានិច្ច តែផ្កាចេញមកទទួលពន្លឺ ឬអត់ វាជារឿងរបស់ផ្កា ។

សៀវភៅអានល្អៗមានច្រើនរាប់មិនអស់ តែមិនប្រាកដថាគ្រប់គ្នាសុទ្ធតែមានកែវភ្នែកល្អ មានខួរក្បាលល្អជ្រើសរើសសៀវភៅ ដែលអាចពង្រីកចំណេះដឹង និងទាញយកចំណេះដឹងមកប្រើការបានទេ ។ អានសៀវភៅកាន់តែច្រើន ទើបអ្នកនឹងដឹងថា "សៀវភៅខ្លះត្រូវបានគេសរសេរឡើងដើម្បីជួយអប់រំគំនិត បណ្ដុះទម្លាប់ដល់មនុស្សក្នុងសង្គម

និងស្រោចទឹកដាក់ដីដល់ជនសង្គម ។ រីឯសៀវភៅខ្លះទៀត ត្រូវបានគេសរសេរដើម្បីរំសាយអារម្មណ៍អ្នកនិពន្ធ ។ លើស ពីនេះ មានសៀវភៅខ្លះទៀត ក៏ត្រូវបានបង្កើតឡើងដើម្បីតែ ផលប្រយោជន៍ហិរញ្ញវត្ថុហួសហេតុផងដែរ ។ អានសៀវភៅ ដើម្បីចំណេះដឹង មិនមែនអានដើម្បីតែអានទេ ។



អ្នកក្រដែលគ្មានលុយរៀន គ្មានឱកាសរៀនសាលាល្អៗ គ្មានអ្នកជួយជ្រោមជ្រែង បើបណ្តោយខ្លួនឱ្យដូចកូនអ្នកមាន គឺពុំបានឡើយ ។

# ៩

## គន្លឹះខ្លះៗនៃការអានឱ្យមានប្រសិទ្ធិភាព

ការអាន វាអាចផ្លាស់ប្តូរជីវិតមនុស្សម្នាក់ៗបាន ។ បើទោះបីជាបែបនេះក៏ដោយ តែមិនមែនគ្រប់គ្នាសុទ្ធតែអាចតាំងចិត្តដាក់កាយអត់ធ្មត់អាននោះទេ ។ អ្នកខ្លះអានព្រោះតែចូលចិត្ត តែអ្នកខ្លះទៀតអានព្រោះតែមានគោលដៅច្បាស់លាស់ក្នុងការផ្លាស់ប្តូរខ្លួនឯង ក្នុងរយៈពេលតាំងចិត្តណាមួយ ។ ក្នុងនាមជាអ្នកអាន គឺយើងត្រូវបែងចែកឱ្យច្បាស់រវាងសៀវភៅដែលខ្លួនចូលចិត្តអាន និងសៀវភៅដែលខ្លួនត្រូវតែអាន ។ នេះជាគំនិតដែលខ្ញុំនិយាយហើយ

និយាយទៀត ។ រឿងខ្លះវាមិនខុសមិនត្រូវទេ តែត្រូវឱ្យមានមុនមានក្រោយ (អាទិភាពនៃអំណាន) ។ បើខ្លួនក្រហើយកុំចង់សប្បាយ តែត្រូវជ្រើសយកការប្រឹងប្រែងជាមុន ។ ខ្មែរយើងតែងនិយាយថា "នឿយមុនស្រណុកក្រោយ" ។ ប៉ុន្តែបើមានបានហើយ ចង់សប្បាយបែបណា ក៏គ្មានបញ្ហាដែរ ។ តើហេតុអ្វីត្រូវយល់ច្បាស់ពីរឿងអាននេះ? បញ្ហារបស់យើង គឺរឿងលុយ រឿងពេលវេលា និងរឿងប្រសិទ្ធិភាពដែលទទួលបានពីការអាន ។ អ្នកក្រ គ្មានលុយច្រើន គឺត្រូវចេះជ្រើសរើសសៀវភៅដែលល្អ បានអានហើយចេះច្រើន ។ ចង់ដឹងសៀវភៅណាល្អ ឬមិនល្អ គឺត្រូវចេះសួរអ្នកដែលធ្លាប់បានអានមុន ។ ការសួរនេះក៏ត្រូវប្រយ័ត្នដែរ ដ្បិតអ្នកខ្លះចូលចិត្តអានប្រលោមលោក អ៊ីចឹងសៀវភៅល្អ គឺប្រលោមលោកហើយ ។ គំនិតគ្រប់គ្រងពិភពលោក ។

គ្មានមនុស្សណាវង្វេងដោយសារតែចេះដឹងច្រើន មានគំនិតច្រើនទេ តែអ្នកដែលវង្វេងភាគច្រើន គឺអ្នកដែលរស់នៅអវិជ្ជា ប្រើតែអារម្មណ៍ហួសជ្រុលពេក ។ អ្នកក្រពេលវេលាគ្មានពេលអានច្រើន គឺត្រូវចេះជ្រើសរើសសៀវភៅដែលល្អអានហើយចេះច្រើន ។ ខ្ញុំនៅតែនិយាយម្ដងហើយម្ដងទៀតថា “មិនមែនឱ្យតែសៀវភៅ សុទ្ធតែល្អទាំងអស់ទេ ដ្បិតសៀវភៅខ្លះសរសេរបំពុលសង្គម ឬបំពុលអ្នកអាន ឬសរសេរក្នុងប្រយោជន៍ហិរញ្ញវត្ថុជ្រុលពេក” ។

ខ្ញុំតែងតែចែករំលែកនូវគំនិតជាញយៗដងថា “កុំធ្វើជាអ្នកអានដែលជាប់រស់នឹងគំនិតអ្នកនិពន្ធ ឬកុំធ្វើជាខ្ញុំកញ្ជះនៃគំនិតរបស់អ្នកនិពន្ធណាម្នាក់ឱ្យសោះ” ។ បើយើងស្គាល់ខ្លួនឯងច្បាស់ គឺយើងនឹងទទួលស្គាល់ថាខ្លួនឯងខ្លាំង តែបើ

យើងវង្វេងវិញ  គឺជីវិតយើងរស់នៅត្រឹមតែជាឧបករណ៍ប្រើប្រាស់របស់អ្នកដទៃ  និងធ្វើបានត្រឹមជាអ្នកដើរតាម ឬត្រូវបានអ្នកដទៃបោកប្រាស់ប៉ុណ្ណោះ ។ អ្វីដែលមានក្នុងខ្លួនមនុស្សម្នាក់ៗ អំណាចផ្លូវចិត្តដែលមានក្នុងខ្លួនមនុស្សម្នាក់ៗ គឺវាខ្លាំងលើសពីអ្វីដែលខួរក្បាលយើងគិតទៅទៀត ។ តើអានបែបណាទើបបានមានប្រសិទ្ធិភាព?  ខ្ញុំបានឃើញសំណេរចែករំលែកនូវទស្សនៈជាច្រើនដែលនិយាយអំពីការអានដែលមានប្រសិទ្ធិភាព ។ ប៉ុន្តែយើងត្រូវបែងចែកឱ្យដាច់រវាងការអានសៀវភៅជំនាញបច្ចេកទេស ការអានសៀវភៅប្រលោមលោក និងការអានសៀវភៅអភិវឌ្ឍខ្លួន ឬសៀវភៅគំនិត ។  សំណួរសួរថា  “តើឱ្យតែអ្នកអាន គឺសុទ្ធតែពូកែទាំងអស់ឬយ៉ាងណា? តើឱ្យតែសៀវភៅ សុទ្ធតែល្អទាំងអស់ឬយ៉ាងណា?  តើឱ្យតែចំណេះដឹង សុទ្ធតែល្អទាំងអស់ឬ

យ៉ាងណា?" ការអានដែលត្រឹមត្រូវ គឺត្រូវអានសៀវភៅល្អ អានដោយយល់នូវវប្បធម៌នៃសៀវភៅ អានដោយស្គាល់នូវប្រវត្តិនៃអ្នកសរសេរសៀវភៅ អានដោយចេះគិតពិចារណាស៊ីជម្រៅ អានដោយចេះបន្សុទ្ធចំណេះដឹង និងអានដោយចេះប្រើចំណេះដឹងឱ្យត្រូវកាលៈទេសៈ ឱ្យត្រូវពេលវេលា ឱ្យត្រូវមនុស្ស និងឱ្យត្រូវទីតាំង ។ អ្នកដែលមិនចេះអាន គឺចូលចិត្តអានសៀវភៅយកតែចប់ តែពុំអានយកចេះ ឬពុំអានយកយល់ និងពុំអានយកគុណភាពទេ ។ អ្នកអានសៀវភៅត្រឹមតែយកឱ្យចប់ៗ គឺស្មើនឹងពុំចេះ ។ អ្នកដែលអានយកចេះ គឺតែងអានសៀវភៅមិនងាយចប់ ។ តើត្រូវអានបែបណាទើបចេះ? តើអ្វីទៅជាការអានប្រកបដោយការពិចារណាស៊ីជម្រៅ?

ខ្ញុំបានបែងចែកពីរបៀបអានជា ៣ដំណាក់កាល។ ដំណាក់កាលទី១.មុនពេលអានគឺចេះជ្រើសរើសសៀវភៅអាន ដ្បិតមនុស្សដែលអាចទទួលបានប្រយោជន៍ពីសៀវភៅទៅបាន លុះត្រាណាតែយើងជ្រើសរើសសៀវភៅអានបានត្រឹមត្រូវ។ ក្រៅពីនេះ មុនពេលសម្រេចចិត្តថាត្រូវអាន គឺត្រូវដឹងពីប្រវត្តិអ្នកនិពន្ធសិន។ ការសិក្សាពីប្រវត្តិអ្នកនិពន្ធវាអាចធ្វើឱ្យយើងដឹងពីទំនោររបស់ស្មេរជាពិសេសសៀវភៅប្រវត្តិសាស្ត្រ។ ស្មេរខ្លះ គឺជាស្មេរមុខលុយ ឬជាស្មេរឧបករណ៍នយោបាយ ឬហៅថា “Money Writer”។ ស្មេរបែបនេះ គឺជាស្មេរដែលត្រូវបានអ្នកនយោបាយទិញទឹកប៊ិកឱ្យសរសេរបំភ្លៃការពិត ឬសរសេរគាំទ្រ ឬប្រឆាំងទៅតាមអ្វីដែលគេចង់ឱ្យសរសេរ។ ចំពោះសៀវភៅខ្លះក៏អ៊ីចឹងដែរ ដូចជាអ្នកនិពន្ធខ្លះគឺជាគ្រិស្តសាសនិក ឬអ្នកនិពន្ធ

ខ្លះជាពុទ្ធសាសនិក ឬអ្នកនិពន្ធខ្លះមានទំនោរផ្សេងៗគ្នា ។ អ្នកនិពន្ធមានប្រវត្តិបែបណា មានទំនោរទៅខាងណា គឺនឹងធ្វើការតែងនិពន្ធ ក៏មានទំនោរផងដែរ ។ ឧទាហរណ៍ បើអ្នកនិពន្ធជាអ្នកមានសីលធម៌ ឬមានចរិតខ្វល់ពីសីលធម៌ គឺសំណេរក៏មានលក្ខណៈប្រកាន់គោលការណ៍សីលធម៌ច្រើនដែរ ។ បើអ្នកនិពន្ធមានទំនោរជាអ្នកយុទ្ធសាស្ត្រ គឺសំណេរនឹងមានចរិតល្បិចច្រើន ។ បើអ្នកនិពន្ធជាមនុស្សលេងសើចច្រើន ឬជាមនុស្សដែលចូលចិត្តប្រើអារម្មណ៍ច្រើន គឺសំណេរនឹងមានលក្ខណៈប្រើអារម្មណ៍ ។ បើអ្នកនិពន្ធជាអ្នកប្រឹង សំណេរនឹងបង្ហាញពីលក្ខណៈនៃការជំរុញឱ្យអ្នកអានប្រឹងដែរ ។ បើអ្នកនិពន្ធជាមនុស្សជ្រុលនិយម មិនថាក្នុងរឿងសាសនាក្តី ឬរឿងនយោបាយក្តី គឺសំណេរនឹងមានលក្ខណៈជ្រុលនិយម ។ នេះហើយដែលហៅថា

ចរិតអ្នកនិពន្ធបែបណា ផ្លែផ្កានៃសំណេរក៏បែបនោះដែរ ។

ជាទូទៅ ខ្ញុំសូមនិយាយថា “None Fits All” ឬមានន័យថាគ្មានអ្វីដែលប្រើបានគ្រប់កាលៈទេសៈ ឬត្រឹមត្រូវគ្រប់ពេល ឬប្រើបានរហូតទេ ។ តាមបទពិសោធនៃការអានរបស់ខ្ញុំ ខ្ញុំតែងតែកំណត់នូវចរិតលក្ខណៈអ្នកនិពន្ធ និងសៀវភៅដូចជា៖ បើចង់ចេះដឹងផ្នែកសីលធម៌ ឬការពារថ្លៃថ្នូរបែបវិញ្ញូជន កុំភ្លេចគិតដល់សៀវភៅរបស់ ខុង ជឺ ។ បើចង់រស់នៅបានសុខ ស្របតាមធម្មជាតិដូចទឹកហូរ កុំភ្លេចនឹកគិតដល់សៀវភៅរបស់ ឡៅ ជឺ ។ បើចង់រៀនផ្នែកក្បួនយុទ្ធសាស្រ្ត កុំភ្លេចនឹកគិតដល់សៀវភៅរបស់ ស៊ុន ជឺ, ស៊ុន ពីង, ចាង លៀង ។ បើចង់រួចរដោះចិត្ត ដឹងរឿងក្នុងខ្លួនស៊ីជម្រៅ ការត្រាស់ដឹងដល់និព្វានជាតិនេះក្តី ឬ

ជាតិក្រោយក្តី កុំភ្លេចនឹកដល់ព្រះពុទ្ធ ។ ចង់ដឹងរបៀបស្រឡាញ់ដោយឥតលក្ខខណ្ឌ កុំភ្លេចនឹកដល់ព្រះយេស៊ូ ។ បើចង់ដឹងរបៀបដឹកនាំខ្លួនឱ្យក្លាយទៅជាមេដឹកនាំខ្លាំង ជាក្សត្រពូកែ កុំភ្លេចនឹកដល់ភីស្មៈ ព្រះវិទូ អរជុន និងគ្រិស្ណៈ ។ បើចង់រៀនក្បួនរក្សាសច្ចៈ កុំភ្លេចរៀនតាមព្រះរាម ។ បើចង់ដឹងពីការគ្រប់គ្រងស្ថាប័ន គឺត្រូវអានសៀវភៅរបស់ Peter F. Drucker ។ បើចង់ចេះពីមូលដ្ឋាននៃភាពជាអ្នកដឹកនាំ គឺត្រូវអានសៀវភៅរបស់ Xenophon និង Matsushita Kōnosuke និងសៀវភៅតាមផ្នែក ៗ ជាច្រើនទៀត ។ល ។ ក្រោយបានស្គាល់ពីប្រវត្តិអ្នកនិពន្ធហើយ គឺយើងត្រូវស្គាល់ពីប្រភពសៀវភៅ ។ ត្រង់ចំណុចនេះ គឺខ្ញុំចង់សំដៅទៅលើវប្បធម៌សង្គម ស្ថានភាពសង្គម និងរបៀបរស់នៅរបស់មនុស្សក្នុងសង្គម ។ សៀវភៅខ្លះមានប្រភពចេញពីវប្បធម៌

សង្គមផ្សេង ។ ជាក់ស្តែង អ្នកខ្លះបានអានសៀវភៅបរទេសច្រើន តែមិនដឹងថា តើគំនិតបរទេសខ្លះពិតជាអាចប្រើបានក្នុងសង្គមខ្មែរដែរឬទេ ? ការដឹងពីវប្បធម៌សង្គម ជាពិសេសលក្ខខណ្ឌសង្គមវិជ្ជានេះ គឺវាមានភាពសំខាន់ខ្លាំងណាស់ ដ្បិតបើយើងមិនដឹងពីវប្បធម៌នៃសៀវភៅទេ គឺយើងនឹងស្រូបយកគំនិតមកប្រើក្នុងសង្គមយើង ដែលមានវប្បធម៌មិនដូចសង្គមផ្សេងទាំងទទឹងទិស ។ ការមិនយល់ពីរឿងនេះ គឺគ្រោះថ្នាក់ណាស់ ប្រៀបដូចជា ម៉ៅ សេទុង និង ប៉ុល ពត... ស្រូបយកគំនិតម៉ាក្ស លេនីន មកអនុវត្តអ៊ីចឹង ។

ឧទាហរណ៍ គំនិតទីផ្សារបណ្តាញ (Network Marketing/MLM) របស់មហាសេដ្ឋីឪពុកអ្នកមានបង្រៀនកូនអ្នកក្រ រ៉ូប៊ឺត ធីយ៉ូសាគី គឺប្រើមិនសូវត្រូវនឹងស្ថានភាពសង្គម

ខ្មែរទេ ។ ដំណាក់កាលទី២. ពេលកំពុងអាន គឺយើងត្រូវចេះគិតឱ្យបានច្រើន ។ ខ្ញុំនៅចាំសម្ដីរបស់អ្នកប្រាជ្ញខាងរូបវិទ្យា អាល់ប៊ឺត អាញស្តាញ ដែលលោកនិយាយអំពីការអានថា "មនុស្សណាដែលអានច្រើនបំផុត តែបានប្រើប្រាស់ខួរក្បាលគិតតិចតួចបំផុត គឺនឹងធ្លាក់ចូលទៅក្នុងទម្លាប់នៃការខ្ជិលគិត" ។ ត្រង់ចំណុចនេះ ខ្ញុំអាចនិយាយបានថា អ្នកអានមិនត្រូវធ្វើជាខ្ញុំកញ្ជះនៃគំនិតរបស់បុគ្គលណា ទស្សនវិទូណា អ្នកត្រាស់ដឹងណា ឬអ្នកនិពន្ធណាទាំងអស់ ។ ការមិនជឿលើទស្សនៈរបស់អ្នកប្រាជ្ញទាំងអស់ពុំមែនមានន័យថាគំនិតទាំងអស់នេះ ឬគំនិតទាំងអស់នោះវាខុសទេ តែបើទោះបីជាយ៉ាងណាក៏ដោយ ក៏យើងត្រូវប្រើខួរក្បាលគិតមុនសិនដែរ មុននឹងសម្រេចចិត្តទទួលយក ។ របៀបអានបែបនេះ ខ្ញុំដាក់ឈ្មោះថាជា "របៀបអានដែល

ចេះបន្សុទ្ធ ឬការអានប្រកបដោយការត្រិះរិះពិចារណាស៊ីជម្រៅ” ។ មុននឹងជឿ យើងត្រូវមើលមកខ្លួនឯងជាមុនសិន ។ យើងត្រូវគិតពិចារណាថា “តើវាមានប្រយោជន៍ដែរឬទេ? នេះមានន័យថា “អ្នកអានដែលពូកែ គឺជាអ្នកអានដែលចេះឆ្ងល់?” សូក្រាតនិយាយថា “ចម្ងល់គឺជាការចាប់ផ្ដើមកើតឡើងនូវគតិបណ្ឌិតឬបញ្ញាញាណ” ។ អ្នកពូកែឆ្លើយសំណួរពុំមែនជាបុគ្គលឆ្លាតទេ (ត្រឹមតែចងចាំ ហើយសូត្រតាម) តែអ្នកដែលពូកែសួរសំណួរទៅវិញទេ ទើបជាមនុស្សឆ្លាតពិតប្រាកដ ។ អ្នកដែលពូកែសួរ ចេះសួរ ចេះឆ្ងល់ គឺនឹងរស់នៅជាអមតៈ តែអ្នកដែលអស់ចម្ងល់ឈប់សួរនឹងរស់នៅត្រឹមតែរស់ ឬប្រៀបដូចជាមនុស្សស្លាប់អ៊ីចឹង ។ ពាក់ព័ន្ធនឹងសំណួរនេះ ខ្ញុំសង្កេតឃើញមានគំនិតអ្នកប្រាជ្ញខ្លះ គំនិតទស្សនវិទូខ្លះបានស្លាប់តាមម្ចាស់ ដោយសារតែ

មានត្រឹមតែចម្លើយ ឬចោទជាសំណួរសួរតិចតួចពេក ។

ទ្រឹស្តីអ្នកប្រាជ្ញដែលរស់បានយូរ គឺដោយសារតែមានសំណួរសួរច្រើនឥតដាច់ ។ យើងសាកគិតមើល តើព្រះពុទ្ធត្រាស់ដឹងដោយសារអ្វី? តើ អៃសាក់ ញូវតុន ដែលជាអ្នកប្រាជ្ញខាងរូបវិទ្យា អាចរកឃើញច្បាប់ទំនាញផែនដីដោយសារអ្វី? ហើយនិងអ្នកប្រាជ្ញ បុគ្គលត្រាស់ដឹងទាំងអស់បានក្លាយទៅជាអ្នកប្រាជ្ញដោយសារអ្វី? ចម្លើយគឺថា បុគ្គលទាំងនេះក្លាយទៅជាអ្នកប្រាជ្ញ និងក្លាយទៅជាបុគ្គលត្រាស់ដឹងដោយសារតែសំណួរ "ហេតុអ្វី ឬ Why" ។ បើគ្មានសំណួរហេតុអ្វីទេ ម្ល៉េះក៏គ្មានបុគ្គលអស្ចារ្យមកដល់ថ្ងៃនេះដែរ ។ ព្រះពុទ្ធឆ្ងល់ថា "ហេតុអ្វីមានមនុស្សចាស់ ហេតុអ្វីមានមនុស្សឈឺ ហេតុអ្វីមានមនុស្សស្លាប់?" អៃសាក់

ញូវតុន ដែលជាអ្នករកឃើញច្បាប់ទំនាញផែនដីឆ្លល់ថា "ហេតុអ្វីបានជាផ្លែប៉ោមធ្លាក់ចុះមកខាងក្រោម ចុះហេតុអ្វីវាមិនធ្លាក់ឡើងទៅខាងលើ?" ដោយសារតែចម្ងល់ដែលចេញពីសំណួរទាំងនេះ ទើបធ្វើឱ្យបុគ្គលទាំងនេះតាំងចិត្តស្វែងរកចម្លើយរហូតដល់ឃើញ ។ តួយ៉ាងព្រះពុទ្ធបានត្រាស់ដឹង ដឹងពីហេតុនៃទុក្ខ ដឹងហេតុនៃការកើតចាស់ឈឺស្លាប់ និងដឹងពីមាគ៌ារំលត់ទុក្ខ ។ អែសាក់ ញូវតុន បានក្លាយទៅជាអ្នកប្រាជ្ញដោយសារតែបានរកឃើញច្បាប់ទំនាញផែនដី ។ នេះហើយជាអំណាចនៃសំណួរ អំណាចនៃអ្នកចេះឆ្ងល់ និងបានព្យាយាមស្វែងរកសេចក្តីពិតដោយខ្លួនឯងតាមរយៈការពិចារណា ។ ចំពោះការអានក៏ដូចគ្នាដែរ ។ អ្នកអានដែលឆ្លាត គឺត្រូវតែជាអ្នកអានដែលចេះបន្សុទ្ធចំណេះដឹងគិតត្រិះរិះពិចារណាលើខ្លឹមសារ ដែលសៀវភៅសរសេរ ។

តើហេតុអ្វីត្រូវចេះបន្ស៊ុទ្ធ? នេះវាពាក់ព័ន្ធនឹងសៀវភៅដែលសរសេរឡើងមក គឺពុំសុទ្ធតែត្រឹមត្រូវទាំងអស់ឡើយ ។ មិនត្រឹមត្រូវ គឺដោយសារវាជាប់ទាក់ទងនឹងវប្បធម៌សង្គម របៀបរស់នៅរបស់សង្គម សង្គមវិជ្ជានៃប្រទេសមួយ និងផ្នត់គំនិតនៃអ្នកនិពន្ធ ។ អាមេរិក ពុំមែនជាខ្មែរទេ ហើយអង់គ្លេសក៏ពុំមែនជាខ្មែរដែរ... ។ យើងមានវប្បធម៌ខុសគ្នា របៀបរស់នៅខុសគ្នា និងផ្នត់គំនិតសង្គមខុសគ្នា ។ យើងជាអ្នកអាន យើងអានយកតែចំណុចល្អៗដែលអាចប្រើការកើតទៅបានហើយ ហើយជាថ្មីម្តងទៀត ចូរកុំប្រទ្បាថា "ឱ្យតែសៀវភៅសុទ្ធតែល្អទាំងអស់ឱ្យសោះ" ។

រាល់ថ្ងៃអ្នកនិពន្ធខ្មែរយើងខ្លះបានប្រែសម្រួលសៀវភៅបរទេសជាច្រើន ហើយមានសៀវភៅល្បីៗជាច្រើនលក់ដាច់

រាប់លានក្បាលទូទាំងពិភពលោក ។ ឧទាហរណ៍ដូចជា សៀវភៅរបស់ Stephen R. Covey, សៀវភៅរបស់ Robert T. Kiyosaki, សៀវភៅ Napoleon Hill, សៀវភៅរបស់ Dale Carnegie, និងសៀវភៅបរទេសល្បីៗជាច្រើនទៀត ដែលខ្មែរយើងកំពុងតែពេញនិយម ។ ចំពោះទស្សនៈខ្ញុំ និង បទពិសោធនៃការអានរបស់ខ្ញុំ ខ្ញុំយល់ថាអ្នកដទៃជាច្រើន យល់ថាសៀវភៅដែលខ្ញុំរៀបរាប់ខាងលើសុទ្ធតែជាសៀវភៅ ល្អឥតខ្ចោះ ។ ប៉ុន្តែខ្ញុំវិញ ខ្ញុំជឿថាគ្មានឡើយសៀវភៅដែល ល្អឥតទាស់ ។ វាអាចល្អមែន តែល្អសម្រាប់តែអ្នកអឺរ៉ុប ប៉ុណ្ណោះ ប៉ុន្តែមិនមែនល្អសម្រាប់ខ្មែរទេ ។ មូលហេតុ គឺរឿង វប្បធម៌សង្គម ។ ប្រទេសពីរមានវប្បធម៌ពីរ ។ ដូច្នេះ ដូចខ្ញុំ បានលើកឡើងខាងដើមអ៊ីចឹងថា ពាក់ព័ន្ធនឹងកត្តាវប្បធម៌ សង្គមមួយគត់ ។ បន្ទាប់មកទៀត គឺដំណាក់កាលទី៣ ដែល

ជាដំណាក់កាលក្រោយការអាន ។ ក្នុងកាលៈទេសៈខ្លះ យើងពុំចាំបាច់អានគ្រប់សៀវភៅនោះទេ  តែបើមានសៀវភៅណាមួយដែលយើងយល់ថាសក្តិសម និងត្រូវនឹងស្ថានភាពយើងហើយ យើងគួរតែអានសៀវភៅនោះដដែលៗ ។ ខ្ញុំធ្លាប់ឮពាក្យមួយថា "ពេលយើងអានសៀវភៅមួយចប់ហើយ សៀវភៅដែលយើងត្រូវអានបន្ត គឺសៀវភៅដែលយើងបានអានរួចហើយ" ។ សម្រាប់ខ្ញុំ សៀវភៅទាំងអស់និយាយតែរឿងមួយគត់គឺ "ប្រឹងប្រែង" ។ សរុបអត្ថន័យនៃសៀវភៅទាំងអស់ គឺនិយាយតែពាក្យប្រឹងប្រែង តែវិធីសាស្ត្រប្រឹងមានច្រើនរបៀប ។ ដូច្នេះត្រូវការសៀវភៅច្រើន ។ យើងជាអ្នកអានគួរចំណាយពេលវេលាគិត ពេលអានរួច ឬពេលកំពុងអាន ។ ការគិតដែលមានប្រយោជន៍និងទទួលលទ្ធផលល្អ គួរតែស្វែងរកកន្លែងដែលខ្យល់អាកាសស្ងប់ស្ងាត់ហើយ

អង្គុយសញ្ជឹងម្នាក់ឯង ។ការអានបែបនេះ វាជាការអានដែលបូកនឹងសមាធិ ។ សមាធិក្នុងការអាន គឺពុំមែនមានន័យថាអង្គុយពែនភ្នែន បិទភ្នែក ដកដង្ហើមចេញចូល ឬចេញក៏ដឹងចូលក៏ដឹងទេ តែវាគឺជាការគិតពិចារណាលើអ្វីដែលយើងបានអាន ហើយបំបែកទ្រឹស្តី ។ កុំគិតថាការគិតច្រើននាំឱ្យស្មុគស្មាញ តែមនុស្សដែលពុំចូលចិត្តគិតទៅវិញទេដែលវេទនានោះ ។ នេះគ្រាន់តែជាបទពិសោធខ្ញុំផ្ទាល់ប៉ុណ្ណោះ ហើយសូមពិចារណាតាមការគួរ ។ ខុសឬត្រូវ ចូរសាកល្បងសិន ។ បើខុស វាជាកំហុសស្នេរ ។

# ១០

## អានដោយការពិចារណា ជាងការខឹងសម្បារ

អត្ថបទទស្សនៈ និងគំនិតដែលមាននៅក្នុងសៀវភៅទស្សនៈខ្លះ វាគឺជាគំនិតដែលបងប្អូនអ្នកអានមិនគួរកំណត់ថា ត្រូវទាំងស្រុង ឬខុសទាំងស្រុងឡើយ ។ ប៉ុន្តែវាអាចត្រូវឬអាចខុស គឺអាស្រ័យទៅលើស្ថានភាពជាក់ស្តែង និងកាលៈទេសៈប៉ុណ្ណោះ ។ ទស្សនៈខ្លះ យើងអាចពិចារណាត្រឹមត្រូវតាមលក្ខណៈតក្កវិជ្ជា ឬសមហេតុផល ។ វិទស្សនៈខ្លះទៀត ចំណេះដឹងបែបតក្កវិជ្ជាមិនអាចយកមកពិចារណាឱ្យពាល់ផលបានឡើយ ដ្បិតទាល់តែអ្នកអានធ្លាប់ឆ្លងកាត់

នូវបទពិសោធជាក់ស្តែងផ្ទាល់ ទើបអាចពាល់ត្រូវ។

ខ្ញុំលើកទឹកចិត្តឱ្យបងប្អូនអានដោយការពិចារណាច្រើនជាងអានជាមួយនឹងការខឹងសម្បារ។ ទស្សនៈខ្លះវាជាទស្សនៈក្តៅ ដែលអាចធ្វើឱ្យអ្នកអានឈឺចាប់ ឬខឹងសម្បារ នៅពេលអានម្តងៗ។ ការឈឺចាប់និងការខឹងសម្បារនេះ វាលេចរូបរាងឡើងក្នុងលក្ខខណ្ឌដែលគំនិតខ្លះវាផ្ទុយនឹងការយល់ឃើញរបស់យើង ឬប្រឆាំងនឹងនិន្នាការសាសនា ឬទំនោរនយោបាយរបស់យើង។ បើទោះបីជាយើងមានគំនិតផ្ទុយ ឬមាននិន្នាការលើសាសនាណា ឬមានទំនោរនយោបាយលើបក្សណាក៏ដោយ តែសូមកុំប្រតិកម្មអារម្មណ៍ធ្វើឱ្យខ្លួនឯងរងទុក្ខនិងឈឺចាប់ឱ្យសោះ។ យើងគួររៀនធ្វើជាមនុស្សដែលចេះគ្រប់គ្រងទាំងការឈឺចាប់និង

សេចក្តីសប្បាយ ប្រៀបដូចបណ្ឌិតដែលពេញចិត្តពាក្យរិះគន់ស្មើនឹងសម្តីសរសើរ ។




ចំណេះដឹង វាងាយស្រួលរកសម្រាប់បុគ្គលដែលចេះប្រឹង ។ អ្នកចេះប្រឹងរៀន បើទោះបីជានៅទីណា ឬគ្មានឱកាសរៀនបែបណា ក៏មិនអរិជ្ជាដែរ ។

# ១១

## ត្រូវអានយកចេះ កុំអានយកចប់

“មនុស្សណាដែលបានចំណាយពេលវេលាអានច្រើន តែមិនចំណាយពេលគិតច្រើន នោះគឺបានប្រើត្រឹមតែភ្នែកប៉ុណ្ណោះ”។ មនុស្សប្រាកដប្រជា តែងអានយកចេះ អានយកយល់ និងអានដោយយកចិត្តទុកដាក់ តែមិនមែនអានយកចប់ទេ។ អានយកចប់ វាខុសគ្នាពីអានយកចេះ។ ការអានដែលមានប្រសិទ្ធភាពបំផុត គឺត្រូវអានដោយចំណាយពេលវេលាគិតពិចារណាបែបស៊ីជម្រៅឱ្យបានច្រើន។

មនុស្សណាដែលគិតហើយ តែមិនធ្វើ នោះគឺបានត្រឹមតែទ្រឹស្តីប៉ុណ្ណោះ ។ មនុស្សណាដែលធ្វើហើយ តែបរាជ័យ នោះគឺបានត្រឹមតែបទពិសោធប៉ុណ្ណោះ ។ បរាជ័យហើយ បរាជ័យទៀត តែមិនចុះចាញ់ នោះទើបហៅថា “មនុស្សជោគជ័យពិតប្រាកដ” ។

# ១៣

## ចេះអាន គឺត្រូវចេះបន្សុទ្ធ

វ៉ុលទែរ (Voltaire) ពោលថា “ពេលខ្ញុំអានកាន់តែច្រើន ខ្ញុំសញ្ជឹងគិតពិចារណាកាន់តែជ្រៅខ្លាំង ហើយពេលខ្ញុំសញ្ជឹងគិតពិចារណាកាន់តែជ្រៅខ្លាំង គឺខ្ញុំក៏កាន់តែទទួលស្គាល់ខ្លួនឯងកាន់តែច្បាស់ខ្លាំងដែរថាខ្ញុំមិនចេះអ្វីសោះ” ។

អ្នកដែលអានសៀវភៅច្រើនបំផុត ដោយមិនចំណាយ

ពេលគិតពិចារណា គឺមានកំហុសស្មើនឹងអ្នកគិតច្រើនដោយមិនបានអាន ។ មនុស្សដែលគិតច្រើនដោយគ្មានមូលដ្ឋានគោលការណ៍ តែងបង្កបញ្ហានិងមេរោគដល់ចិត្តគំនិតរបស់ខ្លួនឯងជានិច្ច ។មនុស្សដែលចេះអានពិតប្រាកដ គឺជាបុគ្គលដែលដឹងសៀវភៅត្រូវអាន និងចេះបន្សុទ្ធចំណេះចេញពីសៀវភៅ ហើយអាចបំលែងទ្រឹស្តីចេញទៅជាការអនុវត្តន៍ជាក់ស្តែង ។ អ្នកដែលចេះអាន គឺជាបុគ្គលដែលអានសៀវភៅយកគុណភាព តែមិនមែនយកបរិមាណឡើយ ។ ការអានសៀវភៅយកគុណភាព គឺមានន័យថាអានយកចេះ តែមិនមែនអានយកចប់ទេ ។ តើអ្នកជាអ្នកអានយកចេះ ឬអានយកចប់?

# ១៣

## មិនមែនគ្រាន់តែអាន

បុគ្គលដែលអានសៀវភៅ១០ក្បាល មិនស្មើនឹងបុគ្គលដែលអានសៀវភៅល្អមួយក្បាលបាន១០ដង ។ បុគ្គលដែលអានចំសៀវភៅមិនល្អមួយក្បាលរហូតដល់ ១០ដង គឺពុំប្រៀបស្មើនឹងបុគ្គលដែលមិនបានអាន (ទទួលចំណេះដឹងខុស) ។ នេះមានន័យថា "មិនមែនឱ្យតែសៀវភៅ គឺសុទ្ធតែល្អទាំងអស់នោះទេ" ។ ស្រដៀងគ្នា "មិនមែនឱ្យតែបានអានហើយ គឺសុទ្ធតែទទួលចំណេះដឹងត្រឹមត្រូវទាំងអស់

នោះដែរ” ។ អ្នកខ្លះតែងតែយល់ថា “អានច្រើន ចេះច្រើន កើនបញ្ញា” ។ ការយល់ឃើញបែបនេះ គឺត្រឹមត្រូវហើយ តែមិនត្រូវទាំងស្រុងឡើយ ។ តើលក្ខណៈបែបណាដែលគួរតែត្រឹមត្រូវ?

អាន គឺត្រូវតែអានហើយ តែត្រូវបន្ថែមខ្លឹមសារបន្តិចទៀតដោយថា “ត្រូវអានឱ្យត្រូវសៀវភៅល្អ និងអានសៀវភៅដែលល្អ ឬភាសាអង់គ្លេសថា *read the RIGHT BOOKS, not just ONLY READ*” ។ កាលណាបើចំណេះដឹងយើងមិនទាន់ពេញលេញ សៀវភៅខ្លះវាហាក់បីដូចជាផ្ដល់ការរីកចម្រើនយ៉ាងច្រើនដល់យើង ។ ប៉ុន្តែបើមែនទែនទៅការពិតសៀវភៅខ្លះ គឺបំពុលជីវិតយើង ។ ទស្សនៈដែលខ្ញុំតែងតែប្រើក្នុងការជូនជាគំនិតពិចារណាដល់អ្នកអានគឺ

"សៀវភៅល្អតែងព្យាបាលសង្គម តែសៀវភៅអាក្រក់ គឺបំពុលសង្គម។ សៀវភៅល្អ គឺជាឱសថប៉ូវ តែសៀវភៅអាក្រក់ គឺជាថ្នាំពុល"។ តើបំពុលសង្គមយ៉ាងដូចម្ដេច?

នៅក្នុងប្រវត្តិសាស្ត្រ តើរបបផ្ដាច់ការកើតចេញមកពីណា? ជាពិសេសជនផ្ដាច់ការ អាឌុល អ៊ីត្លែរ កើតចេញពីណា? បើពេលយើងក្រឡេកទៅមើលប្រវត្តិនៃការតែងនិពន្ធ ជាពិសេសក្រុមទស្សនវិទូបរទេស ដូចជា វិចទ័រ ហ៊ុយហ្គោ (Victor Hugo), សាំង អូហ្គូស្ដាំង (Saint Augustine) គឺស្ទើរតែគ្រប់សៀវភៅដែលនិយាយអំពីសង្គមវិជ្ជារបស់ សាំង អូហ្គូស្ដាំង ត្រូវបានអ្នកចេះដឹងខ្មែរសម័យមុនៗឱ្យតម្លៃខ្ពស់ និងចាត់ទុកអូហ្គូស្ដាំងជាបិតាសង្គមវិជ្ជាទៀតផង។ បើមើលទៅទស្សនវិទូបារាំង ហ្សង់ ហ្សាក់រ៉ូសូ (Jean-

Jacques Rousseau) ដែលសរសេរអំពី “កិច្ចសន្យាសង្គម ឬកុងត្រាសង្គម ឬ Social Contract” គឺល្អណាស់។ បើមើលទៅ វិចទ័រ ហ៊ុយហ្គូ, មើលទៅអូហ្គុស្តាំង គឺសុទ្ធតែល្អៗទាំងអស់។ រហូតដល់ក្រោយមកទើបមនុស្សដឹងថា “ក្រុមនេះហើយដែលបានកសាងមូលដ្ឋានទស្សនៈបង្កើតឱ្យមានពួកផ្តាច់ការនិយម”។ នេះគ្រាន់តែជាឧទាហរណ៍ខ្លះៗដែលនិយាយអំពីវិបត្តិនៃសំណេរប៉ុណ្ណោះ។

ដូចគ្នាផងដែរ មិនថាសំណេរកំណាព្យ ពាក្យចាប់ចួនណែងណង ផ្តោះផ្តងរណ្តំដួងចិត្ត សុទ្ធតែបង្ហាញពីព្រលឹងនៃស្នេរ ដែលសរសេរចេញតាមបែបលក្ខណៈទស្សនៈឱ្យអ្នកអានប្រៀបធៀប, ទស្សនៈឱ្យអ្នកអានឆ្លុះបញ្ចាំងពីតថភាពសង្គម, ទស្សនៈឱ្យអ្នកអានពិចារណា, ទស្សនៈ

ឱ្យអ្នកអានសំយោគគំនិតបែបអត្តនោម័ត, ស្មេរខ្លួនឯងជាអ្នកជ្រុលនិយម ឬស្ដាំនិយម ឬកណ្ដាលនិយម និងលើសពីនេះវាអាចកំណត់ទៀតថា "ស្មេរមានគំនិតទោរទន់ទៅខាងណា"។ តាមការយល់ឃើញរបស់ខ្ញុំ "សំណេរគ្រប់យ៉ាងគួរណាតែជាសំណេរបង្រួមមនុស្សបង្កើតសាមគ្គីស្រុះស្រួលមូលមតិរវាងជនសង្គមនិងជនសង្គម។ ដើម្បីឱ្យគិតដល់រឿងសាមគ្គីទៅបាន គឺលុះត្រាណាតែស្មេររកទស្សនៈត្រឹមត្រូវ (Unchanging Principles) ឃើញ។ ការរកត្រូវឃើញទៅបាន លុះត្រាណាតែដឹងថាខុសត្រូវនៅកន្លែងណា។ ការដឹងខុសដឹងត្រូវទៅបាន លុះត្រាណាតែស្មេរ គឺជាអ្នកសិក្សាស្រាវជ្រាវ មុជជាមួយនឹងគំនិតច្រើនប្រភព គិតពិចារណាឱ្យស្របទៅនឹងបរិបទសង្គមវិជ្ជា និងហេតុការណ៍ជាក់ស្ដែងរបស់សង្គម"។

អត្ថបទនេះពុំសូវពីរោះស្តាប់ទេ តែទុកគ្រាន់តែជម្រើសសម្រាប់ពិចារណាប៉ុណ្ណោះ ។ បើខុស គឺស្មេរជាអ្នកខុស តែបើត្រូវ គឺរៀនសូត្រទាំងអស់គ្នា ។




បើចង់បំផ្លាញវប្បធម៌នៃសង្គមមួយ អ្នកពុំចាំបាច់ដុតកម្ទេចសៀវភៅចោលឱ្យអស់ទេ ប៉ុន្តែគ្រាន់តែធ្វើឱ្យមនុស្សក្នុងសង្គមនោះលែងចង់អានសៀវភៅ គឺវាគ្រប់គ្រាន់ដើម្បីបំផ្លាញប្រទេសមួយទៅហើយ ។

# ១៤

## អំណាន និងសមាធិ

គ្រូសមាធិឥណ្ឌាក្នុងយុគទំនើបនិយាយថា "អានតិច តែត្រូវសមាធិឱ្យបានច្រើន និងត្រូវសញ្ជឹងគិតដល់ព្រះជាម្ចាស់គ្រប់ពេលវេលា" ។

ឃ្លាខាងលើគឺចង់មានន័យថា "ការអានត្រូវតិចជាងការសមាធិ" ។ សមាធិមានន័យថា "សញ្ជឹងគិត" ពីរចនាសម្ពន្ធចិត្តនិងកាយក្នុងខ្លួន ដោយឈ្វេងយល់ពីស្ថានភាពដោយឡែកក្នុងខ្លួន និងទំនាក់ទំនងរវាងអត្តិភាពរបស់ខ្លួន និងធម្មជាតិក្នុងចក្រវាល ។ "គិតដល់ព្រះជាម្ចាស់

គ្រប់ពេលវេលា” គឺមានន័យថាត្រូវមានសតិដឹងខ្លួនជានិច្ច ពីព្រោះព្រះជាម្ចាស់គឺស្ថិតនៅក្នុងខ្លួនមនុស្ស ។ ឧទាហរណ៍ បើខឹង ត្រូវតែដឹងថាខឹង បើសប្បាយ ត្រឹមតែដឹងថាសប្បាយ បើទុក្ខ ដឹងត្រឹមថាជាទុក្ខ ។ សតិដឹងបែបនេះ វាធ្វើឱ្យមនុស្ស គ្មានការសោយនូវអារម្មណ៍ ។ នៅពេលដែលគ្មានការសោយ នូវអារម្មណ៍ ចិត្តនេះឈានដល់កម្រិតចិត្តសន្តិភាព ឬចិត្ត និព្វានក្នុងខ្លួនមនុស្ស ឬមានថាមពលពាល់ត្រូវធាតុព្រះក្នុង ខ្លួន ។ គិតដល់ព្រះ គឺសញ្ជឹងគិតពីព្រះរហូតស្គាល់ព្រះ ឬគិត ពីខ្លួនឯងរហូតដល់ស្គាល់ខ្លួនឯងពិតប្រាកដ ។

ការអានសៀវភៅបានច្រើន គឺល្អបានត្រឹមតែពាក់ កណ្ដាលប៉ុណ្ណោះ ។ ពាក់កណ្ដាលទៀតនៃភាពល្អអំពីការ អាន គឺត្រូវប្រើការគិតឱ្យបានច្រើន ។ លើសពីល្អ គឺត្រូវ

អានត្រូវសៀវភៅល្អ ពីព្រោះមិនមែនឱ្យតែសៀវភៅ វាសុទ្ធតែល្អទាំងអស់នោះទេ ។ សៀវភៅល្អព្យាបាលសង្គម តែសៀវភៅអាក្រក់គឺបំពុលសង្គម ។ នេះជាបញ្ហាកង្វល់ដែលអ្នកសរសេរនិងអ្នកនិពន្ធ ត្រូវគិតគូរប្រុងប្រយ័ត្នចំពោះសំណេររបស់ខ្លួន ។ អក្សរមួយឃ្លា និងសម្ដីមួយម៉ាត់ គឺជាអ្នកឆ្លាក់ខួរក្បាលមនុស្ស ។

# ១៥

## ការអានទ្រឹស្តី និងការធ្វើជាក់ស្តែង

អាហារល្អៗមានតួនាទីធ្វើឱ្យរូបរាងកាយលូតលាស់ធំធាត់ ។ គំនិតល្អៗ វានឹងធ្វើឱ្យជីវិតយើងស្រស់បំព្រង ។ ពាក្យខ្មែរលោកពោលថា "ស្រឡាញ់ខ្លួន ត្រូវស្ងួនចំណី បើស្រឡាញ់ស្រី ត្រូវស្ងួនចិត្ត ។ ចង់បានស្នូគិ តោងកាន់សុចរិត ចង់សម្បូណ៌មិត្រ ត្រូវរកទ្រព្យ" ។ មនុស្សដែលចេះស្រឡាញ់ខ្លួន គឺចេះប្រឹងប្រែងធ្វើឱ្យខ្លួនឯងរីកចម្រើន ។ ការរស់នៅប្រឹងប្រែងអភិវឌ្ឍខ្លួនឯងឱ្យរីកចម្រើន គឺស្មើនឹងការឱ្យតម្លៃលើខ្លួនឯង ។ មនុស្សដែលមិនចេះឱ្យតម្លៃចំពោះខ្លួន

ឯង គឺចូលចិត្តរស់នៅគ្មានវិន័យ បណ្តែតបណ្តោយវាសនាតាមយថាកម្មរស់នៅត្រឹមធ្វើជាជនរងគ្រោះនៃពិភពលោក ។

ព្រះចន្ទមានមានពន្លឺពេលរាត្រី  រីឯសុរិយាមាននាទីជះពន្លឺពេលថ្ងៃ ។ អាហារដែលមនុស្សញុំា វាមានតួនាទីទៅបំប៉នរាងកាយតាមផ្នែកនីមួយ ៗ ស្របទៅតាមតួនាទីរបស់ខ្លួន ។ រីឯចំណេះដឹងដែលយើងមាន ក្រោយពីបានសិក្សារៀនសូត្រ ជាពិសេសបានមកពីការអានសៀវភៅ ក៏មានតួនាទីធ្វើការទៅតាមផ្នែករៀង ៗ ខ្លួនដែរ ។ ចំណេះដឹងដែលបានមកពីអំណានខ្លះ គឺយើងមិនអាចប្រើពេលនេះបានទេ តែអាចប្រើបាននៅពេលក្រោយ ។ បើកាលៈទេសៈមិនទាន់មកដល់ ចំណេះដឹងដែលបានមកពីអំណានខ្លះ គឺមើលទៅប្រៀបដូចជាឥតបានការណ៍ តែដល់ពេលណាបញ្ហាមកដល់

ទើបយើងអាចអនុវត្តកើត ។ គំនិតដែលត្រឹមត្រូវ និងអាចអនុវត្តទៅបាន គឺត្រូវទម្លាក់លក្ខខណ្ឌចូល ។ រីគំនិតខ្លះ វាត្រឹមត្រូវដែរ តែត្រឹមត្រូវក្នុងខ្លឹមសារគំនិតនិយមប៉ុណ្ណោះ ។

ឧទាហរណ៍ជាក់ស្តែង ទស្សនៈអ្នកខ្លះយល់ថា "ជីវិតដែលប្រឹងប្រែង គឺជឹងតែជោគជ័យ" តែខ្ញុំសុំទម្លាក់លក្ខខណ្ឌចូលដោយនិយាយវិញថា "ប្រឹង គឺត្រូវតែប្រឹងហើយ តែត្រូវប្រឹងឱ្យត្រូវផ្លូវផង ដ្បិតបើប្រឹងខុស វាមិនខុសពីត្រីដែលហែលនៅលើគោក ឬមិនខុសពីបក្សីជ្រមុជក្នុងទឹកទេ" ។ អ្នកខ្លះយល់ថា "ចំណេះដឹង គឺជាអំណាច" តែខ្ញុំសុំទម្លាក់លក្ខខណ្ឌចូលដោយថា "ចំណេះដឹងនឹងក្លាយជាអំណាចទៅបាន លុះត្រាតែយើងយកចំណេះដឹង ទៅធ្វើសកម្មភាពជាក់ស្តែង ។ បើយើងមានចំណេះដឹង តែមិនព្រមអនុវត្ត

តើមានអ្វីខុសគ្នារវាងអ្នកចេះអានអក្សរ តែមិនព្រមអាន និង អ្នកមិនចេះអានអក្សរ?” អ្នកខ្លះយល់ទៀតថា “ចំណេះដឹង ឱ្យតែបានយកទៅអនុវត្តហើយ គឺដឹងតែល្អហើយ” តែខ្ញុំ សូមទម្លាក់លក្ខខណ្ឌថែមទៀតថា “តើវាមានប្រយោជន៍ អ្វី ដែលអនុវត្តន៍ហើយ តែមិនបានផល? ការយកចំណេះ ដឹងទៅអនុវត្ត គឺត្រូវអនុវត្តហើយ ទទួលបានផលល្អ តែបើ ទទួលបានផលអាក្រក់វិញ តើខុសគ្នាអ្វីពីការមិនអនុវត្តន៍?”

នេះគឺមានន័យថា “ចំណេះដឹងវាគឺជាអំណាចទៅបាន លុះត្រាណាតែយើងយកទៅអនុវត្តជាក់ស្តែង ឱ្យកើតជាផល ល្អ មានប្រសិទ្ធភាព”។ នេះហើយដែលហៅថា “ទម្លាក់ លក្ខខណ្ឌឱ្យត្រូវ ទើបដឹងថាអ្វីៗគ្មានខុសនិងត្រូវទេ តែ សំខាន់គឺស្ថានភាពចាំបាច់ជាក់ស្តែង”។ ត្រឡប់មកការអាន

វិញ ក៏វាមានន័យអ៊ីចឹងដូចគ្នាដែរ ។ អ្នកខ្លះមានទស្សនៈថា "អានហើយមិនធ្វើ គឺស្មើនឹងកាំបិតក្នុងស្រោម" ។ ប៉ុន្តែខ្ញុំយល់ថា "ចំណេះដឹងខ្លះ មិនអាចយកមកប្រើបានគ្រប់ពេលទេ ដ្បិតការមានចំណេះដឹងចេញពីអំណាន គឺវាគ្រាន់តែទុកសម្រាប់ឱ្យយើងបង្ការបញ្ហាប៉ុណ្ណោះ ។ ពេលណាបញ្ហាមកដល់ គឺចំណេះដឹងនឹងត្រូវប្រើ ប្រៀបដូចជាភាពងងឹតមកដល់ ព្រះចន្ទក៏រះមកឱ្យយើងឃើញផងដែរ" ។

ជីវិត គឺជាការរៀនសូត្រពេញមួយជីវិត តែមិនប្រាកដថា អ្វីៗដែលយើងរៀនអាចយកប្រើបានទាំងអស់ទេ ។ មនុស្សខ្លាំងចាប់កំណើតចេញពីបញ្ហា ។ អ្នកដែលមនុស្សទូទៅហៅថាសេដ្ឋី គឺកើតពីការលំបាកនិងការប្រឹងប្រែងពីបាតដៃទទេ ។ អ្នកអាន គឺត្រូវយកចំណេះដឹងមកសាបព្រោះ

តាមរយៈការធ្វើជាគំរូដល់មនុស្សដទៃ ឬដល់អ្នកជំនាន់ក្រោយ ។ អ្នកអានត្រូវយកចំណេះដឹងមកដុសខាត់ខ្លួនឯងឱ្យក្លាយទៅជាមនុស្សពេញលេញ ។ អ្នកអានពុំចាំបាច់ធ្វើអ្វីច្រើនក៏បានដែរ តែសំខាន់ត្រូវរស់នៅក្នុងនាមជាមនុស្សមានសីលធម៌ មានមេត្តាធម៌ ចេះយកចំណេះរកសេចក្ដីសុខឱ្យខ្លួនដោយវិធីសុចរិត ក៏ល្មមចាត់ទុកថាបានអនុវត្តចំណេះពីអំណានទៅហើយ ។

# ១៦

## គ្រូបង្រៀនអានសៀវភៅ

សង្គមល្អ អ្នកចេះដឹងអាចរស់នៅស្រួលបាន តែបើសង្គមមិនស្រួលវិញ គឺអ្នកចេះដឹងរស់នៅធ្វើល្អ ធ្វើរឿងត្រឹមត្រូវ ធ្វើរឿងគុណធម៌ដោយលំបាក ។ ការធ្វើសេចក្តីល្អគឺពុំមែនជារឿងងាយស្រួលទេ ឬពេលខ្លះត្រូវបានមនុស្សមិនល្អចោទយើងថាឆ្កួតផងក៏មាន ។ ការកសាងសង្គមគឺត្រូវពឹងទៅលើអ្នកចេះដឹង ជាពិសេសគ្រូបង្រៀន ។ គ្រូគឺជាបុគ្គលគំរូដែលត្រូវចាប់ផ្តើមធ្វើអ្វីៗដែលល្អមុនអ្នកណាៗទាំងអស់ ។ ប្រជាជនខ្មែរខ្លះ មិនសូវចូលចិត្តអាន

សៀវភៅទេ ប៉ុន្តែអ្វីៗ វាបានកើតជាទម្លាប់ ហើយទម្លាប់បានក្លាយទៅជាវប្បធម៌ទៅហើយ ។ ដូច្នេះ មានតែអ្នកជំនាន់ថ្មីទេដែលត្រូវតែជាអ្នកចាប់ផ្ដើមទម្លាប់ដ៏ត្រឹមត្រូវ ដ៏ល្អបំផុតជាពិសេសទម្លាប់នៃការអានសៀវភៅនេះ ។ ចូរឈប់សួរទៅថាហេតុអ្វីកូនខ្ញុំ ឬសិស្សខ្ញុំ មិនចូលចិត្តអានសៀវភៅ ។

ម្ដាយឪពុកដែលស្រឡាញ់កូន គឺត្រូវជំរុញកូនឱ្យខិតខំប្រឹងប្រែងរៀនសូត្រ ជាពិសេសគឺការអានសៀវភៅ ។ ការស្រឡាញ់កូន ការស្រឡាញ់សិស្ស គឺមិនមែនចេះតែស្រឡាញ់ទេ តែត្រូវស្រឡាញ់ឱ្យត្រូវផ្លូវ និងត្រូវរបៀប ឬមិនថាការស្រឡាញ់ខ្លួនឯងទេ ដ្បិតបើស្រឡាញ់ខ្លួនឯងដោយគ្មានវិន័យ ឬធូររលុងពេកចំពោះខ្លួនឯង គឺជាកម្មធំហើយ ។ បើចង់ឱ្យកូនអានសៀវភៅ ម្ដាយឪពុកត្រូវតែជាអ្នកចាប់ផ្ដើម

អានមុន ។ អ្វី ៗ ត្រូវចាប់ផ្ដើមពីគំរូភាព តែមិនមែនរស់នៅយករួចខ្លួនទេ ។ សុភាសិតខ្មែរពោលថា “ពុតគ្រូកុំគ្រាប់ច្បាប់គ្រូឱ្យយក” ។ កិរិយាបាំងទោសខ្លួនឯងរបស់អ្នកខ្លះ គួរពុំមានទៀតឡើយ ដ្បិតវាជះឥទ្ធិពលមិនល្អដល់សង្គមទេ ។

ទ្រឹស្ដីពុទ្ធនិយមតែងតែបង្រៀនឱ្យបុគ្គលប្រដៅខ្លួនឯង និងធ្វើខ្លួនឯងឱ្យបានល្អជាមុនសិន សឹមទៅប្រដៅអ្នកដទៃ ។ ទ្រឹស្ដីបរមគ្រូចិន ខុងជឺ បានបង្រៀនឱ្យមនុស្សធ្វើជាគំរូដ៏ល្អដល់មនុស្សដទៃ ហើយធ្វើអ្វី ៗ ឱ្យត្រឹមត្រូវ សឹមទៅប្រាប់អ្នកផ្សេងឱ្យធ្វើរឿងត្រឹមត្រូវតាមដែរ ។ អ្នកខ្លះប្រាប់អ្នកដទៃឱ្យធ្វើរឿងត្រឹមត្រូវប្រឹងប្រែងរៀនសូត្រ សង្វាតអានសៀវភៅ ស្របពេលដែលខ្លួនឯងមិនខ្វល់នឹងការរៀនសូត្រ និងមិនគិតប្រឹងអាន ។ ការរស់នៅបែបនេះ គឺជាជីវិតដែលរស់នៅ

ចាញ់ខ្លួនឯងនិងបម្រើតណ្ហាខ្លួនឯងហើយ តែបែរជាចង់ឱ្យអ្នកដទៃគោរព ។ ខ្ញុំមិនដឹងថាត្រូវនិយាយបែបណាទេ តែគ្រាន់ជាជូនជាគតិថា "គ្រូបង្រៀនមានតួនាទីជាអ្នកអានសៀវភៅមុនសិស្ស ។ ពេលណាគ្រូបានអានសៀវភៅមុនសិស្ស គឺគ្រូនឹងមានគំនិតល្អៗបណ្ដុះស្មារតីដល់សិស្សផងដែរ" ។ គ្រូម្នាក់មានសិស្ស ៥០នាក់ ហើយគ្រូម្នាក់ជាអ្នកអាន គឺពិតជាមានឥទ្ធិពលធំណាស់ចំពោះសិស្សរបស់ខ្លួន ។ ក្នុងនាមជាមនុស្សម្នាក់ដែលមានតម្លៃ បើស្រឡាញ់ខ្លួនឯង កុំភ្លេចសៀវភៅ ។ ក្នុងនាមជាសមាជិកគ្រួសារម្នាក់ បើស្រឡាញ់គ្រួសារ កុំភ្លេចសៀវភៅ ។ បើស្រឡាញ់សង្គមជាតិដែលខ្លួនកំពុងរស់នៅ កុំភ្លេចសៀវភៅ ។



អ្នករៀន ប្រើពេលវេលានៃថ្ងៃសម្រាកដើម្បីរៀន តែអ្នកមិនរៀនវិញ ប្រើពេលវេលានៃថ្ងៃសម្រាកដើម្បីដើរលេង ។

# ១៧

## ខឹងគោវាយរទេះ

ខ្ញុំបានឃើញសៀវភៅល្អៗជាច្រើន ពេលដើរចូលបណ្ណាគារ ។ សៀវភៅល្អ តែមនុស្សមិនអាន ។ មនុស្សបានអាន តែអានមិនយល់ ។ មនុស្សខ្លះអានយល់ តែធ្វើមិនកើត ។ ពេលធ្វើមិនកើតក៏ប្រឹងទៅបន្ទោសទ្រឹស្តី ។ យើងត្រូវត្រឡប់មកផ្ចុះបញ្ចាំងមើលខ្លួនឯងឡើងវិញទាំងអស់ ទើបយើងអាចគេចផុតពីរឿងអវិជ្ជមានខ្លះបាន ។

ខ្ញុំលង់ក្នុងសមាធិជាប្រក្រតី មានចំណេះដឹងផ្នែកសាសនាខ្លះ ល្មមអាចយល់ខ្លះពីធម្មជាតិមនុស្ស ប្រឹងវិភាគ

ទ្រឹស្តី រវែកញែកគំនិត គិតឃើញរឿងថ្មីៗ តែដល់យល់មែនទែន អ្វីក៏ខ្ញុំលែងបន្ទោសដែរ ។ បើយើងចង់ខ្លាំង ត្រូវប្រឹងរហូត ។ បើយើងចង់ខ្លាំង កុំប្រឹងលេងៗ ។ ស្រឡាញ់សង្គម ត្រូវប្រឹងរៀន ។ បើមានចំណេះត្រូវប្រលេះចែកគ្នា ។

មុនគេង ខ្ញុំធ្វើរឿងពីរសំខាន់ៗ៖ ទី១ សមាធិ និង ទី២ គឺសន្ទនាជាមួយខ្លួនឯង សួរខ្លួនឯង និងពិចារណាលើទង្វើខ្លួនឯង ។ ហេតុអ្វីខ្ញុំធ្វើបែបនេះ? ការពិត ខ្ញុំខ្លាចខ្លួនឯងខុសដោយឥតដឹងខ្លួន វង្វេងដោយឥតដឹងសតិ ។ ខ្ញុំអានសៀវភៅមែន គិតរវែកញែកមែន តែត្រូវការសមាធិជាធាតុអាស្រ័យជ្រោមជ្រែង ទប់ចិត្ត ដ្បិតបើមិនអ៊ីចឹងទេ ចិត្តខ្ញុំនឹងមានមានះ ហើយចិត្តខ្ញុំនឹងមានតែអញ ។ ខ្មៅសល្អអាក្រក់នៅលើចិត្ត គំនិតប្រើមិនកើត ពេលចិត្តវង្វេង ។

ត្រឡប់មកវិញ សូមកុំធ្វើជាខ្ញុំកញ្ជះនៃគំនិតអ្នកនិពន្ធណាម្នាក់ឱ្យសោះ ជាពិសេសក្នុងរឿងសង្គម ។ ចេះមើល បើឃើញជំពាក់ហើយ គឺត្រូវជួយស្រាយ ។ យើងត្រូវការមនុស្សសន្តិភាព ចេះកសាងស្មារតីសាមគ្គី ប្រកៀកស្មារួមគ្នាធ្វើ និងគិតសង្គម ។ ពេលវេលាខ្លីពេក គឺខ្លីយកតែមែនទែន ។

# ១៨

## ជំនាញគិតសំខាន់ជាងជំនាញជឿ

"ការអានអាចនាំយើងទៅមើលគ្រប់កន្លែង ហើយការមានឱកាសបានទៅដល់គ្រប់ទីកន្លែង ក៏នាំឱ្យយើងទទួលបានចំណេះដឹងដូចការអានដែរ" ។

អ្នកអានយកចេះ គឺជាអ្នកអានដែលចេះគិតពិចារណា តែអ្នកអានយកចប់ គឺអានដោយគ្មានយល់ពីខ្លឹមសារនៃសំណេរ ។ អ្នកណាដែលអានច្រើនបំផុតតែបែរជាប្រើប្រាស់ខួរក្បាលគិតតិចតួចបំផុត គឺនឹងធ្លាក់ចូលទៅក្នុងទម្លាប់នៃការខ្ជិលគិត ។ មនុស្សដែលខ្ជិលគិត គឺនឹងក្លាយទៅជា

ទាសករនៃគំនិតរបស់អ្នកនិពន្ធ ។ ដូច្នេះ ជំនាញក្នុងការ គិតពិចារណា គឺសំខាន់ជាងជំនាញក្នុងការជឿ ។

គិតដោយគ្មានការរៀន គឺនឹងនាំឱ្យវង្វេងដោយគ្មាន គោលការណ៍ ហើយបើរៀនដោយគ្មានការគិតពិចារណា នឹងចាំតែជឿស៊ប់ដោយងងឹតងងុល ។ ការអាន និងការ ធ្វើដំណើរ ពេលខ្លះមានលក្ខណៈខុសគ្នាខ្លះ ។ ការអាន គឺ ត្រូវប្រើពេលវេលាជាមួយខ្លួនឯងនៅកន្លែងស្ងប់ស្ងាត់ តែ ការធ្វើដំណើរ គឺត្រូវប្រើពេលវេលាជាមួយកត្តាខាងក្រៅ ច្រើនជាង ។ អ្នករៀន បើទៅដល់ទីណាក៏នៅតែរៀន តែ អ្នកមិនរៀន បើទោះបីជាអង្គុយអានសៀវភៅពេញមួយថ្ងៃ ក៏អានដោយមិនគិតឬអានយកតែចប់ប៉ុណ្ណោះ ។

អ្នកខ្លះ រៀនក្នុងក្លឹបកម្សាន្ត ឬអ្នកខ្លះរៀននៅវង្គសាល

ឬអ្នកខ្លះ បើទៅដល់ទីណា គឺរៀនទីនោះ ។ តើរៀនយ៉ាងដូចម្តេច? អ្នករៀន កាន់តែសំណួរ "ហេតុអ្វី" តាមខ្លួនតែម្យ៉ាង គឺនឹងរៀនបានគ្រប់យ៉ាងពីមជ្ឈដ្ឋានជុំវិញខ្លួន ។ តើហេតុអ្វីសំណួរ "ហេតុអ្វី" សំខាន់សម្រាប់អ្នករៀន? សំណួរ "ហេតុអ្វី" ធ្វើឱ្យព្រះពុទ្ធត្រាស់ដឹង ។ សំណួរ "ហេតុអ្វី" ធ្វើឱ្យសូក្រាត ប្លាតុង ខុងជឺ ឡៅជឺ... ។ល ។ បានក្លាយទៅជាទស្សនវិទូ ។ សំណួរ "ហេតុអ្វី" ធ្វើឱ្យពិភពលោកផ្លាស់ប្តូរពីយុគសម័យមួយទៅកាន់យុគសម័យល្អប្រសើរមួយទៀត ។

# ១៩

## ទាសករគំនិត

“យើងចំណាយពេលវេលាអានសៀវភៅដូចគ្នា និងចំនួនក្បាលសៀវភៅដូចគ្នា តែការជ្រួតជ្រាបទទួលបានចំណេះដឹងពីសៀវភៅ គឺវាពុំដូចគ្នាឡើយ”។ អ្នកអានខ្លះ មានសមត្ថភាពពិចារណាខ្ពស់ជាងអ្នកនិពន្ធ។ គំនិតអ្នកនិពន្ធខ្លះ ជាគំនិតសាមញ្ញ តែបើកម្រិតសមត្ថភាពនៃអ្នកអានខ្ពស់ វានឹងធ្វើឱ្យគំនិតសាមញ្ញផ្គុំសាច់ផ្គុំឈាមក្លាយទៅជាគំនិតអស្ចារ្យ។ ដូច្នេះហើយ បានជាយើងជាអ្នកអាន ត្រូវតែកុំជាប់ក្រឡាជាមួយគំនិតអ្នកនិពន្ធណាឱ្យ

សោះ ដ្បិតបើងាប់ក្រឡា គឺស្មើនឹងងាប់បញ្ញា ហើយបើងាប់បញ្ញា គឺស្មើនឹងក្លាយទៅជាកញ្ជះនៃគំនិតអ្នកនិពន្ធ ។ អ្នកខ្សត់នូវការពិចារណា ច្រើនតែធ្លាក់ខ្លួនក្នុងទាសភាពនៃគំនិត ។ ឥរិយាបថបែបនេះ វាពុំធ្វើឱ្យយើងរីកចម្រើនឡើយ ។

# ២០

## ចេះត្រឹមតែចាំ និងចេះគិតពិចារណា

“គុណភាពនៃជីវិតរបស់យើង វាអាស្រ័យទៅអ្វីដែលយើងគិត តែវាពុំមែនស្ថិតនៅលើអ្វីដែលយើងចងចាំនោះទេ” ។

ថ្វីដ្បិតតែការមានព័ត៌មានក្នុងខួរក្បាលច្រើន វាជាផ្នែកមួយដែលនាំឱ្យយើងអាចទាញយកមកធ្វើការវិភាគមែនតែការចេះគិតពិចារណានិងរបៀបនៃការគិតពិចារណា វាសំខាន់ជាងទិន្នន័យដែលយើងមានក្នុងខួរក្បាលទៅទៀត ។ មានខួរក្បាលដែលចេះគិតពិចារណា វាប្រសើរជាងខួរក្បាល

ដែលមានត្រឹមតែចំណេះដឹងឬព័ត៌មាន ។ អ្នកខ្លះ ចាំទិន្នន័យបានច្រើន ហើយក៏ចេះតែសូត្រតាម គឺសូត្ររហូតដល់បែកពពុះមាត់ក៏មាន ។ (តើនរណាខ្លះធ្លាប់មើលរឿង “3 Idiots” ? តើចាំបានឈុតឆាកមួយ ដែលនិស្សិតម្នាក់ឡើងសូត្រចំណាប់អារម្មណ៍ ដែលនាំឱ្យសាកលវិទ្យាធិការខ្មាសទាំងរដ្ឋមន្ត្រី និងនិស្សិតចូលរួមដទៃទៀតទេ ?)

យុគសម័យពីមុន មនុស្សជាតិប្រកួតប្រជែងលើព័ត៌មាន ។ យុគសម័យបន្ទាប់មនុស្សជាតិប្រកួតប្រជែងលើចំណេះដឹង ។ យុគសម័យថ្មីនេះ មនុស្សជាតិប្រកួតប្រជែងលើការច្នៃប្រតិដ្ឋ ។ គំនិតដែលងាប់ក្រឡា គឺជាគំនិតហួសសម័យឥតបានការណ៍ ។ មនុស្សឆ្លាតពុំមែនជាបុគ្គលដែលមានខួរក្បាលពូកែចាំទិន្នន័យគ្រប់យ៉ាងទេ តែជាមនុស្ស

ដែលដឹងថាតើត្រូវទៅរកទិន្នន័យទាំងអស់នោះនៅឯណា? អង្គចងចាំនៃប្រព័ន្ធបច្ចេកវិទ្យា (Memory) មានតួនាទីជាអ្នកផ្ទុកទិន្នន័យ ហើយខួរក្បាលមនុស្សមានតួនាទីជាអ្នកគិតរិះរកអ្វីដែលថ្មីៗ ។ មនុស្សឆ្លាតពិតប្រាកដ គឺជាបុគ្គលដែលពូកែសួរ តែពុំមែនមនុស្សពូកែឆ្លើយទេ ។ យុគសម័យនេះ គឺជាសម័យនៃការច្នៃប្រតិដ្ឋថ្មី តែពុំមែនជាយុគសម័យដែលប្រកួតប្រជែងលើព័ត៌មាន ឬចំណេះដឹងទៀតឡើយ ។

ការចេះគិតត្រិះរិះពិចារណា ធ្វើឱ្យយើងខុសពីសត្វ ។ ការរស់នៅរបស់សត្វភាគច្រើន ប្រើតែសភាវគតិប៉ុណ្ណោះ ។ បើទោះបីជាយើងរៀនជំនាញអ្វីក៏ដោយ ឱ្យតែពូកែគិត វានឹងធ្វើឱ្យយើងក្លាយទៅជាមនុស្សឆ្នើម ។ អ្នករៀនទស្សនវិជ្ជានៅតែជាអ្នករៀនទស្សនវិជ្ជា បើយើងនៅតែមិនរៀនវែកញែក

គំនិតរបស់ទស្សនវិទូ និងរៀនផ្ទះបញ្ចាំងគំនិតទាំងនោះជាមួយនឹងស្ថានភាពសង្គមដែលខ្លួនរស់នៅទេ ។ គំនិតចាស់ បូកគំនិតថ្មី ស្មើនឹងគំនិតច្នៃប្រតិដ្ឋ ។ គំនិតចាស់ថ្មីទាំងអស់ បូកនឹងកាលៈទេសៈសង្គមជាក់ស្តែង វានឹងបង្ហាញយើងថា តើយើងត្រូវអភិរក្សត្រង់ណា និងអភិវឌ្ឍត្រង់ណា?

បដិវត្តន៍ក្នុងពិភពលោកទាំងអស់ សុទ្ធតែកើតចេញពីក្រុមមេគំនិតធំៗ ឬយើងហៅថា "ទស្សនវិទូ" ។ ទស្សនវិជ្ជា គឺជាហេតុធ្វើឱ្យសង្គមមានបដិវត្តន៍ ដ្បិតមនុស្សរស់ក្នុងសង្គមតែងនៅចង់បានជីវិតដែលល្អប្រសើរជាងមុន ។ ឧទាហរណ៍ជាក់ស្តែង. តើទស្សនវិទូរូបណាដែលធ្វើឱ្យមានបដិវត្តន៍របបរាជានិយម? តើទស្សនវិទូរូបណាដែលបង្កើតរបៀបដឹកនាំរដ្ឋ និងផ្លាស់របៀបដឹកនាំចាស់?

ដូច្នេះ កុំឆ្ងល់ថាហេតុអ្វីសង្គមខ្លះ មេដឹកនាំខ្លះ ហាមឃាត់មិនឱ្យមានការសិក្សាទស្សនវិជ្ជាឱ្យស៊ីជម្រៅ ដល់ប្រជាជនឬយុវជន? មនុស្សដែលមិនហ៊ានគិតនូវអ្វីដែលខ្លួនចង់គិត គឺជាទាសករ ឬជាមនុស្សកំសាក ។ ក្នុងចំណោមទស្សនវិទូទាំងអស់ ខ្ញុំសរសើរសូក្រាត ដ្បិតលោកនិយាយថា "ម្តាយខ្ញុំគឺជាឆ្មបបង្កើតកូន រីឯខ្ញុំជាឆ្មបបង្កើតគំនិត" ។



បើស្រឡាញ់សង្គមពិត គឺត្រូវគិតរឿងប្រឹងអាន ប្រឹងរៀន ។ ស្រឡាញ់អ្វីក៏ដោយ មិនថាស្រឡាញ់ស្រី ឬស្រឡាញ់ប្រុស ឬស្រឡាញ់ឪពុកម្ដាយទេ គឺត្រូវស្រឡាញ់ដោយទង្វើ តែមិនមែនស្រឡាញ់ត្រឹមតែសម្ដីឡើយ ។

# ២១

## បើនាងចេះអាន

នាងសួរខ្ញុំថា “តើធ្វើយ៉ាងណា ទើបដឹងថាមនុស្សប្រុសស្រឡាញ់យើងស្មោះឬមិនស្មោះ?” ខ្ញុំតបថា “ខ្ញុំមិនដឹងទេ?” នាងញញឹមបន្តិច រួចតសម្តីមកខ្ញុំវិញថា “[...] ចុះទស្សនៈក្រសែភ្នែកល្អរបស់នារី ដែលបងប្រុសបានសរសេរក្នុងសៀវភៅប្រតិទិនទស្សនៈ២២២ថ្ងៃ?” ខ្ញុំធ្វើជាងឿងឆ្ងល់បន្តិច រួចនិយាយតបថា “ស្រីស្អាតពេកអភ័ព្វ តែបើអាក្រក់ពេក ក៏មិនសមដែរ ។ នារីស្អាតឬមិនស្អាត គឺពុំសូវជារឿងសំខាន់ទេ ។ អ្វីដែលសំខាន់ គឺចំណេះដឹងមើលមនុស្ស ដែល

អាចដឹងថានរណាស្មោះស ឬនរណាមិនល្អ [...]"។

"[...] បើនារីណាម្នាក់តាំងចិត្តអានសៀវភៅក្រេបយកចំណេះដឹងពីឥឡូវនេះបណ្ដើរ ៗ ទៅ យ៉ាងយូរមួយឆ្នាំទៀតនាងនឹងដឹងពីចរិតពិតនៃបុរសល្អ និងរបៀបរស់នៅ ដើរហើរការនិយាយស្ដីរបស់បុរសដែលអាចផ្ដល់សុភមង្គលដល់ជីវិតនាងបាន ។ រីឯម្យ៉ាងទៀត នារីម្នាក់ដែលអាចធ្វើជាប្រពន្ធល្អ និងអាចធ្វើជាម្ដាយល្អទៅបាន គឺត្រូវការចំណេះដឹងច្រើនណាស់ ។ សុភមង្គលនៃជីវិតម្នាក់ឯង ឬមិនថាជីវិតគូទេ គឺត្រូវការចំណេះវិជ្ជា ។ កុំធ្វើជាមនុស្សដែលចេះតែបង្កើតកូនចោលតែមិនចេះប្រៀនប្រដៅអប់រំកូនឱ្យសោះ"។

យុវនារីណាដែលកាន់សៀវភៅពេលបច្ចុប្បន្ន គឺនឹងក្លាយទៅជាម្ដាយដ៏ល្អនាពេលអនាគត ។ នៅសាលាមាន

គ្រូបង្រៀន រីនៅផ្ទះមានស្ត្រី ដ្បិតស្ត្រីមានតួនាទីធំជាអ្នក
បណ្តុះគ្រាប់ពូជសង្គម ។

# ៣៣

## សៀវភៅ និងជាតិ

ការស្រឡាញ់ វាធ្វើឱ្យយើងចេះលះបង់ ។ បើចិត្តស្រឡាញ់ជាតិមានទំហំធំប៉ុនណា នោះការស្រឡាញ់សៀវភៅក៏មានទំហំធំប៉ុណ្ណោះដែរ ។ ស្រឡាញ់ជាតិតិចពេក ការអានសៀវភៅនឹងឆាប់ហត់នឿយ ។ បើស្នេរសរសេរសៀវភៅក្រាស់ៗ គឺនឹងធ្វើឱ្យអ្នកអានត្រូវអានសៀវភៅក្រាស់ៗដែរ ។ ស្នេរម្នាក់ៗតែងប្រឹងប្រែងរាប់ឆ្នាំទម្រាំបានសៀវភៅមួយក្បាលៗ រីឯអ្នកអាន អានមិនដល់រាប់ឆ្នាំទេ ក៏អាចចប់ដែរ ។ ហេតុអ្វីខ្ញុំសរសេរសៀវភៅក្រាស់ៗ ?

ពេលខ្ញុំមានពេលទំនេរ ឬថ្ងៃសីល ខ្ញុំតែងតែចំណាយពេលវេលាទៅប្រាសាទអង្គរវត្ត ។ខ្ញុំចេះតែសម្លឹងមើលពីទឹកដៃ និងស្នាដៃដែលបុព្វបុរសខ្មែរបានបន្សល់ទុក ។ រូបចម្លាក់ខ្លះ ឬអប្សរាខ្លះ ញញឹម ខ្លះមានទឹកមុខមាំ ។ មិនថានៅត្រង់កន្លែងណាទេ គឺសុទ្ធតែមានចម្លាក់ បើទោះបីជាកន្លែងនោះខ្ពស់ទាប ចង្អៀតទូលាយ....ដែលពិបាកឱ្យជាងឆ្លាក់អាចឆ្លាក់បានក៏ដោយ ក៏ខ្ញុំនៅតែឃើញរូបចម្លាក់រចនាយ៉ាងស្រស់ស្អាតស្ទើរតែគ្រប់ទីកន្លែង ។ អត្ថន័យនេះ គឺចង់បង្ហាញអំពីចិត្តអំណត់អត់ធ្មត់នៃដូនតាខ្មែរ ដែលព្យាយាមមិនខ្លាចហឿយហត់ក្នុងកិច្ចដែលខ្លួនត្រូវទទួលខុសត្រូវ ។ បើខ្មែរបាត់បង់ចរិតជាមនុស្សសកម្មលើការប្រឹងប្រែង និងគ្មានចរិតជាអ្នកអត់ធ្មត់ទេ គឺយើងនឹងមិនអាចជោគជ័យឡើយ ។

ដល់ផ្ទះបញ្ចាំងមកបទពិសោធជីវិតជាក់ស្ដែងរបស់ខ្ញុំវិញ ខ្ញុំឱ្យតម្លៃខ្លាំងទៅលើការតស៊ូប្រឹងប្រែង ចិត្តអំណត់អត់ធ្មត់ក្នុងការងារ មិនរអ៊ូថាក្ដៅរងារ បើទោះបីស្ថិតក្នុងកាលៈទេសៈមេឃភ្លៀង ឬបើកថ្ងៃក៏ដោយ។ ការតស៊ូប្រឹងប្រែង និងចិត្តអំណត់នេះហើយ ទើបធ្វើឱ្យមានខ្ញុំនៅថ្ងៃនេះ។ ខ្ញុំហ៊ាននិយាយថា "បើខ្ញុំមិនបានប្រឹងប្រែងទេម្ល៉ោះប្រហែលជាគ្មានខ្ញុំនៅថ្ងៃនេះទេ ឬសូម្បីតែជីវិតក៏រក្សាមិនបានផង។ ជីវិតលំបាកខ្លាំងណាស់ តែវាមិនឈ្នះការប្រឹងទេ"។ តើវាពិតជាធ្ងន់ធ្ងរដល់ថ្នាក់នេះមែនដែរឬទេ? ជីវិតដែលគ្មានការប្រឹងប្រែង គឺនឹងត្រូវស្លាប់ទាំងរស់។ ជីវិតដែលរស់នៅដោយពុំបានប្រឹងប្រែងដោយខ្លួនឯង គឺជាជោគជ័យដែលគ្មានតម្លៃសោះ។ ការងារខ្លះយើងធ្វើបានជោគជ័យ តែវាពុំមែនជាជោគជ័យដែលយកញើសឈាម

ទៅប្តូរ តើយើងនឹងមានអារម្មណ៍បែបណា? ការងារខ្លះប្រឹងយ៉ាងលំបាក តែលទ្ធផលបានតិចតួច តើយើងនឹងមានអារម្មណ៍បែបណា? លទ្ធផលល្អក្តី ឬមិនល្អក្តី គឺវាមានតម្លៃដ្បិតនៅពេលណាដែលយើងបានប្រឹងដោយខ្លួនឯង ។ ចូរធ្វើជាមនុស្សដែលតែងតែមានមោទកភាពលើគ្រប់ការងារដែលយើងបានធ្វើ ។ការងារដែលធ្វើឱ្យយើងមានមោទកភាពគឺសុទ្ធតែកើតចេញពីការប្រឹងប្រែងទាំងអស់ ។

ក្នុងកាលៈទេសៈដ៏លំបាកនៃជីវិត ខ្ញុំយល់ថា វាគឺជាឱកាសមួយដែលអាចឱ្យយើងសាកល្បងសមត្ថភាពខ្លួនឯង ។ សុរិយាចេញយាត្រានាពេលថ្ងៃ ។ ចន្ទ្រា បើគ្មានវត្តមានរាត្រីទេ ក៏គ្មានអ្នកណាស្គាល់តម្លៃនៃពន្លឺដែរ ប្រៀបដូចជាជីវិតមនុស្សយើងម្នាក់ៗ បើគ្មានការលំបាកទេ តើយើងអាច

បញ្ចេញសមត្ថភាពម្ដេចបានទៅ ។ មនុស្សខ្លាំង ឬខ្សោយពិតប្រាកដ យើងនឹងសម្គាល់បានច្បាស់នៅពេលជួបបញ្ហាលំបាក ៗ ប្រៀបដូចជាយើងសម្គាល់ចន្ទ្រាពេលរាត្រីស្ងាត់អ៊ីចឹង ។ ត្រឡប់មកប្រធានបទសៀវភៅវិញ តើយើងប្រឹងអានដែរឬទេ? អ្នកខ្លះយល់ថាខ្ញុំមិនយល់ពីសិល្បៈ រៀបចំសៀវភៅគ្មានសិល្បៈ ។ ឃ្លាដែលនិយាយថា "មិនយល់ពីសិល្បៈ" នេះ គឺចង់ឱ្យខ្ញុំធ្វើអ្វីដែលងាយស្រួល សរសេរសៀវភៅងាយ ៗ រកវិធីឱ្យអ្នកអានចង់អាន មានចំណាប់អារម្មណ៍អាន ។ល។ អ្វីក៏ដោយ គឺត្រូវធ្វើដោយបុព្វហេតុច្បាស់ តែមិនមែនធ្វើដោយសារតែ "ចង់ ឬមិនចង់ ឬធ្វើតាមអារម្មណ៍ល្អអាក្រក់" ទេ ។ បើក្នុងសង្គមយើង រកមនុស្សដែលចង់ចេះចង់ដឹង អ្នកខ្លាំងខាងរៀន ខ្លាំងខាងអានមិនបានផង តើសង្គមរំពឹងអ្វីទៀតទៅថ្ងៃមុខ ។ សូមកុំធ្វើជាមនុស្ស

ដែលចេះចង់បាន តែមិនចង់ប្រឹង ។ កុំធ្វើជាមនុស្សដែលមានត្រឹមតែឆន្ទៈចង់ជួយសង្គម តែគ្មានសមត្ថភាពជួយ ។ ការងារសំខាន់ៗ និងការងារចាំបាច់ជាច្រើននាពេលខាងមុខវាលំបាកជាងការអានសៀវភៅ ៤00 ទៅ៥00ទំព័រ ។

# ២៣

## នឹកអ្នកណា?

អ្នកមានស្នេហា ពេលណាភ្ញាក់ពីគេង គឺតែងមានមនុស្សសំខាន់ដែលត្រូវនឹករឭកដល់ ដ្បិតការនឹករឭកនេះវាជាក្តីសង្ឃឹមក្នុងការរស់នៅមួយ និងកម្លាំងចិត្តក្នុងការបំពេញការងារផងដែរ ។ រីចំណែកឯអ្នកសិក្សា ពេលណាភ្ញាក់ពីគេង គឺមានតែសៀវភៅល្អ ៗ ដែលត្រូវនឹកគិតដល់ ។ ជីវិតរស់នៅដោយគ្មានស្នេហា ប្រៀបដូចជាសុរិយាដែលត្រូវពពកខ្មៅបាំង ។ រីឯជីវិតដែលមានស្នេហាខុស ជួបមនុស្សមិនល្អ គឺប្រៀបដូចជាសូគ្រោសដែលសុរិយាត្រូវងងឹតសូន្យ

ឈឹងគ្មានពន្លឺសោះ ។ តើជីវិតរស់នៅមានអត្ថន័យអ្វីទៅ ?

មនុស្សយើងគួរណាតែរស់នៅជាមួយនឹងបុព្វហេតុមួយដ៏សមគួរ ព្រមទាំងរស់នៅមានសេចក្តីស្រឡាញ់សាកលចំពោះមនុស្សគ្រប់ៗគ្នា ដ្បិតបើយើងគ្មានសេចក្តីស្រឡាញ់ជំរុញដំណើរជីវិតទេ ឬបើរស់នៅជួបតែការឈឺចាប់ញ៉ាំកញ្ញាប់ពេក គឺហាក់នឿយចិត្ត គ្មានកម្លាំងទៅមុខទេ ។ បុព្វហេតុនៃការរស់នៅ វាធ្វើឱ្យយើងចេះរស់នៅដោយអត់ធ្មត់ ស៊ូទ្រាំនឹងការលំបាក បើទោះបីជាស្ថិតក្នុងស្ថានភាពខ្លួនឯងមានជីវិតដូចជាសូត្រាស ឬបើទោះបីជាខ្លួនឯងមានស្ថានភាពជីវិតល្អដូចមេឃទើបរាំងភ្លៀងក៏ដោយ ។ នេះមានន័យថា "ទុក្ខរសាត់មកដល់ជីវិត ក៏នៅតែប្រឹងទៅមុខ ឬបើសុខប៉ះកាយប៉ះចិត្ត ក៏នៅតែទៅមុខជានិច្ចដែរ ។ ពេលក្រ ពេល

ហាក់នឿយមែនទែនពេលឈឺចាប់ខ្លោចចិត្តគឺមិនអស់សង្ឃឹមឡើយ ។ ពេលមានបាន ពេលសប្បាយរីករាយ គឺមិនដាច់បង្កៀរ” ។ ចុះចំណែកឯសេចក្តីស្រឡាញ់សាកលវិញ តើវាមានន័យបែបណា ?

គ្មាននរណាម្នាក់អាចរស់នៅដោយគ្មានអ្នកយល់ចិត្តបានទេ ។ ពេលខ្លះ មនុស្សយើងស្ទើរតែគ្រប់គ្នាចង់មានសេចក្តីសុខជាមួយនឹងមនុស្សដែលខ្លួនស្រឡាញ់ពិត តែតើបំណងប្រាថ្នាទាំងនេះ វានឹងអាចសមតាមចិត្តយើងគ្រប់ៗដែរឬទេ ? វាមិនអាចទៅរួចទាំងស្រុងឡើយ ដ្បិតមនុស្សដែលយើងស្រឡាញ់ បែរជាមិនស្រឡាញ់យើង ហើយមនុស្សដែលយើងមិនស្រឡាញ់ បែរជាមកចាប់អារម្មណ៍ដាក់ចិត្តស្រឡាញ់យើងទៅវិញ ។ ជីវិតបែបនេះ ហេតុអ្វីក៏បញ្ច្រាស

គ្នា? ចុះហេតុអ្វីទេវតាមិនឱ្យមនុស្សដែលយើងស្រឡាញ់ស្រឡាញ់តបចំពោះសេចក្ដីស្រឡាញ់របស់យើង ឬចុះហេតុអ្វីទេវតាមិនកំណត់ឱ្យយើងស្រឡាញ់តបចំពោះមនុស្សដែលស្រឡាញ់យើងខ្លាំង? នេះឬជាជីវិតមនុស្សលោក?

សេចក្ដីស្រឡាញ់បែបសាកល វានឹងធ្វើឱ្យយើងចេះរស់នៅផ្សាយមេត្តាចំពោះអ្វីដែលនៅក្បែរខ្លួនយើង មិនថាជាមនុស្ស សត្វ ធម្មជាតិ ឬអមនុស្ស ខ្មោច ព្រាយ បិសាចឡើយ ។សេចក្ដីស្រឡាញ់សាកលវាគឺជាអារម្មណ៍ដែលបំពាក់នូវចិត្តបរិសុទ្ធក្នុងខ្លួនមនុស្សគ្រប់រូប ។ ខ្ញុំមានបទពិសោធជួបជជែកជាមួយនឹងយុវជនឆ្នើមម្នាក់ ដែលមានឈ្មោះបោះសំឡេងក្នុងសង្គម ។ ដល់ពេលជួប គ្រាន់តែដើរទៅក្បែរ និងមើលក្រសែភ្នែក ខ្ញុំទទួលអារម្មណ៍ថា "ម្នាក់នេះ

ខាងក្រៅដូចជារឹងមាំល្អណាស់ តែខាងក្នុងចិត្តវិញ ពិតជាជំពាក់ជំពិននឹងរឿងស្នេហាគ្រោកច្រើនណាស់ ទាំងផ្លូវជីវិតស្នេហា ជីវិតការងារ និងទំនាក់ទំនងសង្គម" ។ អំណាចនៃចិត្តបែបនេះ វាប្រៀបដូចកែវពង្រីកមើលអ្វីដែលនៅក្នុងខ្លួនមនុស្សអ៊ីចឹង ។ ត្រង់ចំណុចនេះគឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ហើយសូមមេត្តាកុំយល់ផ្តេសផ្តាស ។ ចុងក្រោយតើអ្នកអានយល់ពីអ្វីដែលខ្ញុំសរសេរទេ ?




អ្នកដែលអវិជ្ជាក្នុងសម័យនេះ គឺមិនមែនជាបុគ្គលមិនចេះអក្សរទេ តែជាមនុស្សដែលមិនចូលចិត្តអានសៀវភៅ និងមិនសូវរៀនសូត្រជាប្រចាំ ។

# ៣៤

## សៀវភៅទស្សនៈ

សៀវភៅខ្លះជាប្រភេទសៀវភៅទស្សនៈ ។ទស្សនៈគឺជាដំណើរនៃការយល់ឃើញ ។ ការយល់ឃើញ គឺតែងស្ថិតនៅចន្លោះរវាងខុសនិងត្រូវ ។ ខុសនិងត្រូវ គឺតែងនៅលាយឡំជាមួយគ្នាជានិច្ច តែអ្វីដែលសំខាន់បំផុត  គឺកាលៈទេសៈជាក់ស្ដែង  ឬស្ថានភាពជាក់ស្ដែង ។  គំនិត  ឬទស្សនៈល្អត្រឹមត្រូវ  តែបើប្រើខុសស្ថានភាព ឬខុសកាលៈទេសៈ គឺស្មើនឹងមិនបានផលល្អ ហើយទស្សនៈខុស តែបើយកមកប្រើត្រូវស្ថានភាព  ឬត្រូវកាលៈទេសៈ  គឺស្មើនឹងបានផល

ល្អ។ ទស្សនៈខ្លះ វាត្រឹមត្រូវក្នុងកាលៈទេសៈនេះ តែអាចប្រើមិនកើតការណ៍នៅពេលក្រោយ ឬខុសពេលនេះ តែវាប្រហែលជាអាចប្រើបានការណ៍នៅពេលក្រោយ។

បើទោះបីជាលោកអ្នកយល់ថាខុស ឬត្រឹមត្រូវក៏ដោយ តែសូមលោកអ្នកមេត្តាកុំធ្វើជាកញ្ជ្រះនៃគំនិតអ្នកនិពន្ធណា ឬជាកញ្ជ្រះនៃគំនិតទស្សនវិទូណា ឬជាកញ្ជ្រះនៃគំនិតរបស់បុគ្គលត្រាស់ដឹងណាឱ្យសោះ។ ការបន្សុទ្ធចំណេះដឹង និងព្យាយាមគិតពិចារណាថ្លឹងថ្លែងដោយខ្លួនឯង វាគឺជាដំណើររកឃើញនូវគតិបណ្ឌិត។ ជំនាញក្នុងការគិតពិចារណា គឺសំខាន់ជាងជំនាញក្នុងការជឿ។ គិតដោយគ្មានការរៀន គឺនឹងនាំឱ្យវង្វេងដោយគ្មានគោលការណ៍ ហើយរៀនគ្មានការគិតពិចារណា នឹងចាំតែជឿស៊ប់ដោយងងឹតងងុល។

ខ្ញុំសង្ឃឹមថា លោកអ្នកអាននឹងព្យាយាមអានអត្ថបទទស្សនៈដោយយកចិត្តទុកដាក់ ជាមួយនឹងការបើកបេះដូងទទួលស្គាល់ការពិតផង និងពិចារណាការមិនពិតផង ។ រឿងដែលខ្ញុំបារម្ភជាងគេបំផុត គឺរឿងនយោបាយ និងសាសនា ពីព្រោះរឿងទាំងពីរនេះតែងក្លាយជារនាំងញែកមនុស្សឱ្យមានការស្អប់ស្រឡាញ់ ទំនាស់គ្នា និងអើសអើងមនុស្សដូចគ្នា ។ នៅពេលដែលអារម្មណ៍មនោសញ្ចេតនាផុសឡើងបែបអវិជ្ជមាន គឺប្រៀបដូចជាភ្លើងឆេះកម្ទេចការពិចារណាក្នុងខួរក្បាលមួយខណៈ ។ មែនឬមិនមែន ខុសឬត្រូវ ពិតឬក្លែងក្លាយ គឺសុំត្រឹមតែរក្សាអារម្មណ៍នឹងនរ មិនរំជើបរំជួល មិនក្តុកក្តួល និងមិនខឹងសម្បា ឬស្អប់ស្រឡាញ់ ។

បើលោកអ្នកជាសាសនិកជនដែលមានជំនឿស៊ប់លើ

និកាយសាសនាណាមួយ នៅពេលណាដែលអានសៀវភៅខ្លះ បើប៉ះចំចំណុចដែលប្រឆាំងនឹងគោលជំនឿសាសនារបស់លោកអ្នក គឺសូមមេត្តាកុំយកចិត្តទុកដាក់ ឬកុំប្រតិកម្មអារម្មណ៍ ពីព្រោះជៀសវាងការធ្វើឱ្យអារម្មណ៍លោកអ្នកមិនល្អ ឬល្អក់កករ ។ បើលោកអ្នកមាននិន្នាការនយោបាយលើបក្សណាមួយ នៅពេលដែលអានប៉ះចំគំនិតដែលប្រឆាំងនឹងនិន្នាការនយោបាយផ្ទាល់របស់លោកអ្នក គឺសូមមេត្តាកុំប្រតិកម្មអារម្មណ៍ដូចគ្នាដែរ ។

ក្នុងខណៈពេលអាន បើលោកពុំបានយល់ខ្លឹមសារណាមួយសោះពីអត្ថបទ តែយ៉ាងហោចណាស់ ក៏គួរតែស្វែងរកឃ្លា ឬប្រយោគដែលងាយស្រួល អាចយល់បានមិនថាមួយឃ្លា ឬពីរឃ្លាទេ ពីព្រោះបើធ្វើបែបនេះ គឺដើម្បី

ជៀសវាងការអានរំលងទំព័រណាមួយ ដោយពុំយល់អត្ថន័យអ្វីសោះពីសៀវភៅ ។ តាមបទពិសោធខ្ញុំផ្ទាល់ សៀវភៅខ្លះខ្ញុំចំណាយពេលអានមួយឆ្នាំទើបអាចយល់បាន ពីព្រោះពេលខ្លះខ្ញុំយល់ថា ចំណេះដឹងរបស់ខ្ញុំនៅមានកម្រិត ដែលជាបុព្វហេតុអាចឱ្យខ្ញុំពិបាកយល់នូវអ្វីដែលខ្ញុំមិនធ្លាប់បានយល់ពីមុន ។ ប៉ុន្តែ ឱ្យតែមានការព្យាយាមតាំងចិត្តខ្ពស់មិនថាអត្ថន័យឬឃ្លាប្រយោគពិបាកប៉ុនណាទេ គឺគ្រប់យ៉ាងសុទ្ធតែអាចទៅរួចទាំងអស់ ។ បើលោកអ្នកយល់ថាមានទស្សនៈខ្លះល្អ ឬគំនិតខ្លះគួរតែពិចារណា និងមានប្រយោជន៍ លោកអ្នកអានគួរតែប្រឹងអានម្តងហើយម្តងទៀត ដើម្បីជាការចងចាំ និងអាចពង្រីកគំនិតនេះ ឬគំនិតនោះទៅតាមរបៀបមួយផ្សេងទៀត ។

# ៣៥

## អានដោយពុំគិត

អាល់ប៊ឺត អាញស្តាញ និយាយថា “មនុស្សណាដែលប្រឹងអានច្រើនបំផុត តែបែរជាប្រើប្រាស់ខួរក្បាលគិតតិចតួចបំផុត គឺនឹងធ្លាក់ចូលទៅក្នុងទម្លាប់ខ្ជិលគិត” ។

ធម្មជាតិបង្កើតមនុស្សឱ្យមានដៃពីរ ជើងពីរ គឺឱ្យយើងប្រឹង ។ ឱ្យមានភ្នែកពីរ គឺឱ្យយើងសម្លឹងមើលទៅមុខ និងមើលគ្រប់យ៉ាង ។ ឱ្យមានត្រចៀកពីរ គឺស្តាប់ឱ្យច្រើន ។ ឱ្យមានមាត់មួយ គឺនិយាយឱ្យតិចឬច្រើន ត្រូវមើលកាលៈទេសៈ ។

យើងមានដៃជើង មានភ្នែក មានត្រចៀក មានមាត់ តែបើត្រឹមតែរៀនដោយទទួលយកព័ត៌មាននិងទទួលទិន្នន័យ ដោយឥតប្រើខួរក្បាលគិត ឬបន្សុទ្ធចំណេះដឹងទេ នោះរាល់ចំណេះដឹងទាំងឡាយគឺឥតន័យហើយក៏ឥតប្រយោជន៍ដែរ ។

ក្នុងនាមជាអ្នកអាន សូមកុំធ្វើជាកញ្ជះដាច់ថ្លៃនៃគំនិតរបស់អ្នកនិពន្ធឱ្យសោះ ។ ការសាបព្រោះចំណេះដឹងខុស គឺប្រៀបដូចជាសាបព្រោះគ្រោះកាចដល់សង្គមទាំងមូល ។ ខួរក្បាលទម្ងន់ ១.៣ ទៅ១.៥គីឡូ តែវាអាចដឹកនាំ និងគ្រប់គ្រងខ្លួនប្រាណទាំងមូលរបស់មនុស្សរាប់សិបគីឡូបាន ។

*“Any man who reads too much and uses his own brain too little falls into lazy habits of thinking.”*

*– Albert Einstein*

# ២៦

## លួចញញឹម

“[...] តើសៀវភៅនេះនិយាយអំពីអ្វីខ្លះ?” ខ្ញុំតបថា “សៀវភៅនេះនិយាយអំពីរឿងជាច្រើន តែមិននិយាយពីស្នេហាទេ”។ ប្អូនស្រីនៅខាងឆ្វេងតបថា “ធ្វើដូចជាខ្ញុំចូលចិត្តរឿងស្នេហាអ៊ីចឹង”។ ខ្ញុំសួរថា “តើប្អូនធ្លាប់មានស្នេហាទេ?” អ្នកកណ្តាលតបថា “មិនដែលធ្លាប់មានផង”។ ខ្ញុំបញ្ជាក់ថា “មិនកុហកទេ?” ក្រោយមកមានអ្នកលួចញញឹម។

ខ្ញុំបានសួរទៅនារីខាងស្តាំថា “មានបុរសប៉ុន្មាននាក់

តាមសុំស្នេហ៍ប្អូនស្រី សូមប្រាប់ខ្ញុំឱ្យអស់មក ហើយអាយុប៉ុនណោះ ចេះស្រឡាញ់ហើយឬនៅ?"។ គ្មានអ្នកឆ្លើយ ហើយខ្ញុំបាននិយាយថា "ឥឡូវ ខ្ញុំសួរទាំងអស់គ្នា ហើយសូមឆ្លើយម្នាក់ម្ដងមក"។ បន្ទាប់មក ម្នាក់ៗញញឹមឆ្លើយគ្រប់សំណួរដែលខ្ញុំចង់ដឹងតាមរយៈក្រសែភ្នែករៀងៗខ្លួន។ ខ្ញុំនិយាយថា "ឥឡូវពេលនេះ ខ្ញុំយល់ហើយ"។ ម្នាក់ៗសួរខ្ញុំថា "បងប្រុសយល់រឿងអ្វីដែរ?"

ខ្ញុំនិយាយ "[...] នៅក្មេង នៅមានឱកាសរៀន នៅមានស្ថានភាពមិនទាន់យ៉ាប់យឺន គឺថាសូមប្រឹងប្រែងរៀន ប្រឹងប្រែងអានសៀវភៅល្អៗ រស់នៅក្បែរមនុស្សល្អៗ ហើយបន្តដំណើរជីវិតឱ្យមានន័យ។ ជីវិតដែលមានន័យវាស្ថិតនៅលើសេចក្ដីស្រឡាញ់ តែបើសេចក្ដីស្រឡាញ់មិន

បរិសុទ្ធទេ វានឹងធ្វើឱ្យជីវិតល្អក់កករ ។ ចំណេះដឹងនឹងធ្វើឱ្យយើងចេះមើលមនុស្សល្អអាក្រក់ ប្រៀបដូចជាចង្កៀងដែលបំភ្លឺនារាត្រីស្ងាត់អ៊ីចឹង" ។ ខ្ញុំបានប្រាប់ទៅគាត់ទាំងបីនាក់ឱ្យចូលអង្គុយចុះ រួចហើយដៃកាន់សៀវភៅ ។ ម្នាក់កណ្ដាលបានសួរខ្ញុំថា "បងប្រុសចង់ធ្វើអ្វី?" ខ្ញុំថា "អង្គុយសិន ហើយនេះជាសៀវភៅ" ។ សូមកាន់ ហើយមើលមកខ្ញុំជាអ្នកថត ។ ១..២...៣ សុំថតមួយ អង្គុយឱ្យស្រួល ញញឹមឱ្យស្រស់ ។ "ជាទូទៅ គ្រប់ពេលវេលាដែលខ្ញុំចំណាយនិយាយចែករំលែក ខ្ញុំពុំដែលគិតថ្លៃឡើយ តែពេលនេះសុំថ្លៃឈ្នួល ពីព្រោះអ្នកទាំងបីចាប់កំណើតមកជាមួយនឹងភាពស្រស់ស្អាតក្នុងនាមជានារី" ។ ដល់ពេលនិយាយបែបនេះរួចហើយ ម្នាក់ៗធ្វើមុខស្មើធម្មតា តែមានអ្នកខ្លះបែរក្រោយហើយលួចញញឹម ។

# ៣៧

## អក្សរជួយសង្គម

មិនបានអាន មិនប្រឹងអាន មិនបានសរសេរ មិនប្រឹងសរសេរ កុំថាឡើយដល់អាចជួយសង្គម ប៉ុន្តែសូម្បីតែជួយខ្លួនឯង ក៏ជួយមិនបានផង ។

"អក្សរមួយឃ្លា និងសម្ដីមួយម៉ាត់ វាគឺជាអ្នកឆ្លាក់ខួរក្បាលមនុស្ស" ។ នេះជាឃ្លាមួយដែលខ្ញុំបានសរសេរនៅក្នុងសៀវភៅ "ប្រតិទិនទស្សនៈ ២២២ថ្ងៃ" ត្រង់ជំពូក១ ទំព័រទី៨ ។ ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ មនុស្សបានប្រើប្រាស់អក្សរឆ្លាក់ខួរក្បាលសង្គម អន្លងដួងព្រលឹង

មនុស្ស និងដុសខាត់ស្មារតីមនុស្ស ។ មានអ្នកនិពន្ធជាច្រើន ដែលប្រើប្រាស់សំណេរសរសេរឱ្យអ្នកអានពិចារណា មិនថាក្នុងផ្លូវជីវិត ផ្លូវសាសនា ឬផ្លូវនយោបាយទេ ។

ខ្មែរសម័យបុរាណប្រើប្រាស់រូបចម្លាក់ឆ្លាក់អត្ថន័យនៃខ្លឹមសារ និងចារឹករឿងរ៉ាវប្រវត្តិសាស្ត្រតាមផ្ទាំងសំណង់ប្រាសាទ ។ សំណេររបស់អ្នកនិពន្ធខ្លះ មិនថាជាអ្នកនិពន្ធបរទេស ឬអ្នកនិពន្ធខ្មែរយើងទេ គឺតែងតែមានអ្នកយកសំណេរមកសរសេរធ្វើជាខ្សែភាពយន្ត (script to screen) ជាល្ខោននិយាយ និងជាសាច់រឿងដែលមានន័យខ្លឹមសារអាចផ្លាស់ប្តូរសង្គមក្នុងផ្លូវវិជ្ជមានបាន ។ នេះសុទ្ធតែជាផ្នែកនៃសិល្បៈ និងជាអំណាចនៃសំណេរទាំងអស់ ។ ម្យ៉ាងវិញទៀតមុននឹងអាចបំប្លែងសំណេរផ្ទេររូបរាងទៅជាសិល្បៈចម្លាក់

ឬល្បោន ឬផ្ទាំងទស្សនីយភាពណាមួយបាន គឺស្នេរនិងអ្នកនិពន្ធត្រូវយល់ដឹងឱ្យច្រើនពីក្បួនខ្នាតនៃការសរសេរព្រមទាំងគំនិតនៃការសរសេរ ។

ត្រង់ចំណុចនេះ ខ្ញុំសង្កេតឃើញថា "អ្នកខ្លះចេះក្បួនសរសេរ តែមិនមានគំនិតស៊ីជម្រៅអាចសរសេរបាន ។ រីឯចំពោះអ្នកខ្លះទៀត មានគំនិតស៊ីជម្រៅអាចសរសេរបានតែមិនចេះក្បួនខ្នាតសរសេរ" ។ បើឱ្យជ្រើសរើស ស្នេរគួរតែចេះទាំងក្បួន និងមានទាំងគំនិតស៊ីជម្រៅក្នុងការសរសេរ ។ ប៉ុន្តែបើឱ្យជ្រើសរើសរវាងការចេះក្បួន និងគំនិតសរសេរស៊ីជម្រៅ យើងគួរតែជ្រើសរើសយកការមានគំនិតស៊ីជម្រៅសរសេរ ដ្បិតក្បួនសរសេរអាចរៀនបានចេះ និងអាចរៀនពីស្នាដៃនៃអ្នកនិពន្ធដទៃ ៗ បាន ។ ក្នុងទឹកដៃនៃ

សំណេរនីមួយៗ បើអ្នកអានចេះអានខ្លាំង និងចេះអានរហូតដល់ពាល់ព្រលឹងស្នេរ គឺថាអ្នកអាននឹងឆាប់យល់ភ្លាមថាតើសំណេរនេះជាទឹកដៃអ្នកនិពន្ធរូបណា ។ តើអ្នកណាជាអ្នកពូកែសរសេរ?

បុគ្គលដែលពូកែសរសេរ គឺជាមនុស្សដែលចូលចិត្តអាន ពូកែអាន ព្រមទាំងចេះវិភាគនូវគំនិតបានយ៉ាងម៉ត់ហ្មត់ល្អិតល្អន់ ស៊ីជម្រៅបំផុត ។ អ្នកនិពន្ធសញ្ជាតិអាមេរិកម្នាក់និយាយថា "បើសិនជាយើងចង់ក្លាយខ្លួនទៅជាអ្នកនិពន្ធ គឺយើងត្រូវធ្វើរឿងពីរយ៉ាង៖ ទី១ ត្រូវតែធ្វើជាអ្នកដែលអានច្រើន និងទី២ ត្រូវតែធ្វើជាអ្នកសរសេរច្រើន" ។ យើងមិនអាចសរសេរដោយប្រើភាសានិយាយបានទេ ដ្បិតការសរសេរវាពិបាកជាងនិយាយឆ្ងាយណាស់ ។ ភាសាសរសេរខុសពី

ភាសានិយាយ ហើយការសរសេរ គឺស្មើនឹងគិត ។ អ្នកនិពន្ធប្រឆាំងរបបផ្តាច់ការ ចច អូវែល (George Orwell) និយាយអំពីរឿងសរសេរនេះថា “ប្រសិនជាមនុស្សមិនអាចសរសេរបានល្អទេ គឺស្មើនឹងគិតមិនបានល្អ ។ បើមនុស្សមិនចេះគិតទេ គឺនឹងមានអ្នកដទៃគិតជំនួសវិញ” ។ ឃ្លាដែលថា “មានអ្នកដទៃគិតជំនួស” គឺមានន័យស្តីពីការដឹកនាំដែលមានមេដឹកនាំមិនល្អ ប្រើប្រាស់អំណាចគិតជំនួស ធ្វើជំនួស និងសម្រេចជំនួស ក្នុងលក្ខខណ្ឌគាបសង្កត់ ។ និយាយដោយខ្លីរឿងនេះមិនខុសពីទស្សនៈរបស់រូបវិទូ អាលប៊ឺត អាញស្តាញ ដែលថា “ការគិត គឺលំបាកខ្លាំងណាស់ [...]” ។

នៅក្នុងវេទិកានិយាយអំពី “ការអាន” មួយ, ខ្ញុំបានទទួលសំណួរមួយពីអ្នកចូលរួម ដែលសួរថា “តើត្រូវធ្វើបែប

ណាដើម្បីលើកកម្ពស់ការអានទៅក្នុងសង្គមយើង” ។ ខ្ញុំឆ្លើយថា “គឺចូរលុបពាក្យ ‘Face’ ចេញ ហើយទុកតែពាក្យថា ‘Book’ ទៅបានហើយ ។ ធ្វើឱ្យបណ្ដាញសង្គម ‘Facebook’ ក្លាយទៅជាបណ្ណាល័យអំណានសម្រាប់មនុស្សគ្រប់គ្នា” ។ គ្រប់គ្នាត្រូវចូលរួមសរសេរចែករំលែកចំណេះដឹង និងជំរុញឱ្យការអានកើនឡើងផុសផុល ។ បើកហ្វេសប៊ុកកន្លែងណាឃើញចំណេះដឹងត្រង់នោះ ។ ដល់ពេលខ្ញុំចេញមកខាងក្រៅក៏មានបញ្ញាវន្តថ្នាក់ខ្ពស់ម្នាក់បានចោទសួរខ្ញុំថា “ក្នុងនាមជាស្មេរ តើត្រូវធ្វើបែបណាដើម្បីកុំសរសេរបែបអត្តនោម័តិលើគំនិត” ។ សំណេរអត្តនោម័តិ គឺសំដៅទៅលើសំណេរដែលដាច់ខាត និងមានលក្ខណៈលម្អៀងទៅខាងណាមួយ ។ លម្អៀងនៅត្រង់ថា “បើយើងមាននិន្នាការប្រកាន់លើសាសនា ឬនយោបាយបក្សណាមួយ គឺយើងនឹងសរសេរ

គាំទ្របក្សនោះឬសាសនានោះ" ។ ខ្ញុំតបថា "ចំពោះទស្សនៈខ្ញុំ បើខ្ញុំជាស្មេរ ជាពិសេសស្មេរសង្គម គឺពុំគួរមាននិន្នាការបក្សនិយមណាមួយ ឬសាសនានិយមណាមួយទេ ប៉ុន្តែត្រូវសរសេរអ្វីដែលជាការពិត ឬប្រើធាតុសត្យានុម័ត ។ សំណេរបែបនេះ អ្នកប្រឆាំងក៏អាចអានបាន រីអ្នកស្របក៏អាចអានបាន ។ ផ្ទុយទៅវិញ បើសំណេរមាននិន្នាការ ឬជាស្មេរមាននិន្នាការ គឺដូចជាមិនសូវល្អទេ" ។

"[...] ក្នុងសំណេរប្រវត្តិសាស្ត្រ គឺស្មេរបានប្រើធាតុសត្យានុម័តក្នុងការសរសេរ ដោយបង្ហាញពីព្រឹត្តិការណ៍ដែលបានកើតឡើងជាក់ស្តែង ។ បើស្មេរប្រវត្តិសាស្ត្រមានទំនោរ សំណេរក៏ទោទន់ទៅគាំទ្រ ឬប្រឆាំងនឹងក្រុមម្ខាងដាច់ខាតដែរ" ។ សំណួរដេញបន្ត "ចុះសួរថា តើសំណេរ

បែបណាដែលគ្មាននិន្នាការ ជាពិសេសទាក់ទងនឹងសំណេរបែបស្មារតីសង្គម?” ខ្ញុំតបតាមទស្សនៈថា “គ្មានទេឡើយ សំណេរដែលគ្មាននិន្នាការ ដ្បិតយ៉ាងហោចណាស់ ក៏ស្មេរត្រូវតែទេរទៅខាងភាពត្រឹមត្រូវឬខុសដែរ ។ ការសរសេរទៅរកនិន្នាការដែលគាំទ្រការពិត និងសរសេរការពិត គឺជាសំណេរដែលត្រឹមត្រូវ” ។ អ្នកសួរក៏បានសរុបប្រាប់ខ្ញុំវិញថា “អ៊ីចឹងមានន័យថា ស្មេរសង្គម គឺត្រូវលាងសម្អាតខ្លួនឯងឱ្យស្អាត កុំឱ្យប្រឡូកប្រឡាក់នឹងនិន្នាការណាមួយ ជាមនុស្សកណ្ដាលនិយម ដែលមានទំនោរទៅរកភាពសច្ចៈត្រឹមត្រូវ ប៉ុន្តែត្រូវឈរលើគោលការណ៍ត្រឹមត្រូវ ឬនិន្នាការការពិត ។ បើស្មេរសរសេររបៀបមើលសង្គមក្នុងសភាពខ្មៅងងឹតពេក ឬសរសេរលើកដើងស្ថានការណ៍សង្គមឱ្យល្អផូរផង់ពេក ឬសរសេរដោយមាននិន្នាការ គឺមានន័យថា ស្មេរ

ចូលរួមបំពុលសង្គម”។ ខ្ញុំតបថា “សំណួរដែលបានសួរខ្ញុំ ខ្ញុំបានឆ្លើយរួចហើយ រីចំណែកការសន្និដ្ឋានចុងក្រោយបែបណា វាគឺជារឿងបុគ្គលអ្នកស្តាប់ទេ”។



បើយើងយកការដកដង្ហើមធំ និងសេចក្តីខ្វល់ខ្វាយតានតឹងទាំងឡាយ មកដាក់លើសៀវភៅ នោះវាប្រសើរជាងការទៅត្អូញត្អែរដាក់លើអ្នកដទៃ ។

# ៣៨

## តើនាងជានរណា?

បេះដូងរបស់នាងគឺជាបេះដូងស្មោះត្រង់ដួងចិត្តថ្លាឆ្វង់បរិសុទ្ធ ឥតមានឯាករ តែដំណើរនៃជីវិតស្នេហា វាបានធ្វើឱ្យបេះដូងរបស់នាងច្រៀកជាចម្រៀកតូច ៗ ដោយពុំដឹងថាត្រូវផ្គុំជាប់គ្នាវិញរបៀបណា ។ នាងជាមនុស្សមានគូច្រើន ដ្បិតចរិតរបស់នាងអាចសម្របខ្លួនរស់នៅនឹងបុរសគ្រប់ប្រភេទបាន តែបេះដូងនាងនៅតែមិនអាចដាក់បុរសណាម្នាក់ជំនួសអ្នកបានឡើយ ។

តើនាងជានរណា? នាងគឺជា "ភាពស្មោះត្រង់" ។

នាងសុខចិត្តជ្រើសរើសយកការឈឺចាប់ធ្វើជាមិត្តស្និទ្ធស្នាល រស់នៅជាមួយភាពស្ងៀមស្ងាត់ និងយកតំណក់ទឹកភ្នែកធ្វើជាទីប្រឹក្សា ។ ពេលណានាងឈឺចាប់ខ្លាំង រហូតដល់ទ្រាំមិនបាន គឺដំណក់ទឹកដែលមានរសជាតិប្រៃដូចសមុទ្រនឹងចេញមកលួងលោមប្រលោមអារម្មណ៍របស់នាងឱ្យធូរស្រាលបណ្តោះអាសន្នអន់មួយគ្រា ។

ខ្ញុំយល់អារម្មណ៍មនោសញ្ចេតនាដ៏ជ្រាលជ្រៅដែលមានក្នុងបេះដូងរបស់នាង តែខ្ញុំជួយនាងមិនបានទេ ដ្បិតការឈឺចាប់វាត្រូវការពេលវេលាព្យាបាល ។ ទឹកល្អក់ត្រូវការពេលវេលាដើម្បីឱ្យថ្លាវិញ រីឯការឈឺចាប់របស់នាងក៏ត្រូវការពេលវេលាដូចគ្នាដែរ ។ ខ្ញុំចង់នៅក្បែរនាងគ្រប់ពេលវេលា តែនាងគ្មានអារម្មណ៍មកចង់នៅក្បែរខ្ញុំទេ ។ ខ្ញុំចង់លួងលោម

នាងរាល់ពេលណាដែលនាងមិនសប្បាយចិត្ត តែនាងគ្មានស្នាមញញឹម និងភាពរឹងមាំមកអង្គុយជាមួយខ្ញុំឡើយ ។ តើខ្ញុំជានរណា ? ខ្ញុំគឺជា "សៀវភៅ" ។

# ៣៩

## ចរិតអ្នករៀន

អ្នករៀន ប្រើពេលវេលានៃថ្ងៃសម្រាកដើម្បីរៀន តែអ្នកមិនរៀនវិញ ប្រើពេលវេលានៃថ្ងៃសម្រាក ដើម្បីដើរលេង ។ អ្នករៀន ត្រូវហ៊ានឈឺចាប់ ដ្បិតរសជាតិនៃការអប់រំ តែងល្វីងជូរចត់មែនទែន តែផ្លែផ្ការបស់វាមានរសជាតិផ្អែមណាស់ ។ អ្នកក្រដែលគ្មានលុយរៀន គ្មានឱកាសរៀនសាលាល្អៗ គ្មានអ្នកជួយជ្រោមជ្រែង បើបណ្តោយខ្លួនឱ្យដូចកូនអ្នកមាន គឺពុំបានឡើយ ។

ពេលក្រ កុំអស់សង្ឃឹម ពេលមាន កុំភ្លើតភ្លើន តែយើង

ត្រូវទប់ខ្លួនឯងឱ្យជាប់ ឈរឱ្យនឹង ហើយកុំរំជើបរំជួល។ សេចក្តីលំបាកធ្វើឱ្យមនុស្សឈឺចាប់ តែការឈឺចាប់ វាបានធ្វើឱ្យមនុស្សរឹងមាំ ។ ទ្រឹស្តីពុទ្ធនិយមបង្ហាញថា "យើងត្រូវរៀនទទួលយកព្យុះភ្លៀងក្នុងជីវិត ដ្បិតបើគ្មានទឹកភ្លៀងទេ ក៏គ្មានដើមរុក្ខជាតិណាអាចដុះលូតលាស់បានដែរ" ។ អ្នកដទៃមានលុយ តែយើងមានឆន្ទៈ ។ អ្នកដទៃមានអ្នកជួយជ្រោមជ្រែង តែយើងមានការអត់ធ្មត់ និងចិត្តអំណត់ ។ ឆន្ទៈ និងចិត្តអំណត់ គឺជាអំណាច ។

អ្វីដែលបានលើកឡើងខាងលើនេះ វាជាគោលការណ៍ដែលខ្ញុំប្រើអស់រយៈពេលជិត ១៥ឆ្នាំ ។ "ការកើតជាមនុស្សគឺជាមង្គលដ៏ឧត្តម" ។ "មង្គល" គឺដោយសារយើងនៅមានឱកាសប្រឹង ។ "មង្គល" គឺដោយសារយើងមានឱកាស

ប្រើរូបរាងកាយនេះ ដើម្បីដុសខាត់ព្រលឹងរបស់ខ្លួនឯងបាន ។ “មង្គល” គឺដោយសារយើងមានអំណាចគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរជីវិតរបស់ខ្លួនបាន ។ មនុស្សដែលបានកើតនៅលើផែនដីនេះ អត់អ្វីអត់ចុះ តែកុំឱ្យតែអត់ស្គាល់ខ្លួនឯង ។

# ៣០

## អំណាចទឹកខ្មៅ

"បើអ្នកនិពន្ធមិនបញ្ចូលអារម្មណ៍រហូតដល់ស្រក់ទឹកភ្នែកក្នុងពេលតែងនិពន្ធទេ នោះអ្នកអានក៏ពុំអាចស្រក់ទឹកភ្នែកក្នុងពេលកំពុងអានដែរ ។ បើអ្នកនិពន្ធមិនបញ្ចូលអារម្មណ៍រំភើបក្នុងពេលសរសេរទេ អ្នកអានក៏អានដោយគ្មានអារម្មណ៍រំភើបក្នុងពេលកំពុងអានដែរ" ។

ខ្ញុំចាត់ទុកការអានប្រៀបដូចជាការដកដង្ហើមចូល ហើយចាត់ទុកការសរសេរប្រៀបដូចជាការដង្ហើមចេញ ។ ខ្ញុំធ្លាប់ពាល់អារម្មណ៍ម៉្យាងចេញពីសៀវភៅខ្លះដែលវាមិន

ត្រឹមតែជាចំណីខួរក្បាលប៉ុណ្ណោះទេ តែធ្វើឱ្យអ្នកអានមានអារម្មណ៍រំជើបរំជួល រំភើបញាប់ញ័រ និងប្រៀបដូចខ្លួននៅក្នុងព្រឹត្តិការណ៍ ។ ក្នុងកាលៈទេសៈខ្លះ ខ្ញុំបានស្រូកអារម្មណ៍ចូលទៅក្នុងគំនិតនៃអ្នកសរសេរទៀតផង ។

នៅក្នុងបរិបទនៃការតែងនិពន្ធ ខ្ញុំបានសង្កេតឃើញមានអ្នកសរសេរ ២ប្រភេទ៖ ទី១. គឺជាអ្នកសរសេរដែលចេះបង្ហាញត្រឹមអារម្មណ៍ដល់អ្នកអាន តែគ្មានខ្លឹមសារអប់រំពិតប្រាកដ ។ សំណេរមនោសញ្ចេតនាអវិជ្ជមានបែបនេះតែងពង្វក់អ្នកអានឱ្យឈ្លក់ក្នុងស្បែអន្តកាលនៃអារម្មណ៍រហូតដល់អ្នកអានខ្លះងើបមិនរួចពីអារម្មណ៍និយម ឬអ្នកអានខ្លះលន្លង់លន្លោចនឹងជីវិតបែបអារម្មណ៍ ឬចេញមិនផុតពីការឈឺចាប់ ។ ទីផ្សារអត្ថបទ ឬសៀវភៅបែប

មនោសញ្ចេតនា គឺពេញនិយមជាងអត្ថបទអប់រំ ។ ទី២. គឺអ្នកសរសេរបែបប្រើហេតុផលជ្រុលពេក គំនិតនិយមជ្រុលពេក ឬទស្សនៈជ្រុលពេក រហូតធ្វើឱ្យអ្នកអានធុញទ្រាន់ ដ្បិតមនុស្សភាគច្រើនមិនសូវចូលចិត្តអានអត្ថបទដែលគ្មានលាយមនោសញ្ចេតនា ជាពិសេសយុវវ័យ ។ ពេលខ្លះអ្នកនិពន្ធខ្លះ សរសេរបែបប្រដៅអ្នកអានតែម្តងក៏មានដែរ ។

ខ្ញុំបានអានសៀវភៅបែបប្រែសម្រួលច្រើនបំផុត ហើយខ្ញុំអានសៀវភៅចំណងជើងតែមួយ តែមានពីរភាសា (សៀវភៅដើមជាភាសាអង់គ្លេស និងសៀវភៅប្រែសម្រួលជាភាសាខ្មែរ) ដើម្បីផ្ទៀងផ្ទាត់អត្ថន័យដើម និងការប្រែសម្រួល ថា "តើអ្នកប្រែសម្រួលយល់ពីន័យដែលអ្នកនិពន្ធដើមចង់លើកឡើងដែរ ឬទេ ?" ខ្ញុំសង្កេតឃើញថានៅមានចំណុច

ខ្លះខ្វះខាត ពីព្រោះវាពាក់ព័ន្ធនឹងភាសា វប្បធម៌ បរិបទសង្គម និងកាលៈទេសៈសង្គម។ សៀវភៅប្រែសម្រួលខ្លះអានពិបាកយល់ ហើយអ្នកប្រែសម្រួល ក៏ពេលខ្លះពុំយល់ច្បាស់ពីន័យដើមដែរ។

តាមបទពិសោធនៃការអានរបស់ខ្ញុំកន្លងមក បូកផ្សំនឹងការផ្ទៀងផ្ទាត់អត្ថន័យនៃភាសាពីរ ខ្ញុំមើលឃើញតាមបទពិសោធជាក់ស្តែងថា "ការអានដែលត្រឹមត្រូវ ហើយឆាប់ប្រើការបាន គឺអ្នកអានគួរតែត្រូវស្វែងយល់ពីបរិបទវប្បធម៌ ឬបរិបទសង្គម ឬកាលៈទេសៈសង្គមសិន ពីព្រោះបើមិនបន្សុទ្ធទេ ចំណេះដឹងមួយចំនួនធំ គឺប្រើមិនបានផលទេ ក្នុងបរិបទសង្គមខ្មែរ"។ នេះគឺជាអ្វីដែលខ្ញុំធ្លាប់ឆ្លងកាត់តាមរយៈបទពិសោធរបស់ខ្ញុំប៉ុណ្ណោះ ហើយខ្ញុំក៏ពុំ

មានបំណងរិះគន់អ្នកប្រែសម្រួលដែរ តែខ្ញុំមានតែអរគុណចំពោះសេចក្តីប្រឹងប្រែងពាំនាំនូវចំណេះដឹងល្អៗពីបរទេសមកសាបព្រោះដល់សង្គមយើងទាំងមូល ។

*"No tears in the writer, no tears in the reader. No surprise in the writer, no surprise in the reader."*

*– Robert Frost*

# ៣១

## កម្ពុចសៀវភៅ គឺកម្ពុចជាតិ

“បើចង់បំផ្លាញវប្បធម៌នៃសង្គមមួយ អ្នកពុំចាំបាច់ដុតកម្ទេចសៀវភៅចោលឱ្យអស់ទេ ប៉ុន្តែគ្រាន់តែធ្វើឱ្យមនុស្សក្នុងសង្គមនោះលែងចង់អានសៀវភៅ គឺវាគ្រប់គ្រាន់ដើម្បីបំផ្លាញប្រទេសមួយទៅហើយ” ។

ការអាន មិនអាចធ្វើឱ្យយើងទាំងអស់គ្នាក្លាយទៅជាអ្នកដឹកនាំបានទេ ប៉ុន្តែវាអាចប្រាប់យើងថាតើបុគ្គលប្រភេទណាដែលយើងគួរដើរតាម ។ ការអាន គឺជាផ្នែកមួយនៃការអប់រំ ។ មនុស្សដែលមានការអប់រំខ្ពស់ ធ្វើឱ្យសង្គម

រីកចម្រើន ។ គ្រប់ប្រទេសដែលរីកចម្រើនខ្លាំងក្លានិងមានការអភិវឌ្ឍន៍ខ្លាំងទាំងអស់ គឺសុទ្ធតែដោយសារប្រជាជនក្នុងប្រទេសនោះមានចំណេះដឹងខ្ពង់ខ្ពស់ ។

ប្រទេសក្រីក្រ គឺជាភស្តុតាងបង្ហាញពីកម្រិតនៃការយល់ដឹងរបស់ប្រជាជនឬមនុស្សក្នុងសង្គម ។ វាមានន័យថា "ការយល់ដឹងរបស់ប្រជាជនកម្រិតត្រឹមណា នោះកម្រិតនៃការរីកចម្រើនសង្គម និងការអភិវឌ្ឍសង្គម ក៏ស្ថិតក្នុងរង្វង់នោះដែរ" ។ ជាសច្ចភាព ជាទ្រឹស្តីសកល និងការអនុវត្តជាសកលនៅគ្រប់ប្រទេសទាំងអស់ និងគ្រប់សង្គមទាំងអស់សុទ្ធតែប្រកាសឱ្យតម្លៃខ្លាំងលើការអប់រំ ។ លីក្វាន់យូ លើកឡើងថា "អភិវឌ្ឍន៍ខួរក្បាលរបស់ប្រជាជនសិង្ហបុរីមុន" ។

មេដឹកនាំអាហ្វ្រិកខាងត្បូង នែលសិន ម៉ែនដេឡា (Nelson Mandela) ថា “ការអប់រំ គឺជាអាវុធដ៏មានអានុភាពខ្លាំងក្លាបំផុត សម្រាប់ឱ្យយើងប្រើប្រាស់ដើម្បីផ្លាស់ប្ដូរពិភពលោកទាំងមូល” ។ អតីតប្រធានាធិបតីអាម៉េរិក បារ៉ាក់ អូបាម៉ា លើកឡើងថា “បើអ្នកមិនខិតខំប្រឹងប្រែងរៀនសូត្រទេ នោះមានន័យថាអ្នកបានបោះបង់ប្រទេសរបស់អ្នកចោលហើយ” ។ ចំពោះជីវិតមនុស្សវិញ តាមពិតមនុស្សខ្លះរស់នៅបានសុខ គឺដោយសារតែការប្រឹងប្រែងសង្វាតសិក្សា និងការប្រឹងអានសៀវភៅ ។

មនុស្សខ្លះ ដែលពុំសូវបានអាន គឺពួកគេស្ទាប់ស្ទើររៀងរាល់ថ្ងៃ ពីព្រោះគេជួបបញ្ហាជីវិតរាល់ថ្ងៃ ហើយគេត្អូញត្អែរនឹងជីវិតរាល់ថ្ងៃ ។ ចំណេះដឹងច្រើន តែងនាំឱ្យមាន

ឡាំ លីម

បញ្ហានៃជីវិតកាន់តែតិច ហើយចំណេះដឹងតិច គឺនឹងធ្វើឱ្យបញ្ហានៃជីវិតនឹងកាន់តែកើនច្រើនឡើង ។



អ្នកអានដែលចេះឱបក្រសោបពេលវេលា តែងដើរទៅមុខលឿនជាងអ្នកអានដែលចង់សប្បាយ និងបណ្តែតបណ្តោយខ្លួន ។ យើងមិនដឹងថាថ្ងៃស្អែក និងសេចក្តីស្លាប់ មួយណាមកដល់មុនទេ ។

# ៣២

## ការរៀន និងការគិត

“រៀនដោយពុំបានប្រើខួរក្បាលគិតគឺជារឿងខាតពេលវេលា ហើយគិតដោយពុំបានរៀន គឺជារឿងគ្រោះថ្នាក់” ។

រៀនដោយពុំបានប្រើខួរក្បាលគិត វាគង់អាចខុសហើយខុសព្រោះដោយសារតែកាលៈទេសៈ ។ ទ្រឹស្តីគ្រាន់តែជាអក្សរ ឬជាគំនិតនិយម តែនៅពេលអនុវត្តជាក់ស្តែង គឺត្រូវស្វាបស្ទង់កាលៈទេសៈជាក់ស្តែង ។ គិតដោយពុំបានរៀនគឺជាភាពស្រពិចស្រពិលពុំច្បាស់លាស់ និងគ្មានគោលការណ៍ត្រឹមត្រូវ ។ មនុស្សល្ងង់ពុំមែនដោយសារតែអប្បបញ្ញានោះ

ទេ តែដោយសារខ្វះការអប់រំ ។ មនុស្សកើតមកដូចគ្នា តែការអប់រំធ្វើឱ្យមនុស្សខុសគ្នា ពីព្រោះតែឱកាសនៃការទទួលបានការអប់រំ គឺពុំស្មើគ្នាឡើយ ។

គោលគំនិតរបស់ ស៊ី ជិនពីង គឺតម្រូវឱ្យយុវជននិងប្រជាជន ដាច់ខាតត្រូវតែជាអ្នករៀន និងត្រូវតែជាអ្នកគិត ពីព្រោះការរៀនគឺប្រៀបដូចជាការប្រឹងប្រែងអុំទូកបញ្ច្រាសទឹកដោយគ្មានថ្ងៃដែលខ្សែទឹកនាំទូកវិលថយក្រោយ ។ ប៉ុន្តែការរៀនដោយពុំគិត គឺប្រៀបដូចជាមនុស្សខ្វាក់ជិះសេះដោយមើលពុំឃើញអនាគតខាងមុខ ។ ទស្សនៈស៊ី ជិនពីង មានលក្ខណៈស្រដៀងនឹងទស្សនៈរបស់ ខុង ជឺ ដែលថា "បើបណ្ដោយឱ្យជនណាម្នាក់រៀនដោយគ្មានការគិត គឺជាការខាតពេលវេលា ហើយបើឱ្យជននោះគិតដោយគ្មានការ

រៀន គឺជាការខាតបង់ធនធានមនុស្ស" ។

និយាយរួម និយាយដោយខ្លី និយាយដោយសរុបអំពីទស្សនៈខាងលើ គឺចង់បង្ហាញថាត្រូវប្រឹងរៀន ហើយក៏ត្រូវប្រឹងគិតនូវអ្វីដែលបានមកពីការរៀនដែរ ដ្បិតការរៀនដែលនាំឱ្យបែកគំនិត គឺរៀនគិត រៀនសង្ស័យ រៀនឆ្លល់ រៀនបង្កើតអ្វីដែលថ្មី និងរៀនដោយពុំមែនចាំតែទន្ទេញសុទ្ធដូចសេកទេ (វិជ្ជាខ្លះតម្រូវឱ្យទន្ទេញច្រើនជាងគិត) ។ ទស្សនៈគំនិតណាមួយត្រូវឬខុសគឺអាស្រ័យលើកាលៈទេសៈជាក់ស្តែង ។ គំនិតមនុស្សអតីតកាលខ្លះ ពុំអាចប្រើការបានក្នុងកាលៈទេសៈបច្ចុប្បន្នទេ ។

ដូច្នេះ វាត្រូវការឱ្យអ្នករៀនចេះច្នៃប្រតិដ្ឋកែខៃបន្ថែមខ្លះ ។ ដើម្បីកែខៃគំនិតឱ្យប្រើការបន្តទៅបាន លុះត្រាណា

តែអ្នករៀនចេះគិត គិតដោយឈរលើស្ថានភាពជាក់ស្តែង គិតដោយឈរលើប្រយោជន៍ជាក់ស្តែង និងគិតដោយមានទស្សនវិស័យត្រឹមត្រូវ ។តើហេតុអ្វីរៀនដោយពុំបានប្រើប្រាស់ខួរក្បាលគិត គឺជារឿងគ្រោះថ្នាក់? មនុស្សដែលយល់ថាខ្លួនឯងចេះ គឺមានអញ្ញ និងមានអស្មិមានះពេញខ្លួន ។ ការសាបព្រោះចំណេះដឹង បើសាបព្រោះចំមនុស្សអាក្រក់ និងសាបព្រោះដោយពុំរើសយកមនុស្សល្អ គឺប្រៀបដូចជាការសាបព្រោះគ្រោះភ័យ និងព្យុះភ្លៀងដល់សង្គមទាំងមូល ។

*“To study without thinking is a waste. To think without studying is dangerous.” – Xi Jinping*

# ៣៣

## អ្នកនិពន្ធជួយជាតិបែបណា?

អត្ថបទវិចារណកថារបស់លោក លី ធាមតេង ដែលមានចំណងជើងថា "អ្នកវប្បធម៌ត្រូវជួយជាតិបែបណា?"

"វេលានេះ ប្រទេសជាតិកំពុងមានតែមហន្តរាយ អ្នកវប្បធម៌ទាំងអស់ រួមទាំងអ្នកនិពន្ធ កវី អ្នកអក្សរសាស្ត្រនេះផង ត្រូវប្រឈមមុខប្រឆាំងតទល់ពេញទំហឹង ដើម្បីជួយយឹតយោងប្រទេសជាតិ ។ តើយើងអ្នកនិពន្ធ កវី និងអ្នកអក្សរសាស្ត្រ ប្រឆាំងដោយមធ្យោបាយណា? (...) យើងអ្នកនិពន្ធកវីអ្នកអក្សរសាស្ត្រព្រមជាមួយអ្នកវប្បធម៌ទាំងអស់

មិនមែនប្រឆាំងដោយកម្លាំងកាយ កម្លាំងអាវុធ ពុះពារដូច យុទ្ធជនក្នុងសមរភូមិទេ គឺយើងត្រូវប្រឆាំងតាមផ្លូវប្រាជ្ញា តាមមធ្យោបាយចិត្តសាស្ត្រ តាមការដាស់តឿនសតិអារម្មណ៍ ជនរួមជាតិយើងឱ្យរឹងប៉ឹងស្មារតីស្ម័គ្រសាមគ្គីពួតកម្លាំងដូច ខ្លួនដែរ ទើបអាចរើខ្លួន ឬបម្រះខ្លួន វិលទាន់ពេលប្រយុទ្ធ ប្រកួតប្រជែងនឹងសត្រូវគ្រប់ទិសស្របនឹងយុទ្ធជនបាន” ។

អ្វីដែលខ្ញុំយល់ស្របនឹងលោក លី ផាមតេង ខ្លាំង បំផុត គឺប្រយោគដែលលោកបានលើកឡើងថា “ការតស៊ូ របស់ខ្មែរដែលមានចង្វាក់ស្របគ្នាល្អឥតខ្ចោះ គឺថាអ្នកច្បាំង នឹងអាវុធក៏ខំ អ្នកច្បាំងនឹងកិច្ចការក៏ខំ អ្នកច្បាំងនឹងផ្លូវចិត្ត ផ្លូវអប់រំក៏ខំព្រមគ្នា ទើបប្រទេសជាតិឆ្លងផុត ឬគេចផុតពី ជ្រោះមហន្តរាយបាន” ។ បើមើលពីសង្គមខ្មែរបច្ចុប្បន្ន ខ្ញុំ

បានឃើញថាខ្មែរមួយចំនួនតូចកំពុងតែមានគំនិតមើលបំណាំ ឬអំនួតពីរឿងជួយសង្គមតិច ឬជួយសង្គមច្រើន គិតពីសង្គមតិច ឬគិតពីសង្គមច្រើន...។ល។ មនុស្សដែលយល់បែបនេះ មិនមែនជាមនុស្សអាក្រក់ទេ តែជាមនុស្សដែលខ្សោយចំណេះដឹងចិត្តសាស្ត្រសង្គម ឬមនុស្សដែលមិនយល់ពីស្ថានភាពមនុស្សដទៃ ។

លោក សុទ្ធ ប៉ូលីន យល់ឃើញថា “លក្ខណៈនៃអសមត្ថភាពមនុស្សមាន ៣ប្រភេទគឺ៖ ១.មនុស្សអសមត្ថភាពក្នុងនយោបាយ, ២.មនុស្សអសមត្ថភាពក្នុងផ្លូវភេទ និង៣. មនុស្សអសមត្ថភាពក្នុងជីវិត”។ បើតាម មហាត្មៈ គន្ធី យល់ថាសង្គមមួយអាចរីកចម្រើនទៅបាន លុះត្រាណាតែមនុស្សក្នុងសង្គមស្គាល់តួនាទីខ្លួនឯងជាមុនសិន ។ តើជន

## សង្គមមានតួនាទីកាតព្វកិច្ចអ្វីខ្លះចំពោះសង្គម?

តួនាទី១៖ គឺកាតព្វកិច្ចចំពោះខ្លួនឯង ដោយត្រូវធ្វើយ៉ាងណា ឱ្យជីវិតខ្លួនល្អប្រសើរ កុំធ្លាក់អន្លង់អបាយមុខស្រីឬប្រុស ស្រា ល្បែង (ឆ្កួតជើងក្រាន) ។ បុរាណខ្មែរក៏បានផ្តាំទុកដែរថា "ខូចនឹងប្រុស អស់ព្រហ្មចារីយ ហើយខូចនឹងស្រី គង់ខ្ចីវិជ្ជា" ។

តួនាទី២៖ គឺកាតព្វកិច្ចចំពោះគ្រួសារ និងតួនាទី៣៖ គឺកាតព្វកិច្ចចំពោះសង្គមជាតិ ។ អសមត្ថភាពក្នុងជីវិតរបស់យុវជនក្នុងជីវិតយុវវ័យ គឺកំពុងតែសម្លាប់ទាំងខ្លួនឯង និងសម្លាប់ទាំងអនុជនជំនាន់ក្រោយ ។ សម្លាប់

ខ្លួនឯង  គឺមានន័យថាជីវិតនឹងរស់នៅក្នុងមនោសញ្ចេតនានិយមដោយភ្លេចគិតប្រឹងប្រែងរៀន ឬរៀនមិនចូលដោយសារតែជំងឺស្នេហា ឬជំងឺសង្គមនានា ។ សម្លាប់អនុជនជំនាន់ក្រោយ គឺមានន័យថាមនុស្សក្នុងជំនាន់យើងរស់បានមិនមែនដោយសារតែជុំបាយទេ តែដោយសារការតស៊ូប្តូរផ្តាច់របស់បុព្វបុរសក្នុងប្រវត្តិសាស្ត្រពីមុន ។ ពេលនេះ យើងក្នុងជំនាន់នេះ គឺមានតួនាទីបង្កើតប្រវត្តិសាស្ត្រថ្មីសម្រាប់អ្នកជំនាន់ក្រោយ ហើយបើយើងមិនប្រឹងពេលនេះ តើអ្នកជំនាន់ក្រោយនឹងមានសល់អ្វីខ្លះ ។

# ៣៤

## តម្លៃទឹកខ្មៅស្ថិតត្រង់សច្ចៈ

“តម្លៃទឹកខ្មៅស្ថិតត្រង់សច្ចៈ តែពុំមែនចុកមាត់បិទភ្នែកចាំធ្វើសេកស្រែកបន្ទរតាមអ្នកមានអំណាចបញ្ជាឱ្យសរសេរឡើយ” ។ កវី គង្គ ប៊ុនឈឿន លើកឡើងថា៖

ក្នុងមួយជីវិត ឥតប្រាថ្នាអ្វី ក្រៅពីសេរី ដើម្បី
សរសេរ បើនិពន្ធ តាមតែបញ្ជាគេ ដូចយក
ម្ជុលដេរ បិទមាត់ខ្លួនឯង ។

តម្លៃទឹកខ្មៅ នៅត្រង់សច្ចៈ ទោះគុកច្រវាក់ មិន

ញញើតក្រែង បើឃើញភ្លើងហើយ បែរជាថា
ផ្សេង គឺក្បត់ខ្លួនឯង មុនក្បត់អ្នកអាន ។

សុខចិត្តក្រីក្រ មិនទ្រដុល្លារ មិនលក់អក្ខរា
ដូរវីឡាឡាន មិនលូនឱនក្បាល ធ្វើមុំចង្រ្កាន
ទោះជាចាកឋាន ខកខានឃើញអង្គរ ។

បើទ្រាំនៅស្រុក ចុកមាត់បិទភ្នែក ព្រមធ្វើជា
សេក ចាំតែបន្ទរ ឬធ្វើអន្ទង ចាំតែទូងស្គរ មុខ
ជាលើផ្នូរ ក្មេងលេងខាកស្តោះ ។

រឿងខ្លះក្នុងសង្គម ប្រវត្តិសាស្ត្រខ្លះ ត្រូវបានអ្នកនិពន្ធ ដែលក្បត់អ្នកអាន សរសេរបំភ្លៃការពិត ។ ប្រព័ន្ធព័ត៌មាន ស្ថិតក្រោមអំណាចនយោបាយ ព័ត៌មានទាំងឡាយសរសេរ

បំភ្លៃមហាជន ខុសក្លាយទៅជាត្រូវ ក្លែងក្លាយក្លាយទៅជាពិត ។ ដូច្នេះ យុវជនដែលប្រឡូកក្នុងនយោបាយជំនាន់ក្រោយទាំងឡាយ គឺត្រូវមានសមត្ថភាពវែកញែកឱ្យច្បាស់មុននឹងកំណត់ថាអ្វីមួយត្រូវឬពិត ដ្បិតបើធ្វើដូច្នេះបានយើងនឹងក្លាយខ្លួនទៅជាមនុស្សដែលអ្នកនយោបាយបោកពុំបាន ។ វ្លាឌីមៀ ពូទីន (Vladimir Putin) ដែលជាមេដឹកនាំរុស្ស៊ី និយាយថា "ខ្ញុំមិនអានសៀវភៅទាំងឡាយណាដែលសរសេរដោយជនក្បត់ជាតិនោះទេ" ។

*"I don't read books by people who have betrayed the Motherland." – Vladimir Putin*

# ៣៥

## តិចមែន តែមានគុណភាព

អ្វីដែលខ្ញុំពេញចិត្តចំពោះមេដឹកនាំចិន តេងសៀវពីង បំផុត គឺប្រើមនុស្សតិចដែលមានចំណេះដឹងច្រើន មាន សមត្ថភាពខ្ពស់ មានការតាំងចិត្តមាំ ទៅជួយអ្នកក្រខ្សត់ ខ្សោយ ។ ជាទូទៅ មនុស្សលេងសើចច្រើន មិនចូលចិត្ត អ្នកធ្វើមែនទែនទេ ។ រីឯអ្នកមែនទែនក៏មិនអាចរួមការងារ ជាមួយមនុស្សឡេះឡោះបានដែរ ។ ខ្ញុំជឿថាមនុស្សខ្លាំង ៗ មនុស្សដែលមានសមត្ថភាព និងមនុស្សដែលអាចធ្វើឱ្យ ខ្លួនឯងរីកចម្រើនលឿន គឺមិនចេះធូររលុងចំពោះខ្លួនឯង

ឡើយ ។ លក្ខណៈនៃខ្មែរយើងខ្លះ គឺហាក់បីដូចបាត់បង់ព្រលឹងនៃមនុស្សប្រឹង មនុស្សពិតប្រាកដ មនុស្សនឹងធឹង មនុស្សនឹងន និងជាពិសេសស្មារតីនៃការប្រឹងប្រែង ។ តើអ្វីដែលយើងរំពឹងថានឹងបានមកដោយទទេ ៗ ឥតប្រឹងសោះ និងបំពេញកិច្ចការតាមតែអារម្មណ៍ តាមតែការចូលចិត្តរបស់ខ្លួន ដោយគ្មានវិន័យ ?

ពេលខ្ញុំហត់នឿយចិត្ត ថាមពលចិត្តទន់ខ្សោយ ខ្ញុំតែងតែចំណាយពេលវេលាដើរចូលក្នុងប្រាសាទអង្គរយក្រោមដើមឈើ ក្បែរធម្មជាតិ មានទឹក មានខ្យល់អាកាសបរិសុទ្ធ និងគ្មានមនុស្សមករំខានការស្មិងស្មាធិ៍ បំពេញថាមពល ។ ខ្ញុំចេះតែគិតថា "តើប្រាសាទដ៏មហិមានេះកើតឡើងដោយសារតែការធ្វើការលេង ៗ ឬការតែងប្តូរផ្តាច់សម្រេចសមិទ្ធិ

ផលឱ្យខានតែបាន?” អ្វីៗកើតឡើងសុទ្ធតែចេញពីការលះបង់។ ខ្ញុំដាក់សំណួរទៀតថា “មេដឹកនាំសម័យកសាងប្រាសាទអង្គរ តើមិនដឹងជាត្រូវមនុស្សឡេះឡោះប៉ុន្មាននាក់ស្លាប់ទេ?” អ្នកចេះ អ្នកប្រឹង អ្នកមែនទែន មានរឿងជាច្រើនដែលត្រូវធ្វើ តែអ្នកចង់តែសប្បាយ គឺរវល់តែនឹងឡេះឡោះឥតប្រយោជន៍។

នេះបានហៅថា “ចេះច្រើន រវល់ច្រើន។ រវល់ច្រើនហត់នឿយច្រើន។ ចេះច្រើន មើលឃើញរឿងវែងឆ្ងាយ។ ចេះតិច មិនខ្វល់ខ្វាយ គិតតែសប្បាយរហូតភ្លេចខ្លួន”។ បើស្រឡាញ់សង្គមពិត គឺត្រូវគិតរឿងប្រឹងអាន ប្រឹងរៀន។ ស្រឡាញ់អ្វីក៏ដោយ មិនថាស្រឡាញ់ស្រី ឬស្រឡាញ់ប្រុស ឬស្រឡាញ់ឪពុកម្ដាយទេ គឺត្រូវស្រឡាញ់ដោយទង្វើ តែ

មិនមែនស្រឡាញ់ត្រឹមតែសម្ដីឡើយ ។ អ្នកដែលរវល់លេង សប្បាយនឹងលេង ក៏បណ្ដោយទៅ ដ្បិតពេលណាទុក្ខមិនទាន់ មកដល់ មនុស្សខ្លះតែងយល់ថាគ្មានលំបាកទេ ។ ប៉ុន្តែ បុគ្គលដែលចេះគិត គឺជាអ្នកដែលចេះត្រៀមខ្លួនទុកមុន មិន ភ្លេចខ្លួន ភ្លើតភ្លើនឡើយ ។ ខ្ញុំមើលឃើញថា “គ្មានវិធីណា ដែលអាចធ្វើឱ្យយើងរីកចម្រើនបាន ក្រៅតែពីការអាន ការ ប្រឹងប្រែងរៀន ការមិនភ្លេចខ្លួន ការភ្ញាក់រឭកដឹងខ្លួនទាន់ មិនវង្វេង” ។ ជីវិត បើសម្រេចចិត្តថាធ្វើអ្វីហើយ ត្រូវធ្វើ ឱ្យមុត ធ្វើឱ្យស្រួច កុំធ្វើលេង ៗ កុំធ្វើតាមចិត្តចង់ កុំធ្វើតាម អារម្មណ៍ឱ្យសោះ ។



*ការអាន វាពិតជាមិនអាចឱ្យយើងគ្រប់គ្នាក្លាយទៅជាអ្នកដឹកនាំបាន ពិតមែន ប៉ុន្តែវាអាចប្រាប់យើងឱ្យដឹងថាតើបុគ្គលប្រភេទណា ដែលយើងគួរដើរតាម ។*

# ៣៦

## ប្រឹងអានយកចំណេះ ដើម្បីជ្រើសរើសមេដឹកនាំល្អ

"ការអាន វាពិតជាមិនអាចឱ្យយើងគ្រប់គ្នាក្លាយទៅជាអ្នកដឹកនាំបានពិតមែន ប៉ុន្តែវាអាចប្រាប់យើងឱ្យដឹងថាតើបុគ្គលប្រភេទណាដែលយើងគួរដើរតាម?"

បុគ្គលដែលអានច្រើនតែងចេះច្រើន ហើយមនុស្សដែលមានចំណេះដឹងច្រើនគឺជាមនុស្សគ្រោះថ្នាក់បំផុតសម្រាប់ជនអាក្រក់ ។ ចំណេះដឹងធ្វើឱ្យធ្វើយើងអាចវែកញែករវាងល្អនិងអាក្រក់ ត្រូវនិងខុស ។ ឬ តើមនុស្សបែបណាដែល

ជាមនុស្សល្អពិតប្រាកដ ឬតើមនុស្សប្រភេទណាដែលជាមនុស្សល្អបែបសម្ដែង ។ ក្នុងនាមជាម្ចាស់ប្រទេស ប្រជាជនមានតួនាទីធ្វើជាញញួរដំអ្នកដឹកនាំនយោបាយ ។ កុំអានដើម្បីធ្វើជាអ្នកខ្លាំង តែត្រូវអានដើម្បីគ្រប់គ្រងអ្នកខ្លាំង ។ មានសមត្ថភាពគ្មានអ្វីអស្ចារ្យទេ តែធ្វើជាម្ចាស់លើអ្នកមានសមត្ថភាពទើបអស្ចារ្យពិតប្រាកដ ។

# ៣៧

## ប្រវត្តិសាស្ត្រត្រូវសរសេរដោយអព្យាក្រិត្យ

អាល់ប៊ឺត អាញ្ញស្តាញ យល់ថា “ការរៀនពីប្រវត្តិសាស្ត្រ គួរតែរៀនដោយអព្យាក្រិតមិនលម្អៀង និងសិក្សាពីប្រភពជាក់លាក់ ដោយជៀសវាងការសិក្សាខុស ឬការកាឡៃបំភ្លៃប្រវត្តិសាស្ត្រ”។ មេដឹកនាំរុស្ស៊ី វ្ល៉ាឌីមៀ ពូទីន (Vladimir Putin) និយាយថា “ខ្ញុំមិនអានសៀវភៅទាំងឡាយណាដែលសរសេរដោយជនក្បត់ជាតិនោះទេ”។ ជនក្បត់ជាតិគឺមានន័យដល់អ្នកនិពន្ធប្រវត្តិសាស្ត្រទាំងឡាយណា ដែលសរសេរប្រវត្តិសាស្ត្រដោយមាននិន្នាការនយោបាយ ឬ

សរសេរដោយអគតិទាំងបួន ។ ស្ទើរតែគ្រប់ប្រទេសទាំងអស់ គឺពុំសូវមានសៀវភៅប្រវត្តិសាស្ត្រដែលសរសេរពីវីរជនឡើយ តែមានច្រើនសម្បើមណាស់ រាប់មិនអស់ឡើយ សៀវភៅដែលសរសេរពីអ្នកឈ្នះ ។ ឈ្នះជាស្តេច ចាញ់ជាចោរ ។

អធិរាជបារាំង ណាប៉ូលេឡុង និយាយថា "ប្រវត្តិសាស្ត្រ គឺសរសេរដោយអ្នកឈ្នះ" ។ ដូច្នេះ សូមប្រយ័ត្នចំពោះមនុស្សដែលអានសៀវភៅប្រវត្តិសាស្ត្រតែមួយក្បាល ។ ការសរសេរប្រវត្តិសាស្ត្រដ៏ត្រឹមត្រូវ គឺមិនត្រូវសរសេរដោយប្រើគំនិតអត្តនោម័តនិយមរបស់អ្នកនិពន្ធទេ តែត្រូវសរសេរពីព្រឹត្តិការណ៍ដែលបានកើតឡើងពិតប្រាកដ ។ សំណេរប្រវត្តិសាស្ត្រដែលបំភ្លៃការពិត វានឹងធ្វើឱ្យអ្នកអានជំនាន់ក្រោយៗ វង្វេងប្រវត្តិសាស្ត្រ ។ មនុស្សដែលវង្វេងប្រវត្តិសាស្ត្រ គឺ

នឹងជាន់ដានប្រវត្តិសាស្ត្រម្តងទៀត ។ ការជាន់ដានប្រវត្តិសាស្ត្រ គឺជាសោកនាដកម្មសង្គម ។

អ្នកនិពន្ធដែលស្រឡាញ់ជាតិ ត្រូវសរសេរលាតត្រដាងការពិតក្នុងសង្គម តែមនុស្សដែលស្រឡាញ់បក្ស គឺចូលចិត្តសរសេរបំភ្លៃការពិត ។ចុងក្រោយបំផុតល្អមើលតែមិនល្អស៊ី ។ ស្អាតកាយ តែចិត្តពិសពុល ។ រូបកាយនៅរស់ ប៉ុន្តែចិត្តគំនិតនិងឧត្តមគតិស្លាប់ ។ ធ្វើជាចិត្តល្អ តែរំពឹងផលប្រយោជន៍តបស្នង ។ មានគំនិតដែរ តែឱ្យគេគ្រប់គ្រង ។ ចេះដឹកនាំតែគ្មានអ្នកដើរតាម ។ រស់បាន តែឆាប់ស្លាប់ ។ មានឆន្ទៈល្អ ប៉ុន្តែបែរជាសុខចិត្តរស់ក្រោមឆន្ទៈមនុស្សអាក្រក់ ។ ស្រមៃចង់មានការផ្លាស់ប្តូរ ប៉ុន្តែបែរជាមានចិត្តកំសាកខ្លាចស្លាប់ទៅវិញ ។

# ៣៨

## កុំចង់សប្បាយក្នុងពេលខ្លួនក្រ

អ្នកអានដែលចេះឱបក្រសោបពេលវេលា តែងដើរទៅមុខលឿនជាងអ្នកអានដែលចង់សប្បាយនិងបណ្តែតបណ្តោយខ្លួន ។ យើងមិនដឹងថាថ្ងៃស្អែកនិងសេចក្តីស្លាប់ មួយណាមកដល់មុនទេ ។ ដូច្នេះត្រូវប្រឹងឱបក្រសោបពេលវេលាឱ្យបាន ហើយកុំបណ្តោយខ្លួនពេក ។ ចូរអានសៀវភៅដែលគួរអាន កុំខ្ជះខ្ជាយលុយកាក់ និងពេលវេលាឱ្យសោះ ។

សៀវភៅណាដែលនាំឱ្យយើងរីកចម្រើន ចូរអានសៀវភៅនោះមុន ។ សូមកុំចង់សប្បាយ ក្នុងពេលខ្លួនក្រ ។

ទស្សនៈដែលថា "ឱ្យតែសៀវភៅមិនមែនសុទ្ធតែល្អទេ" គឺជាទស្សនៈដែលខ្ញុំសំយោគចេញពីគំនិតបុគ្គលត្រាស់ដឹងជាច្រើនតាមរយៈការសិក្សាស្រាវជ្រាវ។ បើយើងក្រហើយឆោតទៀត គឺមិនដឹងទៅរកផ្លូវភ្លឺឯណាទេ ។ ខ្ញុំសុខចិត្តឱ្យអ្នកដទៃស្អប់ សុខចិត្តលំបាក តែខ្ញុំមិនជ្រើសរើសឈរនៅមួយកន្លែងទេ ។

សូមព្យាយាមអានរាល់ថ្ងៃ ពីព្រោះសៀវភៅខ្លះ គ្មានអ្នកអានយល់ទេ ។ សូមព្យាយាមគិតឱ្យយល់ ពីព្រោះគំនិតខ្លះ គ្មានអ្នកអាចគិតដល់ទេ ។ អ្នកអានច្រើន មិនប្រាកដថាចេះ តែអ្នកចេះច្រើន ភាគច្រើន គឺជាអ្នកអានច្រើន ។ អ្នកអានច្រើន មិនប្រាកដថាពូកែគិត តែអ្នកពូកែគិតច្រើនភាគច្រើន គឺជាអ្នកពូកែអាន ។ វាគឺជារឿងមិនសូវល្អ

ប៉ុន្មានទេ ដែលមនុស្សយើងមានខួរក្បាល តែបែរជាចាំតែយល់ស្របតាមអ្នកដទៃ ដោយមិនអានដោយខ្លួនឯង ឬចាំតែយល់ស្របតាមគំនិតអ្នកដទៃ ដោយមិនប្រឹងគិតឱ្យចេញជាគំនិតខ្លួនឯង ។

# ៣៩

## បដិវត្តន៍ផ្នត់គំនិតឆ្នាំថ្មី

"បញ្ហាពិបាកបំផុត គឺមិនមែនការផ្លាស់ប្ដូរសង្គមនោះទេ ប៉ុន្តែវាគឺជាបញ្ហានៃការផ្លាស់ប្ដូរខ្លួនយើង" ។

ប្រឹងប្រែងអភិវឌ្ឍន៍សមត្ថភាពខ្លួនឯងជាមុន គឺសង្គមនឹងអភិវឌ្ឍន៍តាមក្រោយ ។ប្រឹងប្រែងដោះស្រាយបញ្ហាលំបាកជាមុន នោះកិច្ចការងាយស្រួលនឹងត្រូវបានដោះស្រាយបានតាមក្រោយ ។ ចង់បានសង្គមល្អ គឺខ្លួនយើងត្រូវធ្វើខ្លួនជាមនុស្សល្អជាមុនសិន ហើយចង់បានសង្គមសាមគ្គី គឺយើងត្រូវចេះអភ័យទោសឱ្យគ្នាជាមុនសិន ។ បដិវត្តន៍ផ្នត់គំនិត

ឆ្នាំថ្មី គឺប្រឹងប្រែងរៀន ប្រឹងប្រែងអាន ទម្លាក់ភាពជាអ្នកមានអំនួតចេញ ទម្លាក់ភាពជាអ្នកចេះតែម្នាក់ឯងចេញ ទម្លាក់ភាពជាអ្នកមានសម្ដីបំពានចេញ និងទម្លាក់ភាពជាអ្នកប្រើសម្ដីអសុរោះចេញ ។ ហេតុអ្វីត្រូវធ្វើបែបនេះ? គឺពីព្រោះតែក្នុងនាមយើងជាមនុស្សម្នាក់ដែលមានឈាមជ័រក្នុងសង្គមមួយ អាក្រក់ឬល្អ សំខាន់ឱ្យតែចេះស្រឡាញ់គ្នា ។ ឱ្យតែយើងចេះស្រឡាញ់គ្នា ទុកចិត្តគ្នា និងមានសាមគ្គីផ្ទៃក្នុងអ្វីក៏យើងអាចធ្វើបានដែរ មិនថារឿងតូច ឬរឿងធំឡើយ ។

# ៤០

## ត្រូវប្រឹងរៀនដើម្បីជួយអ្នកដទៃ

“ការអានមិនអាចឱ្យយើងគ្រប់គ្នាក្លាយទៅជាអ្នកដឹកនាំបានទេ តែវាអាចប្រាប់យើងឱ្យដឹងថា តើបុគ្គលប្រភេទណាដែលយើងគួរដើរតាម ។ អ្នកអានទាំងអស់មិនអាចសុទ្ធតែនឹងក្លាយទៅជាអ្នកដឹកនាំទេ តែគ្រប់អ្នកដឹកនាំទាំងអស់សុទ្ធតែជាអ្នកអាន” ។

កុំអានដើម្បីតែធ្វើជាមនុស្សខ្លាំង តែត្រូវអានដើម្បីជួយអ្នកខ្សោយ ។ ឱ្យតែយើងមានឱកាសបានជួយអ្នកខ្សត់ខ្សោយ និងអ្នកទន់ខ្សោយ នោះគឺមានន័យថាយើង

បានក្លាយទៅជាអ្នកដឹកនាំរួចហើយ ។ អានច្រើន ចេះច្រើន ហើយអានតិច ចេះតិច ។ អ្នកអាន គឺជាអ្នកចេះដឹង ។ អ្នកចេះដឹងពិតប្រាកដ ពុំដែលចាត់ទុកអ្នកដទៃជាមនុស្សល្ងង់ឡើយ ។ កុំយល់ថាអ្នកដទៃល្ងង់ តែត្រូវប្រដៅខ្លួនឯងឱ្យបានល្អសិន ។

ចំណេះដឹងដែលបានបំពាក់នូវសីលធម៌ គុណធម៌ និងមនុស្សធម៌ គឺតែងបង្រៀនមនុស្សឱ្យចេះដាក់ខ្លួន ឱ្យចេះថ្លែងអំណរគុណ និងឱ្យប្រុងប្រយ័ត្ន ។ ទេពកោសល្យ គឺព្រះជាម្ចាស់ជាអ្នកប្រទានឱ្យយើង ។ ដូច្នេះចូរយើងចេះដាក់ខ្លួន ។ កិត្តិនាមល្បីល្បាញ គឺអ្នកដទៃជាអ្នកឱ្យ ។ ដូច្នេះចូរយើងចេះថ្លែងអំណរគុណ ។ រីឯភាពអំនួតអួតក្អេងក្អាង គឺយើងជាអ្នកបង្កើតឡើងដោយខ្លួនឯង ។ ដូច្នេះចូរយើង

ចេះប្រុងប្រយ័ត្ន ។ ចំណេះដឹងនឹងគ្មានតម្លៃ នៅពេលដែល

ចំណេះដឹងប្រាសចាកពីគោលការណ៍សីលធម៌ ។

ឡាំ លីម



ជំនាញក្នុងការគិតពិចារណា គឺសំខាន់ជាងជំនាញក្នុងការជឿ ។ គិតដោយគ្មានការរៀន គឺនឹងនាំឱ្យវង្វេងដោយគ្មានគោលការណ៍ ហើយរៀនគ្មានការគិតពិចារណា នឹងចាំតែជឿស៊ប់ដោយងងឹតងងុល ។

# ៤១

## ទុក្ខធំនៃសង្គម គឺមានមនុស្សអវិជ្ជាច្រើន

ព្រះពុទ្ធជាម្ចាស់សម្តែងថា “ការយល់ត្រូវនឹងឆ្ពោះទៅរកការនិយាយត្រូវ។ ការនិយាយត្រូវនឹងឆ្ពោះទៅរកការងារត្រូវ។ ការងារត្រូវ នឹងឆ្ពោះទៅរកការចិញ្ចឹមជីវិតត្រូវ។ ការចិញ្ចឹមជីវិតត្រូវ នឹងឆ្ពោះទៅរកការព្យាយាមត្រូវ។ ការព្យាយាមត្រូវ នឹងឆ្ពោះទៅរកការភ្ញាក់រឭកត្រូវ។ ការភ្ញាក់រឭកត្រូវ នឹងឆ្ពោះទៅរកបញ្ញាត្រូវ។ បញ្ញាត្រូវ នឹងឆ្ពោះទៅរកការរំដោះទុក្ខត្រូវ” ។

មនុស្សគ្រប់ៗរូបសុទ្ធតែមានទុក្ខ។ ជីវិត វាគឺជាទុក្ខ

នៅពេលណាដែលមនុស្សខ្វះបញ្ញា ។ បញ្ញាគឺជាអ្នករំលត់ទុក្ខរបស់មនុស្ស ។ ក្នុងទ្រឹស្តីពុទ្ធនិយម តែងនិយាយលើកឡើងពី "សីល សមាធិ បញ្ញា" ។ បើទោះបីជាយ៉ាងណាក៏ដោយការទទួលបានបញ្ញាមានវិធី និងមាគ៌ាជាច្រើនទៅតាមរបៀបផ្សេង ៗ ឬតាមគោលការណ៍សាសនានានា ឬអ្នកខ្លះអានសៀវភៅជាដើម ។

នៅក្នុងសង្គមខ្មែរ មនុស្សខ្លះនិងក្រុមខ្លះ តែងហាមាត់អះអាងនិយាយពីជនជាតិជ្វីពដែលចូលចិត្តអានសៀវភៅតែខ្លួនបែរជាប្រឹងតែស្តាប់ ប្រើតែត្រចៀក និងមិនសូវអានទៅវិញ ។ មនុស្សខ្លះ និងក្រុមខ្លះទៀត ហាមាត់និយាយពីសមាធិនិងវិបស្សនាកម្មដ្ឋាន តែខ្លួនឯងបែរជាប្រើសម្តីហិង្សាជេរប្រទេចទៅវិញ ។ ទុក្ខធំនៃសង្គម គឺមនុស្សអវិជ្ជាច្រើន ។

ទុក្ខធំផ្សេងទៀត គឺមនុស្សមានចំណេះ តែគ្មានសីលធម៌ ។

# ៤៣

## ដួងព្រលឹងសិល្បៈ

"អក្សរជាតិ គឺជាដួងព្រលឹងជាតិ ។ ដួងព្រលឹងជាតិ គឺមានន័យថាជាអត្តសញ្ញាណរបស់ជាតិ" ។

មនុស្សដែលបាត់ព្រលឹង គឺលែងស្គាល់ខ្លួនឯង ។ មនុស្សលែងស្គាល់ខ្លួនឯង គឺមានន័យថាមិនដឹងថាខ្លួនឯងជានរណា? មកពីណា? មានដូនតាជានរណា? និងមានបុព្វហេតុបែបណាក្នុងជីវិត? សិល្បៈ គឺជាចំណែកមួយនៃការធ្វើឱ្យសង្គមរីកចម្រើនឬអន់ថយ ។ សិល្បៈដែលបង្កប់ទៅដោយខ្លឹមសារអប់រំ គឺធ្វើឱ្យសង្គមរីកចម្រើន តែសិល្បៈ

ដែលមិនបង្ហាញនូវគំនិតអប់រំ វានឹងធ្វើឱ្យសង្គមឆាប់រលំ ។ គ្រប់សិល្បៈទាំងអស់សុទ្ធតែមានព្រលឹង ។ សិល្បៈចម្រៀង តែងមានព្រលឹងរបស់ចម្រៀង ហើយសិល្បៈតន្ត្រី តែង មានព្រលឹងរបស់តន្ត្រី ។ និយាយដោយខ្លី មនុស្សយំឬសើច ទន់ជ្រាយឬរឹងមាំ មានសីលធម៌ឬអសីលធម៌ គឺដោយសារតែ ព្រលឹងនៃសិល្បៈ ។ សិល្បៈអាចមិនមែនជាការពិត តែវា អាចធ្វើឱ្យក្លែងក្លាយក្លាយទៅជាពិតបាន ។

អ្នកនិពន្ធខ្មែរសម័យបុរាណ គឺតែងសម្រិតសម្រាំង ជ្រើសរើសពាក្យពេចន៍ក្នុងការសរសេរ ។ ការធ្វើបែបនេះ គឺជាការកំណត់អត្តសញ្ញាណ និងបញ្ចូលព្រលឹងទៅក្នុង សំណេរ ។ សំណេរដែលមានព្រលឹង គឺមិនងាយស្លាប់ទេ ។ សំណេរដែលរស់រវើក គឺធ្វើឱ្យអ្នកអានជក់ចិត្តជិតអារម្មណ៍ ។

ប៉ុន្តែសម័យនេះ ក្នុងពេលខ្លះ អ្នកខ្លះសរសេរឱ្យមនុស្សឆាប់បែកទ្រូង ឆាប់វង្វេងតាមអារម្មណ៍ សរសេរខ្វះមូលដ្ឋានទស្សនវិជ្ជា សរសេរដោយខ្វះមូលដ្ឋានគំនិត ដែលប្រកបទៅដោយទស្សនវិស័យវែងឆ្ងាយ និងសរសេរឱ្យមនុស្សជឿដោយស្លូងគំនិត (អ្នកនិពន្ធខ្មែរជាច្រើនរូបដូចជា៖ សុទ្ធប៉ូលីន, វ៉ាន់ឌី កាអុន....សុទ្ធតែទទួលឥទ្ធិពលពីទស្សនវិទូជាច្រើនរូប) ។ កុំភ្លេចពាក្យពេចន៍របស់មេដឹកនាំសិង្ហបុរី លីក្វាន់ យូ ផ្តាំថា “វប្បធម៌ជាដោគវាសនា” ។ ឬមានន័យថា វប្បធម៌សង្គមបែបណា វានឹងកំណត់វាសនាប្រទេសជាតិនោះបែបហ្នឹង” ។

*“We all know that art is not truth. Art is a lie that makes us realize the truth.” - Pablo Picasso*

# ៤៣

## អំណាចនៃការហ្វឹកហាត់

"យើងត្រូវតែរៀនធ្វើកិច្ចការងារណាដែលយើងគិតថាខ្លួនឯងមិនអាចធ្វើបាន ហើយដោយសារតែយើងមិនចេះទើបយើងត្រូវចេះគិតវិជ្ជមាននិងហ៊ានរៀនសាក" ។

យើងមិនអាចក្លាយជាចុងភៅដ៏ពូកែបាន ដោយត្រឹមតែយើងអានសៀវភៅវិជ្ជាធ្វើម្ហូបនោះទេ ។ យើងមិនអាចក្លាយជាអ្នកនេសាទដ៏ពូកែបាន ដោយត្រឹមតែអង្គុយអានសៀវភៅនេសាទនោះទេ ហើយយើងក៏នឹងមិនអាចក្លាយជាមនុស្សពូកែឬមនុស្សល្អបាន ដោយត្រឹមតែយើងអង្គុយអាន

ពីទ្រឹស្ដីមនុស្សពូកែឬអានពីសិក្ខាបទមនុស្សល្អដែរ ។ ប៉ុន្តែ ចូរធ្វើជាមនុស្សអស្ចារ្យ ដោយចាប់ផ្ដើមពីការធ្វើអំពើល្អ និង ធ្វើសកម្មភាពត្រឹមត្រូវពីឥលូវនេះតែម្ដងទៅ ។

# ៤៤

## ចេះគិត ពុំប្រាកដថាគិតត្រូវ

អាញស្តាញ ពោលថា "អ្នកដែលនិយាយថាការគិតមិនលំបាក គឺអ្នកនោះពុំដែលធ្លាប់បានគិតទេ" ។ មនុស្សមិនចេះអក្សរ មិនអាចអានអត្ថបទច្បាប់បាន ។ អ្នកអាចអានអត្ថបទច្បាប់បាន មិនប្រាកដថាអាចយល់បាន ។ អ្នកអាចយល់បាន មិនប្រាកដថាអាចវិភាគបកស្រាយបាន ។ អ្នកអាចវិភាគបកស្រាយបាន មិនប្រាកដថា បកស្រាយបានត្រឹមត្រូវ ។ គ្រប់យ៉ាងត្រូវតែឆ្លងកាត់ការគិតយ៉ាងស៊ីជម្រៅ ។ ដើម្បីអាចគិតបានស៊ីជម្រៅ គឺត្រូវប្រើថាមពលច្រើន ។

កាលបើប្រើថាមពលគិតច្រើន គឺតែងមានការលំបាក ។ អាញ្ញស្តាញ ត្រូវបានគេពន្យារពេលទទួលពានរង្វាន់ណូបែល ដោយសារកត្តាពីរគឺ៖

១.គណៈកម្មការគ្មានសមត្ថភាពអាចយល់បាន ពីគំនិត និងទ្រឹស្តីដែលអាញ្ញស្តាញបានរកឃើញ ។

២.ទ្រឹស្តីរបស់អាញ្ញស្តាញពេលនោះមិនទាន់អាចយកគំនិតនិងទ្រឹស្តីទាំងនោះមកអនុវត្តជាក់ស្តែងបាននៅឡើយ ។

ស្រដៀងគ្នាដែរ អត្ថបទបែបទ្រឹស្តីទស្សនវិជ្ជា វាតែងមានគំនិតបង្កប់ជ្រៅដែលមនុស្សធម្មតា ឬមនុស្សដែលខ្វះ

ការព្យាយាមអាន គង់មិនងាយអានយល់បានស្រួល ឬអាចត្រូវប្រើពេលអានច្រើនដង ។

នយោបាយតែងមានទីផ្សាររបស់នយោបាយ ។ ទីផ្សារនយោបាយរបស់គណបក្ស “ក” គឺបានរំដោះប្រទេសឱ្យរួចផុតពីសង្គ្រាម សុខសន្តិភាព និងការអភិវឌ្ឍន៍ ។ ទីផ្សារនយោបាយរបស់គណបក្ស “ខ” គឺអន្តោប្រវេសន៍ខុសច្បាប់របស់ប្រទេសជិតខាង អំពើពុករលួយ ការកាប់ព្រៃឈើ បក្សពួកនិយម និងអយុត្តិធម៌សង្គមរបស់មេដឹកនាំកាន់អំណាច ។ ទីផ្សារនយោបាយរបស់បក្ស “គ” គឺការសេរីនិយម និងការផ្លាស់ប្តូរការគិតរបស់ពលរដ្ឋ......គឺថាអ្នកនយោបាយ សុទ្ធតែបានស្ទង់មើលចិត្តសាស្ត្រនយោបាយរបស់ពលរដ្ឋ ហើយបន្ទាប់មកកំណត់ទីផ្សារគោលដៅថាតើ

ពលរដ្ឋប្រភេទណាដែលជាអតិថិជនរបស់ខ្លួន ។

មនុស្សដែលប្រឹងអាន ឬព្យាយាមអានសៀវភៅ ឬអត្ថបទទស្សនវិជ្ជា គឺជាយុវជនដែលចង់ធំដឹងក្តីមុនអាយុ ។ បើកាលណាមនុស្សចេះគិតហើយ នោះការគិតរបស់គេនឹងក្លាយទៅជាចាស់ទុំ ។ បន្ទាប់ពីការគិតចាស់ទុំ គឺពេលនោះហើយ ដែលគេនឹងក្លាយទៅជាមនុស្សចាស់ដោយស្វ័យប្រវត្តិ បើទោះបីអាយុនៅក្មេងក៏ដោយ ។ សូមឱ្យការខិតខំរៀនសូត្រស្ថិតនៅក្នុងបេះដូងយុវជនខ្មែររៀងរហូត ។

សូមឱ្យបញ្ញាស្នេហា និងមនោសញ្ចេតនាខុសឆ្គងទាំងឡាយ ជៀសទៅឆ្ងាយពីគំនិតយុវជនខ្មែរបណ្តោះអាសន្ន ។ សូមឱ្យក្តីស្រឡាញ់ និងមេត្តាករុណាស្ថិតក្នុងបេះដូងមនុស្សគ្រប់គ្នា ។ មានតែចំណេះដឹងរបស់ខួរក្បាលប៉ុណ្ណោះ ទើប

អាចនាំឱ្យយុវជនខ្មែរ មានសមត្ថភាពទប់ទល់នឹងយុទ្ធសាស្ត្រជាក់របស់សត្រូវខាងក្រៅបាន ។

# ៤៥

## ស្អាតហើយឆ្លាត

គ្មានបុគ្គលតាំងចិត្តព្យាយាមអានសៀវភៅឯណាដែលថានឹងមិនក្លាយទៅជាអ្នកឆ្លាតទេ ដ្បិតការបង្កើតកម្មនៃសេចក្ដីព្យាយាមសង្វាតអាននេះ វានឹងធ្វើឱ្យបុគ្គលនោះទទួលបាននូវផលនៃចំណេះដឹងនាពេលខាងមុខ ។ គ្មានមនុស្សមានវិជ្ជាឯណាដែលមិនគួរឱ្យស្រឡាញ់ទេ ដ្បិតចំណេះដឹង វាប្រៀបដូចជាម្សៅក្រែមលាបមុខ ផាត់ចិត្តខាងក្នុង ដុសខាត់ព្រលឹងបុគ្គលនោះឱ្យកាន់តែស្រស់សោភារកអ្វីប្រៀបផ្ទឹមពុំបាន ។

២.ក្នុងជីវិតរស់នៅជាក់ស្តែងមិនថាស្ថិតក្នុងកាលៈទេសៈបែបណាទេ ខ្ញុំតែងតែពាល់ត្រូវអារម្មណ៍រីករាយចេញពីការប្រឹងប្រែង ។ ខ្ញុំមិនតូចចិត្តទេ បើទោះបីជាបានផលតិចក្តី ឬបានផលច្រើនក្តី សំខាន់ "បានប្រឹងដោយខ្លួនឯង" ។ មិនថាការប្រឹងប្រែងសាងសេចក្តីល្អ ប្រឹងប្រែងទប់ខ្លួនពីអំនួត ប្រឹងប្រែងទប់ទល់នឹងអ្នកដទៃវាយប្រហារ ប្រឹងអាន ប្រឹងប្រែងសិក្សារៀនសូត្រ ប្រឹងប្រែងដុសខាត់ខ្លួនឯង ឃាត់ចិត្តមិនឱ្យខ្លួនលង់វង្វេងនឹងសេចក្តីអាក្រក់ ជឿជាក់លើកម្មល្អនឹងបានផលល្អ ព្រមទាំងចេះអត់ធ្មត់រង់ចាំទទួលផលនៃសេចក្តីល្អដែលពុំទាន់ប្រមូលផលនៅឡើយ ។

ក្នុងការរស់នៅប្រចាំថ្ងៃ ខ្ញុំតែងតែខិតខំរៀនសូត្រដោយតាំងចិត្តមាំថា "អាត្មាអញពិតជាមានចិត្តចង់ក្លាយទៅជាបុគ្គល

ល្អ រស់នៅត្រឹមត្រូវ រក្សាចិត្តជាបុគ្គលបរិសុទ្ធដោយមានអង្គ បរិសុទ្ធ ដោយកាយបរិសុទ្ធ ដោយសម្ដីបរិសុទ្ធ ដោយចិត្ត បរិសុទ្ធ និងដោយទង្វើបរិសុទ្ធ" ។ ខ្ញុំមិនដឹងទេថា "តើមាន បុគ្គលណាខ្លះ ដែលបានរស់នៅពាល់ត្រូវសេចក្ដីបរិសុទ្ធ ដែលចេញពីការសម្អាតចិត្ត មានសុចរិតភាពដ៏ថ្លាក្នុងចិត្ត និងឃើញសេចក្ដីស្អាតបរិសុទ្ធនៃខ្លឹមខាងក្នុង ស្រស់ស្អាត ជាងសម្បកកាយខាងក្រៅដ៏គួរឱ្យខ្ពើមរអើមនេះ ។ ក្នុងចិត្ត កម្រិតនេះ ខ្ញុំចេះតែមានអារម្មណ៍ខ្ពើមនូវសម្បកាយដែល ស្អាតតែខាងក្រៅ តែខាងក្នុងវិញស្មោកគ្រោករកកន្លែងដែល ប្រើចក្ខុមើលឃើញថាស្អាតពុំមានសោះ ។

ជីវិតមនុស្សរស់នៅចាញ់បោកការបោកប្រាស់ និង ចាញ់ភាពមាយានៃជីវិត គិតបានត្រូវខ្លះ តែពាល់មិនត្រូវ

កម្រិតចិត្តហួសពីថ្នាក់ប្រាជ្ញាឈ្លាវៃ ។ ចុងក្រោយ គ្មានបុគ្គលណាដែលស្រស់ស្អាតជាងអ្នករៀនសូត្រចេះដឹង ដែលមានវិជ្ជាជាអាវុធកម្ទេចយកឈ្នះភាពមាយានៃជីវិតទេ ។ គ្មានបុគ្គលណាដែលមានសម្រស់ស្រស់ស្អាត ជាងមនុស្សដែលបានបោសសម្អាតចិត្តរហូតដល់រួចផុតចិត្តដោយវិជ្ជានេះឡើយ ។ អ្នកខ្លាំង តែងរស់នៅផ្អោបខ្លួននឹងការប្រឹងប្រែងត្រូវ ។ វិញ្ញូជនតែងរស់នៅផ្អោបខ្លួននឹងគុណធម៌ ។ រីឯបុគ្គលអ្នកពាល់សច្ចៈក្នុងបច្ចុប្បន្នជាតិនេះ គឺរស់នៅផ្អោបខ្លួននឹងការពិតនៃជីវិត ដោយព្រមទទួលយកការពិតដោយឥតលក្ខខណ្ឌ ដុសខាត់ព្រលឹងរហូតដល់ចិត្តភ្លឺ ប្រៀបដូចព្រះច័ន្ទដែលជុំពពកខ្មៅបាំងមិនជិត ។




ការបន្សុទ្ធចំណេះដឹង និងព្យាយាមគិតពិចារណាថ្លឹងថ្លែងដោយ ខ្លួនឯង វាគឺជាដំណើររកឃើញនូវគតិបណ្ឌិត ។

# ៤៦

## ខ្ទីខ្ទួរក្បាលអ្នកចេះ

ខ្ញុំមានឃ្លាំង “សៀវភៅអេឡិចត្រូនិច” សម្រាប់ពិគ្រោះទស្សនៈ និងគំនិត ។ សរុបចំនួនសៀវភៅអេឡិចត្រូនិចប្រហែលជាជិត ២ម៉ឺនក្បាល ។ អានដល់ស្លាប់ក៏មិនអស់ដែរ តែសុំខ្ចីប្រើពេលនៅរស់សិន ។ បើខ្ញុំចង់ដឹងអ្វីមួយ ខ្ញុំចូលទៅអានភ្លាម រួចហើយគិតពីទស្សនៈម្ចាស់ដើម, រួចហើយគិតផ្ទុះបញ្ចាំងទស្សនៈជាមួយនឹងស្ថានភាពសង្គមមនុស្សសម័យថ្មី ។

រាល់អត្ថបទដែលខ្ញុំសរសេរទាំងអស់មាន២០% ជា

គំនិតរបស់អ្នកប្រាជ្ញ ហើយ៨០% វាជាគំនិតដែលខ្ញុំបានយកមកផ្ទៀប បន្សុទ្ធ និងផ្ទះបញ្ចាំងជាមួយស្ថានភាពជាក់ស្តែង ។ ដូច្នេះហើយ ទើបបានជាខ្ញុំកំណត់ថាឱ្យតែទស្សនៈ "វាអត់មានខុស ឬអត់មានត្រូវឡើយ" តែត្រូវមើលកាលៈទេសៈជាក់ស្តែង ។ សម្រាប់មនុស្សជាតិ ខុស ឬត្រូវ វាអាស្រ័យលើកាលៈទេសៈជាក់ស្តែង ។ ទស្សនៈដែលត្រូវវានឹងប្រើការបានផលល្អ តែបើវាខុសវិញ វានៅតែប្រើបាន តែមិនមែនពេលនេះ ។ គំនិតខ្លះត្រូវពេលនេះ តែខុសពេលខាងមុខ ឬទស្សនៈខ្លះទៀត វាខុសពេលនេះ តែអាចត្រូវពេលខាងមុខ ។

និយាយមែនទែន អ្វីក៏ខ្ញុំមិនចេះដែរ ដ្បិតខ្ញុំរៀនតាមអ្នកចេះប៉ុណ្ណោះ ។ ខ្ញុំឮអ្នកប្រាជ្ញនិយាយ ខ្ញុំក៏និយាយតាម

ខ្លះ បន្សុទ្ធខ្លះ វិភាគខ្លះ និងធ្វើយ៉ាងណាឱ្យវាត្រូវនឹងបរិបទសង្គម និងរបៀបរស់នៅរបស់មនុស្ស ។ បើគិតថាខ្ញុំចេះ ខ្ញុំនឹងអរគុណ ឬបើគិតថាខ្ញុំមិនចេះ ខ្ញុំនឹងញញឹម ហើយតបវិញថា “ត្រឹមត្រូវហើយ” ។ ខ្ញុំអត់ចូលចិត្តធ្វើជាមនុស្សចិត្តចង្អៀតទេ ។ អ្នកចេះធ្វើ កុំនិយាយយកត្រូវ តិះដៀលអ្នកទ្រឹស្តី ពីព្រោះបើមើលងាយទ្រឹស្តី គឺប្រៀបដូចជាមើលងាយគ្រូអ៊ីចឹង ។ ខ្ញុំរៀននៅសាលា ១២ឆ្នាំ បូកនឹងឧត្តម...សុទ្ធតែរៀនទ្រឹស្តី ។ គ្រូជាអ្នកលក់សីលធម៌ ហើយក្រៅពីសីលធម៌ គ្រូជាអ្នកលក់ទ្រឹស្តី តែពុំមែនជាអ្នកលក់ការអនុវត្តន៍ប៉ុន្មានឡើយ ។ គ្រូជាអ្នកបើកទ្វារ តែសិស្សចូលឬមិនចូល វាជារឿងរបស់សិស្ស ។

ម្តាយខ្ញុំធ្លាប់មានប្រសាសន៍ថា “សៀវភៅរបស់ខ្ញុំ វា

អាចដុតខ្លួនខ្ញុំឆេះសុស ពេលខ្ញុំស្លាប់ទៅ”។ ខ្ញុំតបថា “បើត្រឹមតែមួយរស់ ខ្ញុំមិនប្រឹងអានសៀវភៅទាំងនេះទេ ហើយនៅសុខ ៗ ហេតុអ្វីខ្ញុំត្រូវយកសំរាមដាក់ខ្លួន?” បើត្រឹមតែមួយរស់ មានមាគ៌ាល្អជាងនេះ ដែលអាចសំលៀងជីវិតបានល្អជាងនេះ ។ ចិត្តខ្ញុំជាចិត្តអ្នកសាសនា ហើយបើទោះបីជាខ្ញុំមិនគ្រងស្បង់ចីពរ ក៏កិលេសនិងតណ្ហារបស់ខ្ញុំមួយចំនួនបានឆេះសន្ធោសន្ធៅស្ទើររលីងទៅហើយ ។ ចិត្តខ្ញុំស្រាល ហើយខ្លួនក៏ខ្ញុំស្រាលដែរ ដ្បិតខ្ញុំពុំបានប្រឹងស្ពាយ “ចំណង់ និងតណ្ហា” ខ្លាំងពេកឡើយ ។ នៅលើលោកនេះអត់មានអ្នកប្រាជ្ញកើតឡើងទៀតទេ ប៉ុន្តែមានតែអ្នករៀនដែលប្រឹងរៀនរហូតដល់ក្លាយទៅជាអ្នកប្រាជ្ញ ។ មានឱកាសប្រឹង ក៏ចេះតែប្រឹងទៅ ។ បើចង់ធ្វើជាមនុស្សបែបណា ក៏ធ្វើទៅ តែសំខាន់ឱ្យតែជាមនុស្សល្អ ។ បើដល់ពេលស្លាប់

ក៏ស្លាប់ទៅ កុំស្តាយស្រណោះអ្វីឡើយ ។ ពេលខ្លះ ខ្ញុំចង់តែដកដង្ហើមធំនឹងជីវិតនេះ តែសុខចិត្តប្រឹង វាប្រសើរជាងដកដង្ហើមធំ ។

# ៤៧

## តើខ្ញុំជាអ្នកចេះ ឬអ្នកចែក?

ចំណេះដឹង វាងាយស្រួលយកសម្រាប់បុគ្គលដែលចេះប្រឹង ។ អ្នកចេះប្រឹងរៀន បើទោះបីជានៅទីណា ឬគ្មានឱកាសរៀនបែបណា ក៏មិនអវិជ្ជាដែរ ។ ការសិក្សាដ៏ត្រឹមត្រូវបំផុត គឺសិក្សាពីជីវិត និងការឆ្លងកាត់បទពិសោធជីវិតជាក់ស្តែង ។ នេះមិនខុសពីសម្តីអ្នកប្រាជ្ញរូបវិទ្យានាសតវត្សរ៍ទី២០, អាល់ប៊ឺត អាញស្តាញ ដែលនិយាយថា "គតិបណ្ឌិតគឺពុំមែនជាផលិតផលដែលកើតចេញពីសាលារៀនទេ តែវាទទួលបានពីការឆ្លងកាត់នូវបទពិសោធជីវិតជាក់ស្តែង" ។ បទ

ពិសោធជីវិតខ្ញុំខ្លី តែខ្ញុំបានប្រើពេលវះកាត់ខ្លួនឯង, សិក្សាលម្អិត, គិតយ៉ាងស៊ីជម្រៅពីអ្វីដែលខ្ញុំបានឆ្លងកាត់ មិនថាការងារ ស្នេហា គ្រួសារ ការសិក្សា។ គ្រប់យ៉ាងសុទ្ធតែជារឿងដែលសើចមិនចេញ ប៉ុន្តែគ្មានអាទិទេពណាដែលអស្ចារ្យអាចមករាំងខ្ញុំមិនឱ្យសើចបានឡើយ។

អ្វីដែលធ្វើឱ្យខ្ញុំហត់នឿយកាយជាងគេ គឺហត់នឹងចែករំលែកចំណេះដឹងដល់មនុស្សដែលខ្ជិលរៀន។ អ្វីដែលធ្វើឱ្យខ្ញុំហត់នឿយចិត្តជាងគេគឺហត់ចិត្តនឹងចរិតអ្នកចេះដឹងខ្លះ ដែលខ្ជិលស្រាវជ្រាវបន្ត តែចាំតែបន្ទរវាយប្រហារដោយខ្វះមូលដ្ឋានស្រាវជ្រាវ។ មនុស្សអវិជ្ជាខ្លះចាំតែវាយប្រហាររីឯអ្នកចេះដឹងខ្លះដែលមិនចេះស្រាវជ្រាវរៀនបន្ត គឺចាំតែច្រណែននិន្ទា។ ខ្ញុំចង់ចែករំលែកសៀវភៅសំខាន់ៗមួយ

ចំនួនដល់អ្នកទាំងអស់គ្នា ជាពិសេសអ្នកចេះដឹងខ្លះ ដែលខ្ជិលអានបន្ត ខ្ជិលអភិវឌ្ឍខ្លួនបន្ត និងជាពិសេសសម្រាប់បញ្ញវន្តដែលតែងតែយល់ថាខ្លួនឯងចេះគ្រប់គ្រាន់លើសគេហើយ ។

ខ្ញុំសប្បាយចិត្តនឹងចែករំលែកសៀវភៅទាំងអស់ដែលខ្ញុំមាន តែសំខាន់ឱ្យប្រាកដថានឹងយកទៅអាន យកទៅរៀនប្រឹងស្រាវជ្រាវដាក់ចិត្តដាក់កាយ ឬបើដាក់ជីវិតនឹងការសិក្សាស្រាវជ្រាវទៀត គឺរឹតតែល្អប្រសើរបំផុត ។ បើមនុស្សគ្រប់គ្នាជាមនុស្សឧស្សាហ៍រៀនមែន ឬឧស្សាហ៍ស្រាវជ្រាវមែន ឬជាមនុស្សដែលចេះឈឺចាប់មែន ម្ល៉ោះប្រហែលជាសង្គមមិនធ្លាក់ដល់ថ្នាក់នេះ ។ តាមការសិក្សាស្រាវជ្រាវរបស់ខ្ញុំ, ខ្ញុំបានមើលឃើញក្នុងរូបភាពទាំងមូលថា "មនុស្សជាតិរៀន

ត ៗគ្នា ច្នៃប្រតិដ្ឋ និវានុវត្តន៍ (Innovation) បង្កើតថ្មី ផ្ដុំសាច់ឈាមគំនិត ។ គំនិតខ្លះមានទស្សនវិទូចន្លោះពី៥នាក់ទៅ១០នាក់ និយាយដូច ៗគ្នា តែប្រើប្រាស់ពាក្យពេចន៍និងភាសាខុស ៗគ្នា (ខ្លឹមសារនៅដដែល)” ។ ហេតុអ្វីដូច្នេះ? វាដូច្នេះ ដ្បិតវាជាសច្ចភាពដែលមានតែមួយ ។ សរុបដោយខ្លី ខ្ញុំមិនមែនជាអ្នកចេះទេ តែជាអ្នកចែក ហើយជាអ្នកចែកដែលមានសមត្ថភាពប្រើប្រាស់ខួរក្បាលគិត បន្សុទ្ធ និងពិចារណាមុននឹងចែក ដ្បិតក្រែងលោវាខុសនឹងបរិបទវប្បធម៌សង្គម នាំឱ្យចលាចល ។ មនុស្សមិនមែនមានតម្លៃដោយសារតែចំណេះដឹងទេ តែដោយសារតែការប្រើប្រាស់ចំណេះដឹងឱ្យត្រឹមត្រូវ និងប្រកបទៅដោយសីលធម៌ ។

រឿងដែលខ្ញុំស្ដាយស្រណោះ ដែលបានរស់នៅក្នុង

សង្គម គឺស្គាល់ខ្លួនឯងដែលបានរៀនសូត្រពីទ្រឹស្ដីសាសនាស៊ីជម្រៅល្អម និងបានពិសោធចិត្តផ្ទាក់ពាល់ រហូតដល់ធម្មជាតិពិតរបស់មនុស្ស ។ បើខ្ញុំពុំមានចំណេះដឹងសាសនាស៊ីជម្រៅល្អមទេ ឬបើខ្ញុំពុំបានពិសោធចិត្តនេះទេ ម្ល៉ោះខ្ញុំប្រហែលជាប្រឹងប្រវេប្រវា គោងធ្វើខ្លួនជាអ្នកចេះដឹងប្រឹងរៀនយកចំណេះដើរសម្ដែងឫកពារបង្អួតគេឯងហើយមើលទៅ ។ អ្នកណាក៏ដោយ បើចង់បានអ្វី ក៏ប្រឹងដោយខ្លួនទៅ, ចង់ល្បី ក៏ប្រឹងឱ្យល្បីទៅ, ចង់បានមុខមាត់ ក៏ប្រឹងឱ្យបានមុខមាត់ទៅ, ចង់បានការសរសើរឱ្យតម្លៃពីអ្នកដទៃក៏ប្រឹងទៅ ដ្បិតគ្រប់យ៉ាងសុទ្ធតែអាចទៅរួច តែត្រូវដើរដោយផ្លូវត្រឹមត្រូវផង ។ គិតប្រយោជន៍រួម តែកុំគិតតែពីខ្លួនឯង ។ មានគេសួរខ្ញុំថា “តើត្រូវទៅរកទិញសៀវភៅដែលខ្ញុំសរសេរនៅទីណា”? ខ្ញុំតបថា “បើមានលុយ ចូរ

ទិញ តែបើគ្មានលុយទេ ចូររកផ្លូវចេញ ។ សៀវភៅរបស់ខ្ញុំ វាមាននៅក្នុងហ្វេសប៊ុករបស់ខ្ញុំគ្រប់អត្ថបទទាំងអស់ គ្មានលស់មួយអត្ថបទណាទេ  ទាំងសៀវភៅ “ប្រតិទិនទស្សនៈ ៣៦៥” និងសៀវភៅ “ប្រតិទិនទទ្សេនៈ ២២២ថ្ងៃ” ។

# ៤៨

## អ្នកចេះជំនាញដែលពូកែអាន

សៀវភៅខ្លះយើងសប្បាយនឹងអាន ។ សៀវភៅខ្លះយើងចូលចិត្តអាន ។ ប៉ុន្តែសៀវភៅខ្លះទៀត វាធ្វើឱ្យយើងមានចំណេះដឹងរីកចម្រើនទៅមុខ ។ តើលុយ ១០ដុល្លារជាង ឬសៀវភៅមួយក្បាល វាអាចជួយសង្គមបានយ៉ាងដូចម្តេច? សូមឱ្យការចំណាយលុយ ៨ដុល្លារ ទៅ១០ដុល្លារជាងលើសៀវភៅ វាក្លាយទៅជាលុយដែលអាចជួយសង្គ្រោះគ្រួសារ ជ្រោមជ្រែងខ្លួនឯងនិងអ្នកជំនាន់ក្រោយ ។

បើមិនប្រឹងអានដើម្បីខ្លួនឯងទេ តែយ៉ាងហោចណាស់

គួរអានដើម្បីបម្រើមនោសញ្ចេតនាសង្គម ។ ការអានច្រើន គឺមិនអាចធ្វើឱ្យមនុស្សគ្រប់គ្នាពូកែនោះទេ តែអ្នកដែលពូកែ តែងចូលចិត្តការអាន ។ អ្នករៀនគណនេយ្យ ហើយបើពូកែអានថែមទៀត គឺនឹងពូកែជាងគណនេយ្យករធម្មតា ។ អ្នករៀនច្បាប់ ហើយបើពូកែអានថែមទៀត គឺនឹងពូកែជាងអ្នកច្បាប់ធម្មតា ។ អ្នករៀនព័ត៌មានវិទ្យា ហើយបើពូកែអានថែមទៀត គឺនឹងពូកែជាងអ្នកព័ត៌មានវិទ្យាធម្មតា ។

មិនថាយើងរៀនជំនាញបច្ចេកទេសអ្វីនោះទេ ហើយបើពូកែអានថែមទៀត គឺនឹងពូកែជាងមនុស្សចេះជំនាញបច្ចេកទេសធម្មតា ។ ចុងក្រោយ មិនថាយើងរៀនបានតិចឬបានច្រើន, មានលុយច្រើន ឬលុយតិច, មានអ្នកដទៃស្គាល់ច្រើន ឬតិច គឺថាបើអានច្រើន នឹងកើនសុភមង្គលក្នុងចិត្ត

និងសន្តិភាពចំពោះខ្លួនឯងផង និងអ្នកដទៃផង ។

# ៤៩

## សរុបថាខ្ញុំនៅក្មេង

ពេលដើរមកដល់ភ្លាម ខ្ញុំសួរថា "ប្អូនទាំងពីរនាក់មានស្នេហាហើយឬនៅ?" ពួកគាត់សួរតបថា "ចុះបងឯងមុខចាស់ហើយ ដល់ណាបានមាន?" ខ្ញុំតបថា "ខ្ញុំនៅក្មេងហើយម្យ៉ាងខ្ញុំនៅរៀនទៀតផង"។

ប្អូនម្នាក់តបថា "មើលមុខអ្នកនៅវ័យក្មេង។ អាយុបងខ្ញុំរហូតជិត ១០ឆ្នាំហើយ តែនៅថាខ្លួននៅក្មេងទៀត។ បងឯងបានកាមេរ៉ាជួយទេ ហើយឮមកថាធ្លាប់បង្រៀនកុំព្យូទ័រទៀត។ សង្ស័យមុននឹងផុសរូបចូលហ្វេសប៊ុកម្តងៗ

មិនដឹងកែកន្លែងណាខ្លះទេ” ។

ពេលនិយាយរួចហើយ គាត់ងាកមុខចេញសើចយ៉ាងសប្បាយ ។ រីឯខ្ញុំនៅតែញញឹមដដែល បើទោះបីជាគាត់ថាខ្ញុំចាស់ក៏ដោយ ។ ខ្ញុំប្រាប់គាត់ថា “ឱ្យតែអ្នកប្រឹងរៀន និងប្រឹងអានសៀវភៅ គឺសុទ្ធតែនៅក្មេងទាំងអស់ ហើយខ្ញុំពុំដែលគិតថាខ្លួនឯងចាស់ផង” ។ អ៊ីចឹងដោយយោងទៅតាមទ្រឹស្តីនេះ សរុបដោយខ្លីថា “ខ្ញុំនៅក្មេង” ។ អ្នកអានអ្នករៀន តែងនៅក្មេងជានិច្ច តែអ្នកមិនរៀន មិនប្រឹងអាន គឺនឹងចាស់លឿនឆាប់ស្លាប់ ។

# ៥០

## សៀវភៅភាពជាអ្នកដឹកនាំដែលគួរអាន

សៀវភៅភាពជាអ្នកដឹកនាំដែលអាចប្រើបានស្ទើរតែទាំងស្រុងនៅក្នុងបរិបទសង្គមវិជ្ជាកម្ពុជា គឺគួរតែសៀវភៅ "*Xenophon's Cyrus the Great: the Arts of Leadership and War*" ឬជាសៀវភៅភាពជាអ្នកដឹកនាំផ្សេង ៗ ទៀតរបស់ Xenophon ដ្បិតវាជាគ្រឹះដំបូង ។ សៀវភៅភាពជាអ្នកដឹកនាំមួយទៀត គឺគួរអានសៀវភៅរបស់ស្ថាបនិកក្រុមហ៊ុន Panasonic គឺលោក ម៉ាសឹស៊ីតៈ (Matsushita Kōnosuke) ដែលជាសហគ្រិនជនជាតិជប៉ុន ។

យុវជនខ្មែរជំនាន់ថ្មីគួរតែព្យាយាមសម្រួចចរិតលក្ខណៈ កាយវិការ ឥរិយាបថ និងរបៀបគិតគូរ តាមរយៈការសិក្សាស្វែងយល់ពីភាពជាអ្នកដឹកនាំឱ្យបានច្រើនជាងជំនាន់ណាៗទាំងអស់ ។ ចង់កសាងខ្លួនឱ្យខ្លាំង គឺពុំអាចរស់នៅបណ្ដោយខ្លួនបានឡើយ ។ ចង់កសាងសង្គមឱ្យរុងរឿង ក៏មិនអាចយកមនុស្សដែលបណ្ដោយខ្លួនមកធ្វើបានដែរ ។ ខ្មែរបាត់បង់វិជ្ជានេះ រហូតដល់មិនដឹងថាតើធ្វើម៉េច បានអាចខ្លួនខ្លាំងបាន ។ មិនថាជាអ្នកចេះដឹងខាងបច្ចេកទេស ឬអ្នកចេះដឹងខាងសង្គមទេ ឱ្យតែខ្វះវិជ្ជាភាពជាអ្នកដឹកនាំនេះ គឺពិបាកនឹងអាចខ្លាំងបានយូរណាស់ ។

# ៥១

## ពិការអ្វីអាចពិការបាន តែកុំពិការចិត្តគំនិត

“បើយើងយកការដកដង្ហើមធំ និងសេចក្ដីខ្វល់ខ្វាយ គានតឹងទាំងឡាយមកដាក់លើសៀវភៅ នោះវាប្រសើរជាង ការទៅត្អូញត្អែរដាក់លើអ្នកដទៃ” ។

យើងតែងមានអារម្មណ៍ថាខ្លួនឯងគួរឱ្យអាណិតពីព្រោះ តែដៃទាំងពីររបស់យើងពោរពេញទៅដោយស្នាមរបួសនៃការ តស៊ូ រហូតដល់ថ្ងៃណាមួយ យើងបានជួបមនុស្សដែលគ្មាន សូម្បីតែដៃ ប៉ុន្តែគេនៅតែមានការតស៊ូ ។ យើងតែងតែមាន

អារម្មណ៍អាណិតខ្លួនឯង ព្រោះយើងពាក់ស្បែកជើងដាច់រហែក រហូតដល់ថ្ងៃមួយ យើងបានជួបនឹងមនុស្សដែលគ្មានសូម្បីតែជើង ប៉ុន្តែគេនៅតែអាចដើរទៅមុខបាន ។

ខ្ញុំជាមនុស្សខ្សោយមែន គឺខ្សោយព្រោះតែខ្ញុំជាមនុស្សដែលគ្មានសញ្ញាបត្របរិញ្ញា គ្មានសញ្ញាបត្រថ្នាក់អនុបណ្ឌិត គ្មានសញ្ញាបត្រថ្នាក់បណ្ឌិត និងគ្មានកិត្តិយសនៅក្នុងសង្គម តែខ្ញុំមិនមែនជាជនរងគ្រោះទេ ។ ខ្ញុំតែងតែស្តាប់ការត្អូញត្អែរពីមនុស្សដែលមានការអប់រំខ្ពស់ទាំងឡាយ និយាយពីបញ្ហាជីវិតប្រាប់ខ្ញុំជារឿយៗថា "ជីវិតគេលំបាក និងកំសត់ណាស់ ..." ។ ប៉ុន្តែចំពោះខ្ញុំវិញ ខ្ញុំឥតត្រូវការឱ្យនរណាម្នាក់អាណិតខ្ញុំទេ ហើយខ្ញុំក៏មិនចង់ទទួលងារជា "ជនរងគ្រោះ ឬជាជនគួរឱ្យអាណិត" ដែរ ។

សូមចងចាំថាការបានកើតមកជាមនុស្សលោកម្នាក់នឹងគេ (Human Beings) គឺសំណាងជាងសត្វលោកទាំងពួង (Beings) ពីព្រោះមនុស្ស គឺជាសត្វចម្រើននិយម ឬវឌ្ឍនិយម ឬ Being of Progressivism ។ ដូច្នេះ ចូរខិតខំប្រឹងប្រែងប្រព្រឹត្តទង្វើជាមនុស្ស (Human Doing) ដែលតែងតែដើរទៅមុខរកភាពចម្រើនរុងរឿងជានិច្ច ។




មនុស្សណាដែលប្រឹងអានច្រើនបំផុត តែបែរជាប្រើប្រាស់ខួរក្បាលគិតតិចតួចបំផុត គឺនឹងធ្លាក់ចូលទៅក្នុងទម្លាប់ខ្ជិលគិត ។

# ៥៣

## វិជ្ជា៧សម្រាប់យុវជន និងនិស្សិតភ្នាក់១

“[..] តួនាទីរបស់យើងដែលជាអ្នកជំនាន់ក្រោយនេះ មិនមែនត្រឹមតែប្រឹងដើម្បីរស់តែម្យ៉ាងទ តែត្រូវប្រឹងជួយត្រួសត្រាយផ្លូវ កសាងមាគ៌ា និងរៀបចំអនាគតសម្រាប់អ្នកជំនាន់ក្រោយ ព្រមទាំងបន្សល់ទុកនូវមរតកសម្រាប់អ្នកជំនាន់ក្រោយៗទៀត។ អ្នកជំនាន់មុនដែលល្អ គឺជាមនុស្សដែលចេះរៀបចំត្រួសត្រាយផ្លូវ ទុកឱ្យអ្នកជំនាន់ក្រោយដើរ ហើយដូនតាដែលគួរឱ្យគោរពបំផុត គឺជាអ្នកដែលបានបន្សល់ទុកនូវកេរដំណែលសម្រាប់អ្នកក្រោយៗ

តជំនាន់”។ នេះជាខ្លឹមសារមួយដែលសរសេរទុកក្នុងសៀវភៅ “ប្រតិទិនទស្សនៈ ២២២ថ្ងៃ”។ តើយុវជនត្រូវត្រៀមអ្វីខ្លះក្នុងតួនាទីជាអ្នកទទួលខុសត្រូវ?

ការទទួលខុសត្រូវ៣សំខាន់ៗ៖ ទី១ ទទួលខុសត្រូវចំពោះខ្លួនឯង, ទី២ ទទួលខុសត្រូវចំពោះគ្រួសារ, និងទី៣ ទទួលខុសត្រូវចំពោះសង្គមជាតិ។ ការទទួលខុសត្រូវនេះត្រូវរំលងចោលទី១និង ទី២ បើក្នុងកាលៈទេសៈជាតិជួបវិបត្តិដូចជាការឈ្លានពានរបស់បរទេស (សង្គ្រាម)។ តើត្រូវធ្វើបែបណាដើម្បីឱ្យយើងក្លាយទៅជាអ្នក ដែលចេះទទួលខុសត្រូវម្នាក់? ការទទួលខុសត្រូវ គឺមានន័យថាមិនបន្ទោសទៅលើអ្វីដែលនៅក្រៅខ្លួន បើទោះបីជាមានបញ្ហាខាងក្រៅមកញាំញីយ៉ាងណាក៏ដោយ។ ប៉ុន្តែ បើ

យើងជាមនុស្សដែលបន្ទោសនូវអ្វីដែលនៅក្រៅខ្លួនហើយ វាគឺមានន័យថាយើងមិនមែនជាមនុស្សដែលមានលក្ខណៈសម្បត្តិជាបុគ្គលចេះទទួលខុសត្រូវទេ ។ អ្នកដែលយល់ពីអំណាចដែលនៅក្នុងខ្លួនឯង គឺជាប្រភេទបុគ្គលដែលស្គាល់ខ្លួនឯងដល់ថ្នាក់ស៊ីជម្រៅខ្លាំងបំផុត ។ តើខ្មែរសម័យអង្គរជាប្រភេទមនុស្សដែលស្គាល់ខ្លួនឯង ឬក៏វង្វេងខ្លួនឯង ?

បច្ចុប្បន្ន យុវជនខ្មែរត្រូវការវិជ្ជាពីរយ៉ាងសម្រាប់ធ្វើឱ្យខ្លួនឯងខ្លាំង ។ វិជ្ជាទី១ គឺជាចំណេះដឹងខាងផ្នែកចិត្តវិញ្ញាណ ឬចំណេះដឹងថ្នាក់ពាល់ខាងផ្នែកសាសនា (Spirituality Knowledge) ដ្បិតចំណេះដឹងបែបនេះ វាជាចំណេះដឹងតែមួយគត់ដែលអាចធ្វើឱ្យមនុស្សអាចស្វែងរកខ្លួនឯងឃើញថា "តើខ្ញុំពិតប្រាកដ ជានរណា" ។ ចំពោះ

ខ្ញុំ ខ្ញុំហ៊ាននិយាយថា “មនុស្សខ្លាំងមិនមែនដោយសារតែសម្បកកាយនេះទេ តែដោយសារតែវិញ្ញាណ ព្រលឹង និងចិត្តដែលមានអំណាចខាងក្នុង” ។ វិជ្ជាទី២ គឺជាវិជ្ជានៃភាពជាអ្នកដឹកនាំ (Leadership) ដ្បិតចំណេះដឹងបែបនេះវាជាមូលដ្ឋាននៃការដឹកនាំខ្លួនឯងទៅភាពជោគជ័យ និងប្រមូលមនុស្សឱ្យចេះសាមគ្គីគ្នា ។

វិជ្ជានៃភាពជាអ្នកដឹកនាំ ឱ្យតែបុគ្គលណាមានវិជ្ជានេះ គឺបុគ្គលនោះនឹងក្លាយទៅជាមនុស្សមានអំណាច ។ អំណាចដែលអ្នកដទៃគោរពកោតខ្លាច ឱ្យតម្លៃ និងស្រឡាញ់រាប់អាន បើទោះបីជាយើងមានឋានៈត្រឹមជាមនុស្សសាមញ្ញក៏ដោយ ។ សូម្បីតែពពួកមេសាសនាធំៗ និងអ្នកដឹកនាំខាងចិត្តវិញ្ញាណ ក៏ត្រូវតែមានវិជ្ជានេះផងដែរ ដ្បិតបើគ្មានវិជ្ជា

នេះទេ គឺមិនអាចដឹកនាំអ្នកដទៃឱ្យដើរតាមខ្លួនបានឡើយ។ សម្រាប់បុគ្គលណាម្នាក់ដែលមានឋានៈ និងមានតួនាទីក្នុងសង្គមរួចហើយ, បើមានវិជ្ជានេះទៀត គឺនឹងធ្វើឱ្យការងាររីកចម្រើនទៅមុខ មានអំណាច មានឥទ្ធពលក្នុងចំណោមមនុស្ស។ រឿងចុងក្រោយរបស់យុវជនដែលមានឆន្ទៈត្រូវតែជ្រើសរើសគ្រូម្នាក់ជាមគ្គុទ្ទេសក៏មកបង្ហាញផ្លូវដើរ ដ្បិតបុគ្គលណាដែលមានអ្នកប្រាប់ផ្លូវដើរ គឺដើរលឿនជាង ប្រៀបដូចជាក្សត្រខ្លាំងដែលគ្រប់គ្រងអាណាចក្រ អត់ទីប្រឹក្សាពុំបានអ៊ីចឹងដែរ។ នេះជាគោលការណ៍ដឹកនាំតាមបែបព្រាហ្មណ៍សាសនា។ គ្រូខ្លាំងតែងនាំយើងឱ្យដើរលឿន តែបើគ្រូខ្សោយវិញ គឺអាចនាំគ្រោះថ្នាក់ដល់យើងដែរ។

# ៥៣

## អំណាន និងសំណេរ

មនុស្សម្នាក់មានតម្លៃ ឬគ្មានតម្លៃ គឺពុំស្ថិតនៅលើសម្បកកាយខាងក្រៅទេ ប្រៀបដូចជាសៀវភៅមួយក្បាលដែលមានតម្លៃ ឬគ្មានតម្លៃ គឺពុំបានកំណត់ទៅលើតម្លៃជាទឹកលុយប៉ុន្មាននោះទេ ប៉ុន្តែវាស្ថិតនៅលើខ្លឹមសារសៀវភៅខាងក្នុង ។ សៀវភៅខ្លះថ្លៃ តែថោក ។រីឯសៀវភៅខ្លះទៀតថោក តែថ្លៃ ហើយក៏មានសៀវភៅខ្លះថ្លៃហើយ ថែមទាំងមានតម្លៃទៀតផង ។ សៀវភៅខ្លះ សប្បាយអាន តែអានមិនបានអ្វីសោះ ។ សៀវភៅខ្លះ មិនសប្បាយអានទេ តែបើ

បានអានហើយ គឺនឹងមានប្រយោជន៍ទៅថ្ងៃក្រោយ ។

អ្នកដែលអវិជ្ជាក្នុងសម័យនេះ គឺមិនមែនជាបុគ្គលមិនចេះអក្សរទេ តែជាមនុស្សដែលមិនចូលចិត្តអានសៀវភៅ និងមិនសូវរៀនសូត្រជាប្រចាំ ។ អ្នកខ្លះចេះអក្សរ តែមិនអានសៀវភៅទេ ។ អ្នកខ្លះអានសៀវភៅដែរ តែមិនអានដោយត្រឹមត្រូវបែបស៊ីជម្រៅទេ ។ ជាធម្មតា អ្នកសរសេរ ឬអ្នកនិពន្ធ គឺពុំអាចកាត់ផ្ដាច់ខ្លួនឯងពីការអានបានឡើយ ។ ការយល់បែបនេះត្រូវដែរតែនៅមិនទាន់ពេញលេញនៅឡើយទេ ដ្បិតអ្នកសរសេរឬអ្នកនិពន្ធពុំគួរធ្វើខ្លួនត្រឹមតែជាអ្នកអានម្យ៉ាងទេ តែត្រូវរស់នៅឱ្យលើសពីការអាន ។ តើអ្វីជាការអានដើម្បីចេះ និងអានដើម្បីសរសេរ ឬអានក្នុងន័យស្រាវជ្រាវ?

ស្មេរដែលអាន រួចហើយយកមកសរសេរឡើងវិញ គឺ

ពេលខ្លះស្មើនឹងស្នេរដែលធ្វើ "Book Review" ។ "Book Review" គឺមានន័យថាជាការបង្ហាញចំណាប់អារម្មណ៍អំពីសៀវភៅណាមួយដែលខ្លួនបានអានចប់ ឬគំនិតដែលខ្លួនបានអានពីសៀវភៅណាមួយ ។ ស្នេរពិតប្រាកដពុំត្រូវសរសេរក្នុងកម្រិត Book Review ទេ ប៉ុន្តែគួរតែជាអ្នកអានដែលស្ថិតក្នុងកម្រិតបែបស្រាវជ្រាវវិញ ។ មិនមែនឱ្យអ្នកអានសៀវភៅ គឺអាចក្លាយទៅជាស្នេរបានទេ ហើយមិនមែនឱ្យតែក្លាយទៅជាស្នេរហើយ អាចយល់ដឹងពីសង្គមវិជ្ជា ឬបរិបទវប្បធម៌សង្គមបានឡើយ ។ ចំណេះដឹងសង្គមវិជ្ជា វប្បធម៌បរិបទរស់នៅផ្តត់គំនិតសង្គមគឺជារឿងចាំបាច់សម្រាប់ស្នេរ ។ ស្នេរពិតប្រាកដ គឺត្រូវបំពាក់ឱ្យខ្លួនឯងនូវចំណេះដឹងបែបស្រាវជ្រាវ ជាពិសេសអំណានតាមបែបស្រាវជ្រាវ ។ ការអានដើម្បីចេះ យកទៅអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ គឺ

វាខុសពីការអានយកមកសរសេរជាសៀវភៅ ។

# ៥៤

## រឿងសៀវភៅឈើចាប់

កើតក្នុងគ្រួសារខ្មែរ ត្រកូលកសិករ ក្រៅតែពីធ្វើស្រែចម្ការចិញ្ចឹមក្រពះ គឺមានតែមុខរបរដាក់ទ្រូ ដាក់បង្កៃយកត្រីចិញ្ចឹមឆ្នាំង ។ ក្រៅពីនេះ ខ្ញុំតែងតែប្រឹងប្រែងរៀននៅតាមសាលាវត្ត ។ នៅក្នុងសហគមន៍របស់ខ្ញុំ គ្មានសាលារៀនឡើយ តែមានតែយកវត្តអារាមជាសាលារៀន ។ ក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៩៥ នៅទីនេះមានទាហានដើរ ដៃប្រដាប់ដោយកាំភ្លើង ។ ពេលខ្ញុំជួបទាហានទាំងនោះម្តងៗ ខ្ញុំចេះតែភ័យខ្លាច ។ ក្មេងៗក្នុងភូមិទាំងអស់ ហើយនិងខ្ញុំ

ចេះតែនាំគ្នាប្រឹងប្រែងរៀនបណ្ដើរ ជួយការងារឪពុកម្ដាយបណ្ដើរ រហូតដល់ចប់ថ្នាក់បឋមសិក្សា ។ បន្ទាប់មក យើងក៏បានបន្តដល់អនុវិទ្យាល័យ ។

ខ្ញុំជាក្មេងប្រុសម្នាក់ដែលសុភាពរាបសារ, ស្ងប់ស្ងាត់, និងចេះតែញញឹមម៉្យាងគត់ ។ ពេលខ្ញុំញញឹមម្ដង ៗ គ្រប់គ្នាមើលគ្រាប់ភ្នែកខ្ញុំមិនឃើញទេ ។ មិត្តភក្ដិស្របាល ៗ គ្នា តែងចូលចិត្តលេងជុំគ្នា តែខុសតែខ្ញុំម្នាក់ឯងដែលចូលចិត្តកាន់សៀវភៅ ។ សៀវភៅដែលខ្ញុំចូលចិត្តកាន់ជាងគេគឺជាប្រភេទសៀវភៅភាសិត, សុភាសិត, ពាក្យចាស់, ច្បាប់ទូន្មានខ្លួន, និងក្បួនយុទ្ធសាស្ត្រ ដែលខ្មែរបុរាណបានសរសេរបន្សល់ទុក ។ ដៃកាន់សៀវភៅ រឺមាត់ប៉ផ្ទូច ៗ តែម្នាក់ឯង ។ អ្នកខ្លះឃើញខ្ញុំអង្គុយនៅក្រោមដើមក្រសាំងឬដើមស្វាយ ហើយនាំគ្នា

គិតមកខ្ញុំថាខ្ញុំពិបាកចិត្ត ។ អានបណ្ដើរ ទន្ទេញឱ្យចាំមាត់បណ្ដើរ ។ តវិយាបថបែបនេះ ខ្ញុំបានរក្សារហូតដល់ចប់ថ្នាក់អនុវិទ្យាល័យ ។

ដល់ថ្នាក់វិទ្យាល័យ ខ្ញុំពេញវ័យពេញរូបរាង ។ ខ្ញុំចូលចិត្តញញឹម ហើយភ្នែកខ្ញុំនៅតែតូចដដែល ។ រហូតដល់ថ្នាក់ទី១១ ខ្ញុំអានសៀវភៅភាសិត សុភាសិត និងពាក្យចាស់អស់ជាច្រើនក្បាល ហើយសៀវភៅខ្លះខ្ញុំបានទន្ទេញរហូតដល់រត់មាត់ក៏មាន ។ ខ្ញុំមិនសូវចូលចិត្តនិយាយទេ តែបើនិយាយម្ដងៗ ខ្ញុំចូលចិត្តលើកពាក្យសុភាសិតមកភ្ជាប់ន័យ ។ ពេលរដូវប្រាំង ខែច្រូតស្រូវ ខ្ញុំពូកែនិយាយជាងគេក្នុងចំណោមអ្នកច្រូតរួមគ្នាទាំងអស់ ។ អ្នកខ្លះបានចំអកឱ្យខ្ញុំថា “មនុស្សពូកែព្រោកប្រាជ្ញ” ។ មែនទែនទៅ ខ្ញុំមិនមែន

ជាមនុស្សចូលចិត្តនិយាយស្តីច្រើនទេ តែបើនិយាយហើយ គឺមិនចេះនិយាយមួយម៉ាត់ចប់ ។ ជីវិតជាអ្នកស្រែផង អ្នកសិក្សាផង គឺមានតែប្រឹងឱ្យមែនទែនហ្នឹងហើយ ។

ដល់ថ្នាក់ទី១២ ខ្ញុំឃើញមិត្តស្រុកស្រែរបស់ខ្ញុំជាច្រើន សុទ្ធតែមានគូរនិងមានសេចក្តីស្នេហា ។ តាំងពីតូចដល់ធំ ខ្ញុំមិនដឹងថាអ្វីទៅជាស្នេហាទេ ដ្បិតស្គាល់តែចប ខ្សែគោ រនេះ កណ្តៀវច្រូតស្រូវ និងសៀវភៅ ។ អ្នករៀនសូត្រស្រុកស្រែ ស្គាល់តែប្រឹងធ្វើស្រែ និងប្រឹងរៀន ហើយបើនិយាយស្តីជាមួយមនុស្សស្រីវិញ គឺប្រើតែហេតុផល ។ ប៉ុន្តែពេលវេលាវិវត្តន៍ទៅមុខជានិច្ច ។ សត្តនិករទាំងឡាយសុទ្ធតែមានគូទៅតាមលក្ខណៈធម្មជាតិ ។ ដល់វេនខ្ញុំធំពេញវ័យកំលោះ ក៏ចេះតែមានអារម្មណ៍ឆ្ងល់នឹងជីវិតនេះ ។ ឱ្យតែ

ពេលវេលាមកដល់ វាប្រៀបដូចជាព្រហ្មលិខិតអ៊ីចឹង ។ មិត្តរបស់ខ្ញុំម្នាក់បានមកនិយាយជាមួយខ្ញុំពីរឿងស្នេហាក្នុងវ័យសិក្សានេះ ។ គាត់បានប្រាប់ខ្ញុំថា "មាននារីទីក្រុងម្នាក់ដែលរៀនថ្នាក់ជុំខ្ញុំ ចេះតែលួចសម្លឹងមើលមកខ្ញុំ ហើយពេលខ្លះនាងតែងតែលួចថតរូបរបស់ខ្ញុំផងក៏មាន" ។ ខ្ញុំចេះតែឆ្ងល់ថាតើនាងថតធ្វើអី? បើនិយាយពីខ្មៅ ខ្ញុំគឺខ្មៅជាងគេក្នុងចំណោមមិត្តរួមថ្នាក់ ។ បើនិយាយពីភ្នែក គឺភ្នែកខ្ញុំតូចជាងគេក្នុងចំណោមមិត្តរួមថ្នាក់ ។

បានឮថាមាននារីលួចសម្លឹងខ្ញុំ ហើយថែមទាំងលួចថតរូបខ្ញុំទៀត [...] វាធ្វើឱ្យខ្ញុំចេះតែឆ្ងល់ថាតើហេតុអ្វី? ចុងក្រោយខ្ញុំបានដឹងចម្លើយពីមិត្តនារីម្នាក់ទៀតថា "នាងលួចចាប់អារម្មណ៍ខ្ញុំ" ។ ពេលដឹងដូច្នោះ ខ្ញុំនៅតែរក្សាចិត្ត

ធម្មតា ដ្បិតខ្ញុំជឿថាការសិក្សាអប់រំគឺសំខាន់ជាង ។ រហូតដល់មួយរយៈមក  ខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងទាល់សោះ ពីព្រោះថាមានមិត្តភក្តិទាំងស្រីទាំងប្រុសចេះតែនាំគ្នាបង្អាប់នាងនិងខ្ញុំ ។ រហូតដល់ដំណាក់កាលមួយ ខ្ញុំហាក់បីដូចជាលង់ស្រឡាញ់នាងផង  និងអាណិតនូវចិត្តមេត្តារបស់នាងចំពោះខ្ញុំផង ។  ដំណាក់កាលនេះ  ចាត់ទុកថាខ្ញុំនិងនាងបានយល់ចិត្តថ្លើមគ្នា៦០%ទៅចុះ ។  រហូតដល់យូរ ៗ ទៅក្តីស្រឡាញ់របស់ខ្ញុំចំពោះនាងចេះតែរីកធំទៅ ៗ ដោយគ្មានមូលហេតុ ។ នេះបានថាស្នេហាឥតមានហេតុផលមែន ។ ពីមួយខែទៅមួយខែ ខ្ញុំមិនដឹងថាត្រូវយកចិត្តទុកដាក់ចំពោះនាងបែបណាទេ តែចេះតែជូនសៀវភៅដែលខ្ញុំធ្លាប់បានអានទៅនាងជារៀងរាល់ខែ ។  ពេលនាងទទួលយកសៀវភៅនាងតែងតែញញឹមរហូត ។ អ្វីដែលខ្ញុំសប្បាយចិត្តជាងគេ

គឺបានឃើញស្នាមញញឹមរបស់នាង ។

ចេញពីត្រកូលកសិករ ជាអ្នកស្រែសុទ្ធសាទ ។ ខ្ញុំធ្លាប់តែឮគេនិយាយថា "អ្នកស្រែស្មោះស្នេហ៍ណាស់" ។ គិតចុះគិតឡើង ក្ដីស្រឡាញ់ចេះតែរីក ហើយចំនួនសៀវភៅដែលខ្ញុំជូននាងក៏កាន់តែច្រើន ។ ខ្ញុំជាអ្នកស្រែមែន តែខ្ញុំសប្បាយចិត្តខ្លាំងណាស់នៅពេលដែលមនុស្សស្រីខ្ញុំស្រឡាញ់អានសៀវភៅដែលខ្ញុំជូននាង ។ វ័យសិក្សា ជួបស្នេហ៍ដំបូងដែលចាស់ៗថាមិនងាយបានដល់ថ្ងៃរៀបការទេ ។ ខ្ញុំមិនជឿ ដ្បិតនាងតែងតែសម្ដែងនូវការពេញចិត្តជានិច្ច គាំទ្រខ្ញុំជានិច្ច និងលើកទឹកចិត្តខ្ញុំជានិច្ច មិនថាក្នុងកាលៈទេសៈណាទេ ។ លើសពីនេះ យើងទាំងពីរប្រឹងប្រែងរៀនខ្លាំងណាស់ ។ មែនហើយ ឆ្នាំដែលយើងស្រឡាញ់គ្នា វាជាឆ្នាំ

ប្រលងមធ្យមសិក្សាទុតិយភូមិ ។ ដល់ពេលប្រលងហើយ ហើយនាងនិងខ្ញុំក៏បារម្ភពីការសិក្សាមិនស្ទើរដែរ ។ ចុងក្រោយ នាងបានផ្ដល់យោបល់មួយដល់ខ្ញុំ គឺថានាងនិងខ្ញុំគួរតែ ផ្អាកទំនាក់ទំនងគ្នាសិនដើម្បីប្រឹងរៀនបន្ថែមលើសដើម រហូតដល់ប្រលងមធ្យមសិក្សាទុតិយភូមិឱ្យចប់សព្វគ្រប់ ។ ពេលឮដូច្នោះ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ។ ខ្ញុំមិននឹកស្មាន ថានាងគិតគូរបានហ្មត់ចត់ដល់ថ្នាក់ហ្នឹងសោះ ។

វេលាកន្លងផុតទៅ យើងខានបានជួបគ្នា និយាយ ជាមួយគ្នាអស់ពេលជិតមួយខែ ។ ថ្ងៃមួយ គឺជាថ្ងៃបុណ្យ ជាតិ ។ ខ្ញុំនឹករឭកដល់នាងជាខ្លាំងណាស់ រហូតដល់សុំ ខ្ចីទូរសព្ទពីមិត្តម្នាក់ហៅទៅនាង ។ ប៉ុន្តែ នាងមិនលើក ទូរសព្ទទាល់តែសោះ ។ ខ្ញុំចេះតែឆ្ងល់ថាហេតុអ្វីនាងមិន

លើកទូរសព្ទខ្ញុំ? ពេលនោះហើយ វាជាពេលវេលាដែលខ្ញុំចាប់ភ្លឹកពីការប្រែប្រួលរបស់នាង។ តាមពិតនាងប្រើល្បិចចង់ចាកចេញពីខ្ញុំ ដោយយកលេសថាផ្អាកទំនាក់ទំនងគ្នាបណ្ដោះអាសន្ន រហូតដល់ប្រលងចប់។ ពេលនេះ វាជាពេលដែលអ្នកសិក្សាស្រុកស្រែបានស្គាល់នូវការឈឺចាប់ហើយ។ ជិតប្រលងផង ខ្ញុំឈឺចាប់ផង រហូតដល់ទឹកភ្នែកស្រក់នៅលើសៀវភៅម្នាក់ឯង។ ជាអ្នកស្រែមែន តែខ្ញុំមិនដែលនឿយហត់ តែបែរជាមកត្រូវនឿយហត់ចិត្តនឹងស្នេហាទៅវិញ។ ពេលខ្ញុំទៅអង្គុយនៅក្រោមម្លប់ក្រសាំងក៏លែងមានអ្នកណាឆ្ងល់ទៀតហើយ ដ្បិតគ្រប់គ្នាដឹងយ៉ាងច្បាស់ថាខ្ញុំអានសៀវភៅ ខ្ញុំប្រឹងរៀន។ ផ្ទុយស្រលះ ការពិតខ្ញុំលួចសំកុកខូចចិត្តសោះ។ ខ្ញុំតែងតែចងចាំនូវបណ្ដាំលោកតារបស់ខ្ញុំដែលថា "ស្រែក៏ដោយ តែត្រូវប្រឹងរៀន

កុំវក់វីនឹងរឿងស្នេហាច្រើនពេក" ។

ខ្ញុំចេះតែអត់ធ្មត់ សង្កត់ចិត្ត ប្រឹងប្រែងតាមបណ្តាំរបស់លោកតាជានិច្ច ។ ក្រោយមក ខ្ញុំក្រោកចេញពីម្លប់ដើមក្រសាំង ហើយដើរតម្រង់ទៅផ្ទះដើម្បីទៅយកសៀវភៅ ។ ដល់ពេលបើកទូរសៀវភៅ ខ្ញុំឥតឃើញសៀវភៅសល់ច្រើនទេ តែមានតែបីក្បាលគត់ដែលសល់ ។ ខ្ញុំចាប់ផ្តើមគិតមួយភ្លែត ហើយក៏នឹកឃើញថា "សៀវភៅរបស់ខ្ញុំជាច្រើនក្បាល បានជូនទៅមនុស្សស្រីដែលខ្ញុំស្រឡាញ់អស់ទៅហើយ" ។ស្នេហាក៏បែកបាក់ សៀវភៅក៏បាត់អស់ ។ រឿងនេះមិនថ្មីទេ ដ្បិតចំណេះទាំងអស់វាបានស្ថិតនៅក្នុងខួរក្បាលខ្ញុំ ។ រយៈពេលមួយឆ្នាំជាង ពីរឆ្នាំជាង បីឆ្នាំជាង រហូតដល់ខ្ញុំជិតបញ្ចប់មហាវិទ្យាល័យ ក៏ខ្ញុំនៅតែមិនអាចបំភ្លេចនាងបានសោះ

ឡើយ ។ ពេលយប់ ខ្ញុំចេះកើតអារម្មណ៍ឈឺចាប់ តែពេលថ្ងៃ ខ្ញុំប្រឹងខ្លាំងណាស់ ។ ឈឺយ៉ាងណា ក៏ប្រឹងដែរ មិនថាការងារ ស្រែចម្ការ ជួយគ្រួសារ និងប្រឹងរៀន ។ និយាយដោយខ្លី ខ្ញុំ ប្រឹងខ្លាំងណាស់ ហើយខ្ញុំចង់ប្រើចំណេះដឹងដែលខ្ញុំមាន បំភ្លេចការឈឺចាប់ទាំងអស់ចោល តែវា "មិនអាច" ។

ល្ងាចមួយ ខ្ញុំបានទទួលសារមួយពីលេខទូរសព្ទ មួយដែលខ្ញុំមិនដែលស្គាល់ ។ ក្នុងសារនោះបានសរសេរថា "ខ្ញុំសូមអរគុណដល់បងខ្លាំងណាស់សម្រាប់គ្រប់យ៉ាង ។ ក្រោយពីចាកចេញពីបងទៅខ្ញុំបានជួបបញ្ហាជីវិតច្រើនណាស់ ជាពិសេសមនុស្សប្រុសខ្លះមិនមានទឹកចិត្តស្មោះត្រង់ដូច បងទេ ។ ខ្ញុំដឹងថាបងឈឺចាប់ដោយសារតែការចាកចេញ របស់ខ្ញុំ ។ ខ្ញុំសុំទោស! មកដល់ថ្ងៃនេះ បើកុំតែបានសៀវភៅ

របស់បង ខ្ញុំប្រហែលជាគ្មានជីវិតបានផ្ញើសារនេះជូនបង ឱ្យដឹងពីស្ថានភាពខ្ញុំឡើយ ។ ពេលដែលខ្ញុំជួបបញ្ហាខ្លាំង និងពេលដែលមនុស្សប្រុសដែលខ្ញុំស្រឡាញ់ក្បត់ខ្ញុំ ខ្ញុំតែង នឹកឃើញបង ហើយខ្ញុំបានយកសៀវភៅរបស់បងមក អាន ។ ខ្ញុំនឹកដល់ចរិតលក្ខណៈរបស់បង កាលយើងមាន ទំនាក់ទំនងស្នេហាជាមួយគ្នា ។ បងតែងលើកទឹកចិត្តខ្ញុំឱ្យ ប្រឹងប្រែងរៀនជានិច្ច ។ មកដល់ពេលនេះ ទើបខ្ញុំដឹងថា ខ្ញុំ បានសាងកំហុសចំពោះបង ហើយខ្ញុំក៏ដឹងថាបងចិត្តទូលាយ និងបានអភ័យទោសឱ្យខ្ញុំរួចហើយ ។ អរគុណម្តងទៀត សម្រាប់សៀវភៅ និងទឹកចិត្តរបស់បង ។ មានសៀវភៅ នៅក្បែរ ដូចបងនៅក្បែរខ្ញុំអ៊ីចឹង” ។



*មិនបានអាន មិនប្រឹងអាន មិនបានសរសេរ មិនប្រឹងសរសេរ កុំថាឡើយដល់អាចជួយសង្គម ប៉ុន្តែសូម្បីតែជួយខ្លួនឯង ក៏ជួយមិនបានផង ។*

# ៥៥

## ថ្ងៃដូរក្លូនកំលោះ

ខ្ញុំចេះតែយករឿងនេះមកពិចារណា និងព្យាយាមពាល់តាមរយៈបេះដូង ដ្បិតដោយសារមនុស្សជាច្រើនចេះតែពិភាក្សាគ្នាមិនព្រមឈប់សោះ ។ រឿងនេះ វាបានកើតឡើងមិនដឹងតាំងពីពេលណាទេ ឬប្រហែលជាមកដល់ថ្ងៃនេះមានអ្នកនិពន្ធណាម្នាក់សរសេររួចហើយក៏មិនដឹង ឬក៏មានអ្នកធ្លាប់បានជួប តែពុំទាន់មានឱកាសបានសរសេរក៏ខ្ញុំមិនដឹងដែរ ។ រឿងនេះជារឿងឈឺចាប់ ជូរចត់ ពើតផ្សានិងរកវាចាថ្លែងមិនចេញទាល់តែសោះ ។ រឿងនេះ វាបន្ត

ភាគពីអត្ថបទ "សៀវភៅឈើចាប់" ដែលខ្ញុំបានសរសេរចែករំលែកកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ កន្លងទៅ ។ មានអ្នកខ្លះបានសួរខ្ញុំថា "ក្រោយពីនារីដែលខ្ញុំស្រឡាញ់ចេញពីខ្ញុំហើយ  រហូតដល់វេលាចុងក្រោយនាងបានវិលមករកខ្ញុំវិញ តើខ្ញុំនិងនាងបានស្រឡាញ់គ្នាម្តងទៀតទេ ?" ខ្ញុំនឹងរៀបរាប់ពីរឿងនេះដូចតទៅ៖

"[....] ពេលដែលខ្ញុំជួបបញ្ហាខ្លាំង  និងពេលដែលមនុស្សប្រុសដែលខ្ញុំស្រឡាញ់ក្បត់ខ្ញុំ  ខ្ញុំតែងនឹកឃើញបង ហើយខ្ញុំបានយកសៀវភៅរបស់បងមកអាន ។  ខ្ញុំនឹកដល់ចរិតលក្ខណៈរបស់បង កាលយើងមានទំនាក់ទំនងស្នេហាជាមួយគ្នា ។បងតែងលើកទឹកចិត្តខ្ញុំឱ្យប្រឹងប្រែងរៀនជានិច្ច ។ មកដល់ពេលនេះទើបខ្ញុំដឹងថា  ខ្ញុំបានសាងកំហុសចំពោះ

បង ហើយខ្ញុំក៏ដឹងថាបងចិត្តទូលាយនិងបានអភ័យទោសឱ្យខ្ញុំរួចហើយដែរ ។ អរគុណម្តងទៀតសម្រាប់សៀវភៅនិងទឹកចិត្តរបស់បង ។ មានសៀវភៅនៅក្បែរ ដូចបងនៅក្បែរខ្ញុំអ៊ីចឹង" ។ ខ្ញុំបានតបសារទៅនាងវិញថា "បងសង្ឃឹមថាអូនសុខសប្បាយ ។ តាមរយៈបទពិសោធនេះ និងមេរៀនជីវិតនេះ បងសង្ឃឹមថាអូននឹងបានរៀនសូត្រនូវមេរៀនដ៏ល្អនេះទុកសម្រាប់ជីវិត" ។ ដោយសេចក្តីស្រឡាញ់របស់ខ្ញុំដែលមានចំពោះនាង វាបានធ្វើឱ្យយើងទាំងពីរនាក់ចាប់ផ្តើមសេចក្តីស្រឡាញ់នឹងគ្នាវិញម្តងទៀត ។ ខ្ញុំដឹងថានាងសប្បាយចិត្តនិងទទួលបានកម្លាំងចិត្តចំពោះជីវិត ក្នុងពេលដែលខ្ញុំមានវត្តមានជាមួយនឹងចិត្តអភ័យលើកលែងទោសឱ្យនាង ។

ក្រៅតែពីនាងសប្បាយចិត្ត រីចំពោះខ្ញុំវិញក៏មានចិត្ត

រំភើបនិងពេញចិត្តបន្តដំណើរជាមួយនាងដែរ ។ ក្តីសង្ឃឹមរបស់ខ្ញុំគឺជឿថានាងនឹងក្លាយទៅជាអនាគតកូនក្រមុំដែលបន្តដំណើរជីវិតជាមួយខ្ញុំរៀងរហូត ។ ខ្ញុំគិតថា "នាងគិតត្រូវហើយគឺថានៅលើលោកនេះគ្មាននរណាម្នាក់ស្មោះត្រង់និងស្រឡាញ់នាងដូចសេចក្តីស្រឡាញ់របស់ខ្ញុំទេ" ។ ស្របពេលដែលយើងបន្តដំណើរជីវិតជាមួយគ្នា យើងតែងតែចំណាយពេលវេលាបង្កើតអនុស្សាវរីយ៍ជាច្រើនជាមួយគ្នា ។ ពេលខ្លះ ខ្ញុំឃើញនាងស្រក់ទឹកភ្នែក ។ ខ្ញុំបានសួរនាងថា "តើអូនកើតអ្វី ទើបបានជាស្រក់ទឹកភ្នែក?" នាងតបថា "ដោយសារអូនរំភើបនឹងសេចក្តីស្រឡាញ់របស់បងពេកទើបទឹកភ្នែកអូនស្រក់" ។ ក្រោយមកនាងមកកៀកក្បែរខ្ញុំ រួចហើយឱបខ្ញុំយ៉ាងខ្លាំង ។ ខ្ញុំបានឱបនាងរួចខ្សឹបដាក់ត្រចៀកនាងថា "អូនជាមនុស្សល្អ ហើយបងនឹងនៅក្បែរ

អូនជានិច្ច ដោយមិនថាមានរឿងអ្វីកើតឡើងទេ”។ នាងយំសួរខ្ញុំថា “ពិតមែនឬ? ឬបើទោះបីជាខ្ញុំបានធ្វើមិនល្អនឹងបងក៏ដោយ?” ខ្ញុំតបជាមួយនឹងអារម្មណ៍ស្រឡាញ់ថា “បាទ គឺពិតមែនហើយ! បងនឹងនៅក្បែរអូនគ្រប់ពេល និងធ្វើគ្រប់យ៉ាងដើម្បីអូន សំខាន់ឱ្យតែអូនទៅមុខមានសេចក្ដីសុខ”។

ថ្ងៃមួយយើងទាំងពីរបានសម្រេចចិត្តជម្រាបប្រាប់រឿងរបស់យើងទាំងពីរឱ្យចាស់ទុំសងខាងដឹងឮ។ ពីដំបូងគ្រួសាររបស់នាងហាក់ប្រតិកម្មបែបអវិជ្ជមាន ដោយសារខ្ញុំជាកូនកសិករ ក្រីក្រ ធ្វើស្រែចម្ការសម្រាប់តែមួយក្រពះ។ ប៉ុន្តែដោយសារតែពេលវេលា ទើបធ្វើឱ្យគ្រប់យ៉ាងចេះតែល្អប្រសើរឡើង ៗ ពីមួយថ្ងៃទៅមួយថ្ងៃ។ ស្របពេលនឹងរឿង

ល្អមួយកើតឡើង វាក៏មានរឿងអាក្រក់មួយទៀតកើតឡើង ដូចគ្នាដែរ គឺឪពុកខ្ញុំបានបរទេះក្រឡាប់នៅកណ្ដាលវាលស្រែ ពីព្រោះដោយសារតែគោអូសរទេះផ្អើល ។ ពេលនោះ ខ្ញុំទទួលដំណឹងថា ឪពុកខ្ញុំសន្លប់នៅនឹងវាលស្រែ ងើបក្រោកមិនរួចទេ ហើយអ្នកភូមិបានយករទេះទៅដឹកគាត់មកផ្ទះវិញ ។ ពេលឪពុកខ្ញុំត្រូវបានអ្នកភូមិដឹកមកដល់ផ្ទះ រីខ្ញុំក៏បានមកដល់ផ្ទះភ្លាមដែរ (ខ្ញុំបានទៅបំពេញការងារនៅតាមស្រុក) ។ ឪពុកខ្ញុំធ្លាក់ខ្លួនឈឺ មើលមិនជា ឬមួយថ្ងៃកាត់មួយថ្ងៃកោរ ។ តាំងពីពេលនោះមក ខ្ញុំត្រូវប្រឹងធ្វើការលើសដើម ។ ការងារដែលឪពុកខ្ញុំធ្លាប់ធ្វើ គឺត្រូវផ្ទេរមកឱ្យខ្ញុំទាំងអស់ ។ ខ្ញុំដឹងថាអ្នកខ្លះប្រហែលជាធ្វើមិនបានទេ ។ ខ្ញុំបានព្យួរឈ្មោះចោលនៅមហាវិទ្យាល័យ ហើយត្រូវប្រឹងធ្វើការគ្មានពេលសម្រាកទាំងការងារខាងក្រៅ និងការងារ

ស្រែចម្ការ ។

រយៈពេលជាងមួយឆ្នាំហើយដែលទំនាក់ទំនងរបស់ខ្ញុំ និងមនុស្សដែលខ្ញុំស្រឡាញ់បានបន្តឡើងវិញជាមួយនឹងក្ដីសង្ឃឹម ។ ខ្ញុំមិនដឹងថានាងគិតអ្វីទេ ទើបពេលមួយនាងសួរខ្ញុំថា “បង តើយើងអាចរៀបការបានទេ?” ខ្ញុំស្ទុតចិត្តនឹងនាង, រួចសួរថា “អូន តើហេតុអ្វីអូនចង់រៀបការលឿនម្លេះ? ពេលនេះបងមិនទាន់មានអ្វីនៅឡើយទេ ហើយពុំអាចមានសមត្ថភាពគ្រប់គ្រាន់ចិញ្ចឹមអូនឱ្យបានរស់នៅសុខស្រួលនៅឡើយទេ ។ អូនដឹងស្រាប់ហើយ បងមានបន្ទុកគ្រួសារ ហើយម្យ៉ាងឪពុកបងក៏កំពុងតែឈឺរ៉ាំរ៉ៃនៅផ្ទះផងដែរ” ។ នាងតបថា “អូនធ្លាប់ទទួលអារម្មណ៍ឈឺចាប់នឹងសេចក្តីស្រឡាញ់” ។ នាងនិយាយបែបនេះ ធ្វើឱ្យខ្ញុំនឹកអាណិតនាង

ជាខ្លាំង, រួចខ្ញុំតបថា “បាទ! បងនឹងពិភាក្សាជាមួយអ្នកម្ដាយនិងលោកឪពុកសិនណ៎ា” ។ ពេលខ្ញុំយករឿងនេះទៅជម្រាបអ្នកម្ដាយនិងលោកឪពុក ពួកគាត់ទំនងសប្បាយចិត្ត ហើយឪពុកខ្ញុំនិយាយថា “កូនអើយ! ពុកចាស់ណាស់ទៅហើយ រីម្យ៉ាងពេលនេះឈឺទៀត ។ ពុកសង្ឃឹមថានឹងបានឃើញកូនរៀបការ ទាន់ភ្នែកភ្លឺ” ។ ចុងក្រោយគ្រួសារខ្ញុំសម្រេចចិត្តអនុញ្ញាតឱ្យខ្ញុំរៀបការ ។ ខ្ញុំបានយកដំណឹងល្អនេះទៅប្រាប់នាង ហើយនាងក៏បានមកឱបខ្ញុំយ៉ាងខ្លាំង ជាមួយនឹងពាក្យថា “អរគុណគ្រប់យ៉ាង” ។ ប៉ុន្តែពេលនោះ ពេលដែលនាងឱបខ្ញុំយ៉ាងខ្លាំង ខ្ញុំមានអារម្មណ៍ចម្លែកម្យ៉ាងថានាងមិនមែនឱបខ្ញុំទេ ។ ខ្ញុំចេះតែសួរខ្លួនឯងថា “នាងស្រឡាញ់ខ្ញុំខ្លាំងហើយនាងឱបខ្ញុំ? ចុះហេតុអ្វីពេលនាងឱបខ្ញុំ ខ្ញុំបែរជាទទួលអារម្មណ៍ថានាងមិនបានឱបខ្ញុំទៅវិញ? ខ្ញុំអើយ!

! មិនគួរគិតផ្ដេសផ្ដាសតាមអារម្មណ៍អ៊ីចឹងទេ ដ្បិតនាងស្រឡាញ់ខ្ញុំខ្លាំងណាស់"។

សំឡេងភ្លេងខ្មែរប្រគំយ៉ាងរងំសណ្ដំដួងចិត្ត។ កូនកំលោះ គឺខ្ញុំ។ តាំងពីពេលនៅរៀន រហូតដល់នាងធ្លាប់ចាកចោលខ្ញុំម្ដង តែគូព្រេងមិនព្រាត់ទេ តែបើវាព្រាត់ គឺព្រាត់ដោយកម្មប៉ុណ្ណោះ។ នាងជាគូព្រេងរបស់ខ្ញុំពិតមែនហើយ ដ្បិតបើទោះបីជាមានរឿងអ្វីកើតឡើង ក៏យើងនៅតែមានថ្ងៃពិសេសនេះដែរ (ថ្ងៃរៀបការ)។ សំឡេងភ្លេងការចេះបន្លឺឡើងៗ ហើយនាងបានសួរខ្ញុំថា "បងស្រឡាញ់អូនពិតទេ?" ខ្ញុំតបថា "បាទ ពិត"។ នាងសួរបន្តថា "តើពិតយ៉ាងដូចម្ដេច?" ខ្ញុំនិយាយប្រាប់នាងថា "អូនដឹងទេ នៅក្នុងភូមិនេះមាននារីពីរនាក់បានចាប់អារម្មណ៍បង"។

នាងសួរថា "បងអត់សង្ហាផងហ្នឹង ហើយមាននារីស្រឡាញ់បងដែរ?" ខ្ញុំតបថា "បងសង្ហា ឬមិនសង្ហា អូនត្រូវទៅសួរនារីពីរនាក់នោះទើបត្រូវ ពីព្រោះបងក៏មិនដឹងថាហេតុអ្វីនាងស្រឡាញ់បងដែរ"។ នាងសួរខ្ញុំថា "ចុះៗ ម៉េចបងមិនស្រឡាញ់ពួកនាងវិញទៅ កាលវេលាដែលបងគ្មានអូនមួយរយៈមុននោះ"។ ខ្ញុំតបថា "សេចក្ដីស្រឡាញ់ណាំអូនវាមិនសំខាន់ថាមានមនុស្សប៉ុន្មាននាក់មកចាប់អារម្មណ៍ស្រឡាញ់យើងទេ តែសំខាន់តើយើងស្រឡាញ់អ្នកណា។ បងស្រឡាញ់អូន"។ នាងសើច រួចនិយាយថា "បងឯងមើលមុខស្រែៗទេ ប៉ុន្តែទើបតែពេលនេះ ទើបអូនឮបងនិយាយផ្អែមល្ហែមបំផុត"។ មួយសន្ទុះក្រោយមក នាងក៏ស្រក់ទឹកភ្នែកទៀត។ ខ្ញុំសួរនាងថា "ហេតុអ្វីអូនយំទៀតហើយ"។ នាងតបថា "អូនរំភើបនឹងសេចក្ដីស្រឡាញ់

របស់បង”។ ភ្លេងការកំដរមនោសញ្ចេតនានាងនិងខ្ញុំ។

លុះដល់ព្រឹកស្អែក គឺជាថ្ងៃហែរជំនូន។ បងប្អូនអ្នកជិតខាងមកជួបជុំគ្នា ហើយម្នាក់ៗនិយាយសរសើរមិនដាច់ពីមាត់ថា “មួយគូនេះសមគ្នាណាស់”។ ពិធីហែរជំនូនចប់យ៉ាងលឿន។ វេលាប្រហែលជា ៩ព្រឹក មានបុរសម្នាក់មុខមាត់សង្ហា ចុះពីលើឡាន រួចហើយដើរតម្រង់មកកាន់ពិធី សួររកកូនក្រមុំ។ ខ្ញុំឃើញហើយ ស្មានតែជាមិត្តភក្តិរបស់នាង ក៏បានអញ្ជើញគាត់ឱ្យឡើងទៅលើផ្ទះ។ បុរសម្នាក់នោះសម្លឹងខ្ញុំក្នុងក្រសែភ្នែកយ៉ាងស្រងូតស្រងាត់បំផុត។ ពេលទៅដល់លើផ្ទះ បុរសម្នាក់នោះបានហៅមនុស្សដែលជាកូនក្រមុំរបស់ខ្ញុំថា “អូន”។ កូនក្រមុំរបស់ខ្ញុំគ្រាន់តែឃើញបុរសម្នាក់នោះ ក៏ហូរទឹកភ្នែកដូច

ទឹកភ្លៀងធ្លាក់ពីលើមេឃ ។ ខ្ញុំគិតក្នុងចិត្តថាប្រហែលជាមិត្តភក្តិបែកគ្នាយូរឆ្នាំហើយមើលទៅ ទើបបានជាម្នាក់ៗដូចជាមានអារម្មណ៍មនោសញ្ចេតនានឹងគ្នាខ្លាំងម្លេះ ។ កូនក្រមុំរបស់ខ្ញុំឃើញបណ្តើរ រួចនិយាយថា "បងមកហើយមែនទេ (សំដៅដល់បុរសម្នាក់នោះ) ?" ក្រោយមកនាងបានរត់ទៅឱបបុរសម្នាក់នោះ ហើយអ្នកទាំងពីរហាក់បីដូចជាជាប់ជំពាក់នូវមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅនឹងគ្នា ។ ខ្ញុំបានសួរថា "តើមានរឿងអ្វី? អូននិងគេ..????" គ្រាន់តែឮខ្ញុំសួរភ្លាម អ្នកទាំងពីរចាប់ដៃគ្នាយ៉ាងជាប់ ។ បេះដូងខ្ញុំពាល់រឿងគ្រប់យ៉ាង និងអារម្មណ៍ទាំងអស់ក្នុងស្ថានភាពពេលនោះ ។ ខ្ញុំសួរកូនក្រមុំរបស់ខ្ញុំថា "តើអូននិងគេធ្លាប់ស្រឡាញ់គ្នាជ្រាលជ្រៅមែនទេ?" អ្នកទាំងពីរចាប់ដៃគ្នាជាប់ ហើយនាងឥតនិយាយអ្វីសោះ ។

ខ្ញុំនិយាយទៅកាន់នាងថា “ក្នុងនាមបងជាកូនកំលោះពេលនេះ តើបងអាចឱបអូនបានទេ?” ខ្ញុំបានដើរទៅកាន់នាងត្រឹមតែពីរជំហានដល់ រួចហើយឱបនាង ។ ក្នុងគ្រានោះខ្ញុំស្រក់ទឹកភ្នែកបណ្ដើរ រួចប្រាប់នាងថា “បងពាល់ហើយ” ។ ការពិតអារម្មណ៍ដែលខ្ញុំសង្ស័យរាល់ពេលដែលនាងឱបខ្ញុំ គឺនាងមិនបានស្រឡាញ់ខ្ញុំទេ ។ ខ្ញុំសួរនាងបញ្ជាក់ថា “អារម្មណ៍កន្លងមកដែលអូនឱបបង វាជាអារម្មណ៍បោកប្រាស់ និងក្លែងក្លាយមែនទេ? អូនធ្លាប់កុហកបង តែបងនឹងមិនកុហកអូនទេ ។ បងធ្លាប់និយាយថា ‘ធ្វើគ្រប់យ៉ាងដើម្បីអូន’ ហើយពេលនេះ វាជាពេលវេលាសក្ដិសមបំផុតហើយ” ។ ខ្ញុំបានដោះសម្លៀកបំពាក់កូនកំលោះដែលនឹងនៅខ្លួនខ្ញុំចេញ រួចទៅបំពាក់ឱ្យកូនកំលោះក្នុងចិត្តរបស់នាង ដោយប្រាប់បុរសនោះថា “ថែរក្សានាង

ឱ្យល្អ ពីព្រោះនាងជាមនុស្សល្អ" ។ រួចខ្ញុំផ្តាំអតីតកូនក្រមុំរបស់ខ្ញុំថា "អូនជាមនុស្សល្អ ហើយអូនគ្មានកំហុសទេ ។ ញញឹម ទៅមុខ ។ បើអូនសុខ គឺបងសប្បាយហើយ" ។ ខ្ញុំដើរចុះពីលើផ្ទះ ស្របពេលដែលមានមនុស្សម្នាសម្លឹងមកខ្ញុំយ៉ាងឈឺចាប់ ។ ពេលនោះមាននារីក្នុងភូមិម្នាក់ដែលធ្លាប់លួចចាប់អារម្មណ៍ខ្ញុំរត់មករកខ្ញុំ រួចសួរខ្ញុំថា "បង តើបងឆ្កួតទេឬ? តើហេតុអ្វីបងដើរចេញ? តើបងមិនឈឺចាប់ទេឬ?" ខ្ញុំតបថា "ការឈឺចាប់ វាមានតែចំពោះមនុស្សដែលមានបេះដូងតូចប៉ុណ្ណោះ ។ ការឈឺចាប់វាមានតែចំពោះមនុស្សដែលមិនយល់ពីសេចក្តីស្រឡាញ់ប៉ុណ្ណោះ" ។ ពេលខ្ញុំកំពុងដើរចេញ មានក្មេងប្រុសម្នាក់រត់មកយ៉ាងលឿនរួចថា "ពូ! ពូភ្លេចសៀវភៅនៅលើផ្ទះហើយ ។ នេះជាសៀវភៅរបស់ពូ" ។ ប្រហែលជាពីរខែក្រោយ ឪពុកខ្ញុំបាន

ទទួលអនិច្ចកម្មទៅ ។ ពេលវេលាចេះតែកន្លងផុតទៅ ខ្ញុំរស់នៅជាមួយនឹងការប្រឹងប្រែង រីនាងរស់នៅជាមួយនឹងសេចក្ដីសុខ ។ ដើម្បីមនុស្សដែលនៅក្បែរខ្ញុំ ដើម្បីគ្រួសារខ្ញុំ ខ្ញុំក៏ប្រឹងប្រែងជាមួយនឹងសេក្ដីសុខដែរ ។ ខ្ញុំនៅតែជាអ្នកកាន់សៀវភៅដដែល ។

# ៥៦

## ដើម្បីក្លាយទៅជាអ្នកនិពន្ធ?

ខ្ញុំរវល់តែការងារស្រែចម្ការ ហើយមិនសូវមានពេលចេញក្រៅ ឬបើចេញ ក៏ត្រូវទៅរកកន្លែងណាស្ងប់ស្ងាត់ដែរ ។ មានបងប្អូនខ្លះឆ្លៀតសួរខ្ញុំពីអ្វីដែលខ្ញុំធ្វើ ក្នុងនាមជាអ្នកសរសេរថា តើត្រូវធ្វើបែបណាដើម្បីក្លាយទៅជាអ្នកនិពន្ធ? ខ្ញុំសុំអនុញ្ញាតឆ្លើយថា "មិនដឹង" តែខ្ញុំសុំត្រឹមតែចែករំលែករឿងខ្លះ ៗ នៅទីនេះ ។ សូមបញ្ជាក់ថា នេះជាការចែករំលែកដល់បងប្អូនប៉ុន្មាននាក់ដែលសួរខ្ញុំប៉ុណ្ណោះ ហើយមិនឆ្លុះបញ្ចាំងពីសមត្ថភាពរបស់ខ្ញុំទេ ។

អ្នកនិពន្ធត្រូវតែជាអ្នកពូកែស្រាវជ្រាវ ពូកែអាន ពូកែគិត ពូកែវិភាគ ពូកែអត់ធ្មត់ និងយល់ដឹងផ្នែកចិត្តសាស្ត្រសង្គម ផ្នត់គំនិតមនុស្ស និងស្ថានភាពសង្គមវិជ្ជារបស់សង្គមទាំងមូល ។ អ្វីដែលសំខាន់សម្រាប់អ្នកនិពន្ធ គឺឯកសាររៀនឬឯកសារពិគ្រោះ ឬឯកសារស្រាវជ្រាវដែលយើងអាចហៅថា "Educational Resource" ។ "Educational Resource" នេះ វាសំខាន់ណាស់ ដ្បិតបើយើងគ្មានវាទេ គឺយើងនឹងអស់អ្វីសរសេរ ឬសរសេរតែអ្វីដែលខ្លួនដឹងប៉ុណ្ណោះ ។ និយាយដោយខ្លី ការស្រាវជ្រាវសំខាន់ខ្លាំងណាស់ ។

ការនិយាយស្រួលជាងការសរសេរ ដ្បិតបើការសរសេរស្រួល ម្ល៉ោះអ្នកពូកែនិយាយទាំងអស់ គឺប្រហែលជានឹងក្លាយទៅជាអ្នកនិពន្ធអស់ទៅហើយ ។ សម្តី ១០០ម៉ាត់

សរសេរយកសាច់ការបានត្រឹមតែ ១០ម៉ាត់ប៉ុណ្ណោះ ។ ការសរសេរ គឺស្មើនឹងគិត ហើយការគិត វាលំបាកខ្លាំងណាស់ ។ អ្នកដែលចង់ក្លាយទៅជាស្មេរ គឺត្រូវស្វែងរកអត្តសញ្ញាណខ្លួនឯង ចរិតលក្ខណៈនៃសំណេរ និងព្រលឹងនៃសំណេររបស់ខ្លួន ។ សំណេរខ្លះ បើទោះបីជាដូរឈ្មោះអ្នកសរសេរក៏អ្នកអានដឹងដោយស្វ័យប្រវត្តិថាជាសំណេររបស់ស្មេរណាពិតប្រាកដដែរ ។ សំណេរតែងមានព្រលឹងទឹកដៃរបស់អ្នកសរសេរ ។

រឿងចុងក្រោយដែលអ្នកនិពន្ធត្រូវការចេះគឺចំណេះដឹងខាងបច្ចេកវិទ្យា ។ ពេលរៀបចំក្របសៀវភៅមុខក្រោយ និងគម្របសៀវភៅ មិនថាគម្របធម្មតា ឬគម្របបែប 3D គឺយើងត្រូវចេះជំនាញរចនា (Design) ឬឱសាញដោយ

ប្រើប្រាស់នូវកម្មវិធី Adobe Photoshop ឬ Adobe Illus - trator ។ អ្វីដែលសំខាន់បន្ទាប់ គឺយើងគួរតែចេះប្រើប្រាស់កម្មវិធីរចនាអត្ថបទ/រៀបចំទំព័រឱ្យច្បាស់ជំនាញ ឬកម្មវិធីរៀបចំអត្ថបទ/ទំព័រឱ្យមានលក្ខណៈស្តង់ដារ គឺយើងមិនអាចប្រើប្រាស់កម្មវិធី Microsoft Office Word ដើម្បីរចនាអត្ថបទនិងទំព័រសៀវភៅទេ ។កម្មវិធីស្តង់ដារសម្រាប់ការងារឌីសាញអត្ថបទ គឺ Adobe InDesign ។ សោភណ្ឌភាពនៃអត្ថបទ គឺវាសំខាន់ខ្លាំងណាស់សម្រាប់អ្នកអាន ។ រឿងចុងក្រោយសម្រាប់អ្នកសរសេរ គឺគួរតែមានចំណេះដឹងខាងសមាធិ និងការពិសោធន៍ ពីព្រោះវាធ្វើឱ្យយើងមានគំនិតមិនសុញ មានអារម្មណ៍ស្រស់ថ្លា និងមានថាមពលផ្លូវចិត្តល្អ ។ ស្នេហត្រូវការចិត្តស្ងប់ តែបើចិត្តល្អក់វិញ បើទោះបីជាមានគំនិតល្អដែលអាចសរសេរបានក៏ដោយ ក៏អត្ថបទនឹង

បង្ហាញសភាពល្អក់ដែរ ។ បើតាមទស្សនៈរបស់ខ្ញុំ អ្នកនិពន្ធជំនាន់ក្រោយគួរតែមានមូលដ្ឋានចំណេះដឹងទស្សនវិជ្ជាឱ្យច្រើន ការគិតបែបស៊ីជម្រៅ និងភាពជាអ្នកដឹកនាំ ដ្បិតវាល្អសម្រាប់អ្នកអាន និងការរីកចម្រើនសង្គម ។

ខ្ញុំមិនមែនជាអ្នកនិពន្ធទេ ហើយក៏គ្មានបំណងចង់ធ្វើជាអ្នកនិពន្ធដែរ តែសុំត្រឹមតែកាន់ប៊ិកក្នុងនាមជាអ្នកសរសេរចែករំលែកទស្សនៈ បំផុសគំនិត បង្ហាញការយល់ឃើញ និងការឆ្លុះបញ្ចាំងទ្រឹស្តីទៅនឹងទិដ្ឋភាពសង្គមប៉ុណ្ណោះ ។ អត្ថបទដែលមានក្នុងសៀវភៅរបស់ខ្ញុំទាំងអស់ (សៀវភៅទាំងពីរក្បាល), អ្នកអានគ្រប់គ្នាសុទ្ធតែអាចចូលអានដោយឥតគិតថ្លៃបាននៅក្នុងហ្វេសប៊ុករបស់ខ្ញុំ ។ សរុប នេះជាការចែករំលែកនូវអ្វីដែលខ្ញុំកំពុងធ្វើ ធ្លាប់បានធ្វើ និងអ្វី

ដែលខ្ញុំយល់ថាសំខាន់ និងមានប្រៀប បើសិនជាយើងចេះ

អ្វីទាំងអស់នេះ ។

# ៥៧

## អ្នកមានស្នេហ៍ដាចអ្នកខ្លាចស្នេហ៍ជា

បើនិយាយពីជីវិត គឺគ្មានអ្វីទៀងទាត់ទាល់តែសោះ ដ្បិតសូម្បីតែសម្បកកាយកាលពីដប់ឆ្នាំមុន ក៏វាបានប្រែក្លាយផ្លាស់ប្តូរកាយថ្មីនៅថ្ងៃនេះដែរ ។ នៅក្នុងរាងកាយមនុស្សយើងគ្រប់ៗគ្នា គឺគ្មានធម្មធាតុណាមួយដែលនៅនឹងថ្កល់នោះទេ (ច្បាប់រំញ័រ - The Law of Vibration) ។ លើសពីនេះ ជីវិតយើងក៏ពុំអាចរស់នៅដដែលៗ ដោយគ្មានការផ្លាស់ប្តូរថ្មីដែរ ។ រីចំពោះខ្ញុំវិញ ពីមុនខ្ញុំជាអ្នកស្រែ ហើយខ្ញុំបន្តដំណើរជីវិតជាអ្នកស្រែផង ព្រមទាំងធ្លាប់បម្រើការងារ

នៅតាមអង្គការក្រៅរដ្ឋាភិបាលផង និងរហូតដល់ពេលនេះ អ្នកខ្លះចាត់ទុកខ្ញុំជាស្មេរ ។ មួយជីវិតនេះ ខ្ញុំធុញទ្រាន់នឹងភាពដដែលៗ រហូតកំណត់ជីវិតនេះថាគួរតែប្រែប្រួលខ្លះៗ ដោយកុំដដែលៗ ។ នេះជាច្បាប់សកលនៃជីវិត ។

នៅលើលោកយើងនេះ គ្មានអ្វីដែលមិនប្រែប្រួលទេ មានតែការប្រែប្រួលប៉ុណ្ណោះ ដែលមិនប្រួលប្រួលទៅណាសោះ ។ ការផ្លាស់ប្តូរដ៏តូចមួយ វានឹងធ្វើឱ្យមានការផ្លាស់ប្តូរដ៏ធំមួយ ។ នៅក្នុងអង្គភាពមួយ បើមិនចេះច្នៃ មិនចេះបត់ខ្លួនផ្លាស់ប្តូរឱ្យទាន់កាលៈទេសៈនិងរបត់ទេ គឺនឹងបរាជ័យ ។ ការបរាជ័យក្នុងការប្រថុយប្រថានដើម្បីការផ្លាស់ប្តូរអ្វីមួយឱ្យល្អប្រសើរជាងមុន គឺវាប្រសើរជាងបរាជ័យដោយពុំបានធ្វើអ្វីសោះ ។ សុភាសិតខ្មែរពោលថា "កំហុសរមែងមានដល់

អ្នកធ្វើ អ្នកនៅឥតអំពើ បានអ្វីនឹងខុស”។ ក្នុងបរិបទសង្គមដែលរីកចម្រើន គេបានឱ្យនិយមន័យ “កំហុស” ស្មើនឹង “មេរៀន” តែក្នុងបរិបទខ្មែរយើងវិញ បើខុសគឺខុសហើយ។ ទស្សនវិទូក្រិកបុរាណ សូក្រាត បានឱ្យកំណត់តម្លៃជីវិតដែលមានន័យថាជា “ការពិសោធន៍”។ នេះមានន័យថាមនុស្សរស់នៅត្រូវក្លាហានហ៊ានពិសោធលើជីវិតខ្លួនឯង កុំខ្លាច កុំកំសាក កុំចាំតែថាដោយមិនព្រមធ្វើ កុំចាំតែបន្ទោសអ្វីៗនៅខាងក្រៅខ្លួន ដោយមិនព្រមប្រឹងខ្លួនឯង។

យើងត្រូវប្រើជីវិតជាមួយនឹងសេចក្តីក្លាហានដ៏ត្រឹមត្រូវត្រូវកាលៈទេសៈ និងដឹងពេលវេលាត្រូវក្លាហាន។ បើកាលៈទេសៈមិនអំណោយផលសម្រាប់សេចក្តីក្លាហានរបស់

យើងទេ គឺយើងត្រូវចេះលះបង់ ។ ការលះបង់ត្រូវឈរលើប្រយោជន៍រួម ។ ត្រង់ចំណុចនេះ ខ្ញុំចង់ឆ្លុះបញ្ចាំងបន្តិចពីរឿងសង្គម ។ សង្គមយើងសម្បូរអ្នកចេះដឹងណាស់ តែអ្នកខ្លះមិនសូវចេញមុខទេ ។ អ្នកខ្លះទៀត បែរជាហ៊ាននិយាយពីបញ្ហាសង្គមរបស់ប្រទេសជិតខាង ប៉ុន្តែបែរជាខ្លាចរអាលាតត្រដាងនិយាយពាក្យពិតពីបញ្ហាសង្គមដែលខ្លួនកំពុងរស់នៅទៅវិញ ហើយមិនព្រមបើកវាំងននបង្ហាញការពិតឱ្យយុវជនរៀនគិតពីចំណុចខ្លាំងចំណុចខ្សោយរបស់សង្គមទេ ។ អ្នកខ្លះទៀត គឺជាអ្នកបង្ខាំបង្ខូចសច្ចភាពសង្គមតែម្ដង ដ្បិតនិយាយបាតដៃជាខ្នងដៃ និងខ្នងដៃជាបាតដៃ ។ នេះជាវិបត្តិសង្គមបច្ចុប្បន្នមួយ ដែលក្នុងនាមជាយុវជនត្រូវដឹង ត្រូវស្វែងយល់ដោយខ្លួនឯង និងត្រូវរៀនធ្វើមនុស្សដែលចេះមើលឃើញចំណុចខ្មៅរបស់

សង្គមចំណុចក្ដីរបស់សង្គម និងដំណោះស្រាយសម្រាប់សង្គមរីកចម្រើន ។ល ។ តើមួយណាល្អជាង រវាងភាពខ្លាច និងភាពក្លាហាន ?

"អ្នកស្នេហាសច្ចភាព និងការពិត (សច្ចវិញ្ញូ) - Love of Truth" គួរត្រូវចេះលះបង់ ប្រៀបដូចជាសូក្រាតលះបង់ខ្លួន សុខចិត្តស្លាប់ដើម្បីពង្រឹងច្បាប់ប្រទេសក្រិកអ៊ីចឹង ។ ទស្សនវិទូក្រិក អារីស្តូត (Aristotle) ពោលថា "សូមកុំកំសាករហូតដល់រត់គេចពីគ្រប់គ្រោះថ្នាក់ តែក៏សូមកុំក្លាហានរហូតដល់ធ្វើឱ្យយើងជួបគ្រោះថ្នាក់ដែរ" ។ ភាពក្លាហានដោយស្គាល់កាលៈទេសៈ គឺជាភាពឆ្លាតវៃមួយ ។ ប៉ុន្តែបើរង់ចាំកាលៈទេសៈស័ក្តិសម រង់ចាំហើយរង់ចាំទៀត នៅតែមិនទាន់ដល់កាលៈទេសៈស័ក្តិសមទេ ហើយស្ថិតក្នុងសភាព

ចាំបាច់បំផុតនោះ គឺត្រូវការសេចក្តីក្លាហានប្រកបទៅដោយស្មារតីលះបង់ខ្ពស់ សង្គ្រោះប្រយោជន៍រួមមួយ ។ កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប ។ លើសពីនេះ ទ្រឹស្តីពុទ្ធនិយមក៏បានលើកឡើងដែរថា “ភាពភ័យខ្លាចនឹងមិនមានដល់បុគ្គលដែលមានចិត្តមិនទទឹកជោកសើមដោយរោគៈឬទោសៈប្រទូសរ៉ាយ ហើយក៏មិនមានដល់បុគ្គលដែលមានសតិដឹងនូវបុណ្យបាបនោះឡើយ” ។ ខ្ញុំសូមបកស្រាយនូវទ្រឹស្តីពុទ្ធនិយមដោយសង្កត់ធ្ងន់ទៅលើពាក្យ “បុណ្យ” និងពាក្យ “បាប” ។ ត្រង់ចំណុចនេះ គឺចង់បង្ហាញពី “ប្រយោជន៍ដែលត្រូវធ្វើ” ហៅថាបុណ្យ ហើយការនៅស្ងៀមរង់ចាំស្លាប់ដោយមិនធ្វើអ្វីសោះ គឺហៅថា “បាប” ។ នេះជាគុណធម៌បណ្ឌិតជន និងអ្នកចេះដឹង ។

តាមទស្សនៈខ្ញុំ សេចក្តីក្លាហាន វាគឺជាគុណធម៌មួយ ហើយសេចក្តីក្លាហានប្រកបទៅដោយស្មារតីលះបង់ខ្ពស់ គឺជាឥរិយាបថវីរបុរស ។ ខ្ញុំបានប្រឆាំងទស្សនៈរបស់ទស្សនវិទូបារាំង វ៉ុលទែរ (Voltaire) ដែលលោកលើកឡើងថា "សេចក្តីក្លាហាន គឺពុំមែនជាគុណធម៌ទេ" ។ នៅក្នុងកូនសៀវភៅតូចមួយដែលនិយាយអំពី "មហាគុណធម៌ និងការប្រើប្រាស់ទស្សនវិជ្ជាសម្រាប់ជីវិតប្រចាំថ្ងៃ" បានលើកឡើងថា "ជនកំសាកមាននៅគ្រប់ទីកន្លែង ហើយអ្នកសម្តែងសេចក្តីក្លាហាន ក៏មាននៅគ្រប់ទីកន្លែងដូចគ្នាដែរ ។ សង្គមនីមួយៗ តែងមានអ្នកខ្លាចនិងអ្នកហ៊ាន ។ ភាពខុសគ្នារវាងអ្នកខ្លាចនិងអ្នកហ៊ាន គឺត្រង់ថាអ្នកហ៊ានចេះលាក់សេចក្តីភ័យខ្លាចទុកក្នុងខ្លួន (មិនបង្កើលអ្នកដទៃឱ្យខ្លាច)" ។ គំនិតនេះ វាក៏មិនខុសពីការយល់ឃើញរបស់

មេដឹកនាំភូមា អ្នកស្រី អ៊ុងសាន ស៊ូជី ដែលថា “នរណាដែលថាមិនចេះខ្លាចនោះ តែយើងត្រូវមានរបៀបគ្រប់គ្រងភាពភ័យខ្លាច និងត្រូវចេះលាក់ភាពភ័យខ្លាចទុក” ។ ពេលនិយាយពីរឿងបែបនេះ វាធ្វើឱ្យខ្ញុំនឹកឃើញនូវការសន្ទនាមួយរវាងខ្ញុំ និងអ៊ំប្រុសម្នាក់ដែលខ្ញុំគោរពបំផុត ។

ថ្ងៃមួយខ្ញុំបានជូនសៀវភៅដែលជាស្នាដៃរបស់ខ្ញុំទៅគាត់ ហើយគាត់មានប្រសាសន៍ថា “ក្មួយពូកែទាំងនៅវ័យក្មេង ហើយអ៊ំមិនចេះអ្វីទេ ព្រមទាំងគ្មានសមត្ថភាពអាចធ្វើបានដូចក្មួយឡើយ” ។ ពាក្យសម្ដីនេះធ្ងន់ណាស់សម្រាប់ខ្ញុំ ហើយធ្វើឱ្យខ្ញុំអាក់អន់ចិត្តបន្តិច ។ ខ្ញុំបណ្ដោយឱ្យគាត់មានប្រសាសន៍រហូតដល់ចប់ ។ ក្រោយមក ខ្ញុំបានតបថា “ជម្រាបប្រសាសន៍លោកអ៊ំ! ក្នុងមួយជីវិតរបស់ខ្ញុំ

ខ្ញុំគោរពឱ្យតម្លៃមនុស្សចេះដឹងពីរប្រភេទ៖ មនុស្សចេះដឹងប្រភេទទី១. ចំណេះដឹងដែលបំពាក់នូវសីលធម៌និងគុណធម៌, និងទី២. ការយកចំណេះដឹងទៅសាបព្រោះឱ្យកើតជាផ្លែផ្កាសម្រាប់សង្គម (យកចំណេះដឹងទៅប្រើ) ។ ខ្ញុំមិនមែនជាអ្នកចេះដឹងទេ តែខ្ញុំគ្រាន់តែជាអ្នកចែករំលែកប៉ុណ្ណោះ" ។

"[...] លោកអ៊ំជាអ្នកសិក្សាស៊ីជម្រៅម្នាក់ ហើយអ៊ំប្រហែលជាស្គាល់ទស្សនវិទូអនត្ថិនិយម - Nihilism [អានថា "អន់-ដេវ-ថី"], ហ្វ្រីឌ្រិច និហ្សេ (Friedrich Nietzsche) ដែលជាបុគ្គលម្នាក់ពុំហ៊ានបោះពុម្ពសៀវភៅដែលខ្លួនបាននិពន្ធក្នុងពេលខ្លួនមានជីវិតរស់នៅ សុខចិត្តរក្សាសៀវភៅទុកនៅក្បាលដំណេក រហូតដល់ខ្លួនស្លាប់បាត់បង់ជីវិត ទើបមានប្អូនរបស់ខ្លួនសម្រេចបោះពុម្ព

ផ្សាយ”។ ខ្ញុំយល់ច្បាស់ពីគំនិតនិងចេតនារបស់ទស្សនវិទូនីហ្សឺ។ នីហ្សឺ គឺជាទស្សនវិទូម្នាក់ដែលមានគំនិតប្រឆាំងព្រះ និងមិនជឿថាមានអត្ថិភាពរបស់ព្រះ (Existence of God)។ ថ្វីដ្បិតតែនិហ្សឺ មិនមែនជាមនុស្សក្លាហាន តែនិហ្សឺមិនអាក្រក់ទេ។ អ្នកដែលគ្រោះថ្នាក់ជាងគេ គឺជាអ្នកដែលនិយាយពីរឿងសាសនានិងនយោបាយ។ អ្នកឆ្លាតដើរជាមួយនឹងទឹកសន្សើម តែអ្នកខ្លះត្រូវបង្ខំដើរជាមួយនឹងទឹកជំនន់ ដែលអាចនឹងជន់លិចខ្លួនគ្រប់ពេល។

# ៥៨

## អ្នកនិពន្ធវ័យក្មេង?

កិច្ចការងារតែងនិពន្ធ គឺត្រូវការការសិក្សាស្រាវជ្រាវច្រើន ជាជាងការត្រឹមតែអាន ។ មានទស្សនៈជាច្រើនដែលបានលើកឡើងថា "អ្នកនិពន្ធគឺជាត្រូវតែជាអ្នកពូកែអាន ។ អ្នកនិពន្ធ គឺជាអ្នកចូលចិត្តអាន ហើយត្រូវតែអានឱ្យបានច្រើន" ។ ទស្សនៈនៃការយល់បែបនេះ គឺមិនខុសឡើយ ។ បើមែនទែនទៅ ការសរសេរគឺពិបាក ហើយវាមិនខុសពីគំនិតរបស់អ្នកប្រាជ្ញម្នាក់ ដែលបាននិយាយថា "សរសេរគឺគិត" ទេ ។ អ្នកសរសេរត្រូវការគិតច្រើនជាង

អ្នកអាន ។ បញ្ហាមួយទៀតនៃសំណេរ គឺអ្នកខ្លះ ឬបញ្ញវន្ត ដែលមានចំណេះដឹងជ្រៅជ្រះខ្លះ ក៏នៅតែមិនក្លាហានហ៊ាន សរសេរជាសៀវភៅចែករំលែកជាទស្សនៈដល់អ្នកជំនាន់ក្រោយៗដែរ ។ នេះគឺដោយសារតែបញ្ញវន្តខ្លះបារម្ភខ្លាច សាបព្រោះចំណេះដឹងខុសដល់សង្គម ។ សៀវភៅខ្លះជាថ្នាំ ព្យាបាលសង្គម រីសៀវភៅខ្លះជាថ្នាំបំពុលសង្គម ។ ខ្ញុំនៅតែ អះអាងថា "គ្រប់ចំណេះដឹងទាំងអស់ វាមិនមែនសុទ្ធតែជា ចំណេះដឹងត្រឹមត្រូវទេ ។ ចំណេះដឹងខ្លះ គឺមនុស្សមិនគួរ រៀន មិនគួរចេះ ឬក្នុងកាលៈទេសៈខ្លះទៀត មនុស្សត្រូវ ដឹងថាពេលណាខ្លួនត្រូវចេះ និងពេលណាត្រូវមិនចេះ ។

ខ្ញុំធ្លាប់បានមានឱកាសជួបជជែកជាមួយនឹងបញ្ញវន្ត ថ្នាក់ខ្ពស់ប៉ុន្មានរូប ដែលលោកសុទ្ធតែជាអ្នកចេះដឹងជ្រៅជ្រះ

មានអាយុចំណាស់ៗ និងបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតពីក្រៅប្រទេស។ ខ្ញុំតែងតែសួរសំណួរទៅកាន់លោកថា "តើហេតុអ្វីលោកមិនសរសេរស្នាដៃជាសៀវភៅបន្សល់ជាគំនិតដល់អ្នកជំនាន់ក្រោយៗ"។ លោកឆ្លើយដាក់ខ្លួនយ៉ាងសាមញ្ញថា "ខ្ញុំមិនចេះទេ ក្មួយ!" ពេលបានឮឃ្លាដែលថា "ខ្ញុំមិនចេះទេ ក្មួយ" គឺធ្វើឱ្យខ្ញុំយល់ច្បាស់ពីចេតនាខាងក្នុងរបស់លោក ដែលបារម្ភខ្លាចខុស ឬគំនិតដែលសាបព្រោះក្នុងសង្គមហើយ វាអាចនឹងមិនត្រឹមត្រូវ។ បើធ្វើបញ្ច្រាំងមកកាន់សង្គមយើងបច្ចុប្បន្នវិញ គឺមិនសូវមានអ្នកហ៊ានសារភាពថាខ្លួនមិនចេះទេ។ ក្នុងវគ្គបណ្ដុះបណ្ដាលខ្លះ អ្នកខ្លះអះអាងថាខ្លួនពូកែខ្លាំង ឬជាគ្រូលើគ្រូ (គ្រូធំ - Master) ចេះនេះ ឬចេះនោះ ឬរៀនមួយថ្ងៃក្លាយទៅជាសេដ្ឋី។ល។ ឬបើបានសរសេរស្នាដៃជាសៀវភៅបោះពុម្ពផ្សាយមួយក្បាល ក៏

ប្រកាសខ្លួនធ្វើជាគ្រូតែងនិពន្ធ ឬបើកវគ្គបង្រៀនតែងនិពន្ធផងក៏មាន ។ សង្គមយើងបច្ចុប្បន្ន (២០១៩) សម្បូរតែអ្នកសម្ញែង អ្នកសម្តែង តែខ្វះអ្នកពិតប្រាកដ ។ អ្នកខ្លះ ប្រឹងធ្វើការងារយកមុខមាត់ ច្រើនជាងធ្វើការងារយកលទ្ធផលពិត ។ ខ្ញុំនិយាយបែបនេះ វាអាចប៉ះពាល់អារម្មណ៍អ្នកដែលមានខ្លួន អាចរអៀសខ្លួន ។ នេះមិនខុសពីពាក្យខ្មែរដែលថា "ស៊ីលៀសរអៀសខ្លួន ឬគោដំបៅខ្នង ក្អែកហើររំលងរំភាយកន្ទុយ" ។

ខ្ញុំធ្លាប់បានអានសៀវភៅខ្លះអំពីលក្ខណៈអ្នកចេះដឹងនិងកិច្ចការដែលអ្នកចេះដឹងត្រូវធ្វើដើម្បីស្រោចទឹកដាក់ដីសង្គម ។ សូមសាកល្បងអានអត្ថបទរបស់លោក Noam Chomsky ដែលនិយាយអំពី "តួនាទីរបស់បញ្ញជនក្នុង

សង្គម - The Responsibility of Intellectuals" ។

ខ្ញុំសូមអនុញ្ញាតបង្ហាញជាទស្សនៈនៃការយល់ឃើញខ្លះ ៗ ពាក់ព័ន្ធទៅនឹងលក្ខណៈនៃអ្នករៀនសូត្រចេះដឹងតាមរយៈអត្ថបទខាងក្រោម៖

ក្នុងជីវិត បើយើងជាមនុស្សធម្មតា ក៏ប្រឹងរស់នៅធម្មតាទៅរស់នៅតាមរបៀបសាមញ្ញទៅហើយកុំតែប៉ះពាល់អ្នកដទៃទៅបានហើយ ។ ក្នុងនាមជាបុគ្គលសង្គម ឬបុគ្គលសាធារណៈ បើចង់រស់នៅធម្មតាសាមញ្ញ ក៏រស់នៅបែបធម្មតាសាមញ្ញទៅ តែសំខាន់ឱ្យតែរស់នៅល្អ ត្រឹមត្រូវ និងមានសុចរិតភាព ។

ក្នុងលក្ខខណ្ឌខ្លះ បើបានក្លាយខ្លួនទៅជាបុគ្គលគំរូហើយ ក៏ពុំគួរបណ្ដោតខ្លួន បណ្ដោយអារម្មណ៍ឱ្យគ្រប់គ្រងខ្លួនហួសហេតុពេក រហូតដល់ធ្វើអ្វីមួយខុសមុខខុសក្រោយផ្ដេសផ្ដាស បង្ហាញចំណុចខ្សោយចិត្តសាស្ត្រឱ្យអ្នកចេះដឹងដូចគ្នាវាយតម្លៃក្នុងន័យប្រមាថដែរ។ ជាទូទៅ ខ្ញុំកំណត់ថា "មនុស្សធម្មតាអាចធ្វើអ្វីបានតាមចិត្តដោយសេរី តែបុគ្គលដែលមានអ្នកដទៃស្គាល់ច្រើន គឺពុំអាចធ្វើអ្វីតាមទំនើងចិត្តបានទេ ដ្បិតយើងត្រូវរស់នៅក្នុងនាមជាអ្នកបង្ហាញគំរូ"។

[...] "ខ្ញុំអាណិតក្មេងៗជំនាន់ក្រោយណាស់ពីព្រោះពួកគាត់ត្រូវការជីវិតរស់មួយដែលមាន

គំរូល្អ និងគំរូដែលមានគុណភាព ។ គំរូទាំងនេះគឺចាស់ៗត្រូវតែជាអ្នកផ្តល់ជូនអ្នកក្រោយៗ ” ។ ជីវិតបែបនេះ បើប្រឹងសម្តែង វាហត់នឿយបន្តិចមែនហើយ តែបើហ្វឹកហាត់ឱ្យល្អៗយូរទៅ វានឹងក្លាយទៅជាចរិតលក្ខណៈតាមបែបធម្មជាតិ ។ ការអប់រំ គឺជាការកែប្រែអ្វីដែលខុសមកអ្វីដែលត្រូវ ។ យើងជាអ្នកចេះដឹង មិនថាអ្នកនិពន្ធ យុវបញ្ញវន្ត គ្រូបង្រៀន ។ល ។ ត្រូវលះបង់ច្រើនណាស់ ហើយទំហំនៃការលះបង់នេះ វាក៏ពុំងាយស្រួលប៉ុន្មានទេ ។

ក្នុងនាមជាអ្នករៀនសូត្រចេះដឹង កុំអួតសម្ញែងសន្លឹកសញ្ញាបត្រ តែត្រូវអួតសកម្មភាពធ្វើ

បានផលល្អ អ្នកចរិតសីលធម៌ អ្នកទឹកចិត្តទូលាយ អ្នកការចេះឱ្យតម្លៃមនុស្សដូចគ្នា អ្នកចិត្តរាបទាប ។ ចំណេះដឹង វានឹងក្លាយទៅជាឥតប្រយោជន៍ បើកាលណាយើងមិនបានយកមកប្រើការណ៍ឱ្យកើតកាលវាលគុម្ព ។ ការយកចំណេះដឹងទៅប្រើដោយខុសគោលការណ៍សីលធម៌ វាជាអំពើបាប ឬការយកចំណេះដឹងទៅប្រើដែរ តែប្រើមិនបានផលល្អ វាក៏ជាចំណេះដឹងឥតប្រយោជន៍ដែរ ។

អ្នកចេះដឹងដែលប្រើអារម្មណ៍ គឺជាបុគ្គលអវិជ្ជាក្នុងរឿងព្រលឹង ឬបេះដូងគ្មានការអប់រំ ឬខួរក្បាលជាបណ្ឌិត តែចិត្តជាកូនក្មេង ។ អាយុ

ច្រើននេះមួយ និងការសិក្សាអប់រំខ្ពស់ដែលគ្មានការពិសោធន៍ជាក់ស្តែងនេះមួយ, គឺរបស់ទាំងពីរនេះ វាពុំបានបង្ហាញពីលក្ខណៈនៃការអប់រំដ៏ពិតប្រាកដទេ ។ យើងគួរតែឈប់និយាយភាសាដែល "ជាប់អញ" តែគួរតែនិយាយភាសានៃសេចក្តីស្រឡាញ់ ។ អ្នកចេះដឹងពិតប្រាកដ គេមិនដែលដើរអួតសម្ញែងសន្ធឹកសញ្ញាបត្រទេ តែគេតែងតែបង្កើតលទ្ធផលការងារល្អៗដល់សង្គម និងសាបព្រោះគ្រាប់ពូជសីលធម៌រស់នៅក្នុងសង្គមជានិច្ច ។ *ជាប់អញ គឺមានន័យថា មានអញ ជាប់អំនួត ជាប់ជំពាក់នូវចិត្តអរិជ្ជា (មិនមែនខួរក្បាលអរិជ្ជា) ។

កិច្ចការងារខ្លះ វាត្រូវការពេលដើម្បីពង្រឹងគុណភាព តែអ្វីដែលត្រូវការជាងគេបំផុត គឺជាការទទួលស្គាល់នូវចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ដ្បិតពេលណាយើងដឹងចំណុចខ្សោយរបស់ខ្លួនហើយ គឺយើងនឹងឱបក្រសោបពេលវេលាពង្រឹងខ្លួនឯង ។ បើប្រៀបពីសម័យមុន និងឥឡូវ (សំណេរ) គឺខុសគ្នាឆ្ងាយណាស់ ។ នេះជាការយល់ឃើញរបស់ខ្ញុំប៉ុណ្ណោះ ហើយបើត្រូវឬខុស ក៏សូមពិចារណាតាមការគួរចុះ ។ ពេលអានអត្ថបទនេះ មានអ្នកខ្លះនឹងយល់ថាខ្ញុំមានចិត្តចង្អៀតចង្អល់ តែបើទូលាយពេក ក៏មិនខុសពីមានចរិតហៃអើៗដែរ ។ ចរិតដែលមិនសូវចូលចិត្តទើសរឿងដែលត្រូវទើស ទើបយើងចេះតែខុសតៗជំនាន់ ។ ពាក្យពេចន៍ក្នុងអត្ថបទនេះខ្លះ វាប្រហែលជាមានអ្នកចង់និយាយដូចខ្ញុំដែរ ប៉ុន្តែគ្រាន់តែអ្នកខ្លះមិនក្លាហាន

ហ៊ាននិយាយ ពីព្រោះអ្នកដែលចង់និយាយបែបនេះខ្លះ គឺខ្លាចអ្នកដទៃស្អប់ ។ រីចំពោះខ្ញុំវិញ ខ្ញុំបានបោះបង់ចោលនូវអារម្មណ៍ខ្លាចត្រូវអ្នកដទៃស្អប់ ។ បើខុស ខ្ញុំចាត់ទុកជាកំហុសខ្ញុំម្នាក់ឯង តែបើត្រូវវិញ គឺជាការរៀនសូត្របន្ថែមទាំងអស់ ។

# ៥៩

## តើយកចំណេះពីអំណានទៅធ្វើអ្វី?

យើងមិនអាចភ្លេចសង្គមដែលខ្លួនកំពុងរស់នៅទេ ។ សង្គមត្រូវការមនុស្សស្រោចទឹក ដាក់ជី ថែទាំ ប្រៀបដូចជាដើមឈើមួយដែលត្រូវការអ្នកថែទាំអ៊ីចឹង ។ គ្រឹះដែលអាចធ្វើឱ្យសង្គមរឹងមាំទៅបាន គឺស្ថិតនៅលើស្មារតីរឹងប៉ឹង ចិត្តនឹងន និងគំនិតរីកចម្រើនរបស់យុវជន ។ ខ្ញុំឃើញជំងឺខ្លះដែលកើតនៅលើយុវជនសម័យនេះ គឺជំងឺស្មារតីទន់ខ្សោយ និងចិត្តមិននឹងន ជួបបញ្ហាតិចតួច ឆាប់តែចុះចាញ់ អារម្មណ៍ឆាប់ស្លន់ស្លោរ វង្វេងស្មារតី ។ យើងខ្វះស្មារតី "ខាំមិនលែង

ឬ NGU – Never Give Up Spirit” ។

ពាក់ព័ន្ធនឹងលំនឹងចិត្ត និងស្ថិរភាពផ្លូវអារម្មណ៍ (Emotional Stability) ក៏មិនងាយនឹងនល្អដែរ ។ ខ្ញុំសរសេរចុះឡើង ៗ វាប៉ះពាល់ តែមិនដឹងសរសេរវាងទៅខាងណា ដ្បិតបើកាន់តែវាង ផ្លូវវាកាន់តែឆ្ងាយ ហើយខុសកាន់តែច្រើនទៀតផង [សរសេរចំ ឆាប់ត្រូវ តែត្រូវអ្នកដទៃស្អប់បន្តិច] ។ បើអ្នកចេះខ្លាំង ច្រើនតែអំនួត ឬបើមានចំណេះដឹងច្រើន ចិត្តចង់តែធ្វើមេ ភ្លេចស្រែ ភ្លេចចម្ការ ភ្លេចមនោសញ្ចេតនាបងប្អូន ។ រីចំណែកឯអ្នកខ្លះ ចេះត្រឹមតែសេដ្ឋកិច្ចទេ តែមកព្រោកប្រាជ្ញរឿងទស្សនវិជ្ជា ប្រៀបដូចខ្លួនឯងជាបណ្ឌិតទស្សនវិជ្ជា ។ អ្នកខ្លះចេះគណិតវិទ្យាទេ តែមកអួតរឿងសាសនា រហូតដល់បង្រៀនអ្នកស៊ីជម្រៅខាងសាសនាផងក៏

មាន ។ បើយើងជាអ្នកសេដ្ឋកិច្ច ចូរកុំនិយាយរឿងទស្សនវិជ្ជា ប្រៀបដូចជាខ្លួនឯងបណ្ឌិតទស្សនវិជ្ជា ។

របៀបនេះហៅថា "មិនស្គាល់តួនាទី ឬភ្លេចថាខ្លួនចេះអី" ឬចាស់លោកហៅថា "ប្រាជ្ញតតមារយាទ" ។ ខ្មែរយើងខ្លះមិនទាន់ចេះផ្គុំជំនាញ និងរបៀបផ្គុំចំណេះដឹងចាប់ដៃគ្នាធ្វើការទេ ។ កុំចង់ចេះតែឯង និងក្រឡិចក្រឡុច ។ មូលហេតុទាំងអស់ គឺដោយសារតែយើងមិនទាន់ឈរខាងប្រយោជន៍រួមនិងសច្ចភាព ។ បើកាលណាយើងមិនទាន់បានឈរខាងប្រយោជន៍រួម គឺជាហេតុធ្វើឱ្យយើងមិនទាន់ពាល់ចិត្តជាអ្នកលះបង់ ។ ការមិនចេះលះបង់ គឺដោយសារតែចិត្តជាប់ "អញ" ។ ចិត្តជាប់អញនេះហើយដែលធ្វើឱ្យយើងចង់ធ្វើតែធំ ។ និយាយដោយខ្លី ចិត្តយុវជនខ្មែរខ្លះ

នៅជំពាក់ច្រើនណាស់ ជាពិសេសជំពាក់នឹងរឿងខ្លួនឯងដើរចេញមិនរួចទាល់តែសោះ។ សង្គមពិតជាត្រូវការមនុស្សស្រោចទឹកដាក់ដី។ ស្រោចទឹកដាក់ដីយ៉ាងម៉េច? អ្នកមានលុយច្រើន ត្រូវរៀបចំកញ្ចប់លុយដើម្បីបណ្ដុះយុវនជនមានឆន្ទះ។ អ្នកមានបទពិសោធ ត្រូវផ្ទេរមកកាន់យុវជនមានឆន្ទះ។ បណ្ដុះនិងរៀបចំយុវជនមិនទាន់ពេលទេ គឺវានឹងក្លាយទៅជាវិបត្តិសង្គមមួយនាពេល១០ឆ្នាំខាងមុខ។ យ៉ាងយូរ ២០ឆ្នាំក្រោយ ចៅរបស់មនុស្សជំនាន់ចាស់ គឺត្រូវផ្ញើវាសនាលើដៃយុវជនជំនាន់នេះ។

## អំពីស្នាដៃខ្ញុំ

ខ្ញុំចាប់អារម្មណ៍លើការសរសេរចែករំលែកចំណេះដឹង តែបើនិយាយដល់វិស័យតែងនិពន្ធវិញ គឺខ្ញុំមិនចេះទេ ។ ប៉ុន្តែដោយសារតែការចូលចិត្តអាន បទពិសោធជីវិតជាក់ស្តែង ចំណេះដឹងសង្គមវិជ្ជាដែលបានមកពីការបំពេញការងារ ទើបធ្វើឱ្យខ្ញុំចង់សរសេរចែករំលែកចំណេះដឹង ការយល់ឃើញ ទស្សនៈ និងគតិខ្លះៗទៅតាមបណ្តាញសង្គម ជាពិសេសផ្តោតសំខាន់ទៅយុវជន ។ ចំណាប់ផ្តើមនៃការសរសេររបស់ខ្ញុំ គឺតាំងពីឆ្នាំ ២០១៥ ។ រហូតមកដល់ថ្ងៃនេះ សៀវភៅដែលជាស្នាដៃផ្ទាល់ខ្លួនរបស់ខ្ញុំមានចំនួន ២ក្បាល៖

ក្បាលទី១ គឺជាសៀវភៅ "**ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ**" ដែលសៀវភៅនេះមានខ្លឹមសារផ្តោតសំខាន់ទៅទស្សនវិជ្ជា ការអភិវឌ្ឍន៍ខ្លួន និងភាពជាអ្នកដឹកនាំ។ សៀវភៅនេះបានបង្កើតជាសៀវភៅឌីជិថល (eBook) ដាក់ឱ្យទាញយកមកអានដោយឥតគិតថ្លៃនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។ មួយរយៈក្រោយមក ខ្ញុំបានសម្រេចចិត្តបោះពុម្ពផ្សាយជាផ្លូវការលើកទី១ ចំនួន២០០០ក្បាល នៅខែមេសា ឆ្នាំ២០១៨។ រហូតមកដល់ពេលនេះ សៀវភៅនេះបានបោះពុម្ពផ្សាយជាលើកទី២ ចំនួន២០០០ក្បាលថែមទៀត នៅខែមីនា ឆ្នាំ២០១៩។ បើតាម

គម្រោងផែនការ គឺប្រហែលជាចុងឆ្នាំ២០១៩ សៀវភៅនេះ អាចនឹងត្រូវបោះពុម្ពផ្សាយជាលើកទី៣ ។

ក្បាលទី២ គឺជាសៀវភៅ "**ប្រតិទិនទស្សនៈ ២២២ថ្ងៃ**" ដែលសៀវភៅនេះផ្តោតសំខាន់ទៅលើខ្លឹមបីប្រភេទសំខាន់ៗរួមមាន មនុស្ស និងការប្រឹងប្រែង សាសនា និងចិត្តវិញ្ញាណ សង្គម និងភាពជាអ្នកដឹកនាំ ។ សៀវភៅនេះបានបោះពុម្ពផ្សាយលើកទីមួយជាផ្លូវការនៅខែកុម្ភៈ ឆ្នាំ២០១៩ ។ លក្ខណៈសៀវភៅជាក្របរឹង (Hard Cover) ដែលមានកម្រាស់ ៣៩៥ទំព័រ ។ តាមផែនការគ្រោង សៀវភៅនេះ

គម្រោងបោះពុម្ពផ្សាយជាលើកទី២ នៅមុន

ខែធ្នូ ឆ្នាំ២០១៩ ។

# រវាងសៀវភៅ “ប្រតិទិនទស្សនៈ៧៧៧ថ្ងៃ” និង “ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ”

សៀវភៅ “ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ” គឺជាសមិទ្ធផលដែលកើតចេញពីការប្រឹងប្រែងអាន ព្រមទាំងបទពិសោធជាក់ស្តែងខ្លះ ដែលខ្ញុំបានជួបប្រទះផ្ទាល់ក្នុងជីវិតផង ។ ខ្ញុំបានជ្រើសរើសខ្លឹមសារបីប្រភេទបញ្ចូលក្នុងសៀវភៅនេះ៖ គឺទីមួយនិយាយអំពីទស្សនវិជ្ជាជីវិត, ទីពីរនិយាយអំពីទស្សនវិជ្ជាសាសនាខ្លះ និងទីបីនិយាយអំពីនយោបាយ

សង្គមខ្លះ ។ សៀវភៅនេះពុំបានកំណត់មាតិកាច្បាស់លាស់ឡើយ ដ្បិតទស្សនៈភាគច្រើននៅរាយប៉ាយចាប់ពីទំព័រដំបូងរហូតដល់ទំព័រចុងបញ្ចប់ ។

រីចំណែកឯសៀវភៅ "ប្រតិទិនទស្សនៈ ២២២ថ្ងៃ" គឺជាកម្រងអត្ថបទបែបទស្សនៈចំនួន ២២២អត្ថបទ ដែលចែកចេញជា៣ជំពូកធំ ៗ ។ ជំពូកទី១ និយាយអំពីមនុស្ស និងការប្រឹងប្រែង ដ្បិតជីវិតមនុស្សកើតមករស់នៅលើផែនដីនេះ គឺត្រូវតែប្រឹងប្រែងកសាងខ្លួន ដុសខាត់ព្រលឹងខ្លួន និងរស់នៅក្នុងគុណធម៌នៃភាពជាមនុស្សត្រឹមត្រូវជានិច្ច ។ ជំពូកទី២ និយាយអំពីសាសនានិងចិត្តវិញ្ញាណ ដ្បិតមិនថាយើងកាន់សាសនាអ្វី ឬមានជំនឿលើលទ្ធិណា ឬនិកាយណាទេ គឺសំខាន់យើងត្រូវតែរស់នៅក្នុងសេចក្តីសុខ សន្តិភាពពិត

និងចេះមានក្ដីមេត្តាករុណាចំពោះមនុស្សដូចគ្នា ។ ជំពូកទី៣ និយាយអំពីសង្គមនិងភាពជាអ្នកដឹកនាំ ។ តួនាទីរបស់យើងដែលជាអ្នកជំនាន់ក្រោយនេះ មិនមែនត្រឹមតែប្រឹងដើម្បីរស់តែម្យ៉ាងទេ តែត្រូវប្រឹងជួយត្រួសត្រាយផ្លូវ កសាងមាគ៌ា និងរៀបចំអនាគតសម្រាប់អ្នកជំនាន់ក្រោយ ព្រមទាំងបន្សល់ទុកនូវមរតកសម្រាប់អ្នកជំនាន់ក្រោយ ៗ ទៀត ។

អ្នកជំនាន់មុនដែលល្អ គឺជាមនុស្សដែលចេះរៀបចំត្រួសត្រាយផ្លូវទុកឱ្យអ្នកជំនាន់ក្រោយដើរ ហើយដូនតាដែលគួរឱ្យគោរពបំផុត គឺជាអ្នកដែលបានបន្សល់ទុកនូវកេរដំណែលសម្រាប់អ្នកក្រោយៗតជំនាន់ ។មិនថាយើងកើតក្នុងសង្គមណាទេ គឺយើងត្រូវរស់នៅក្នុងនាមជាអ្នកទទួលខុសត្រូវខ្ពស់ម្នាក់ដោយមិនថាជាការទទួលខុសត្រូវចំពោះខ្លួន

ឯង ការទទួលខុសត្រូវចំពោះគ្រួសារ និងការទទួលខុសត្រូវចំពោះសង្គមដែលយើងរស់នៅទេ ។ ជោគជ័យរបស់យើងគឺយើងម្នាក់ ៗ ជាអ្នកប្រឹងបង្កើតឡើងដោយខ្លួនឯង តែជោគជ័យសង្គមគឺត្រូវការការចូលរួមពីជនសង្គមគ្រប់ ៗ រូប ។

សៀវភៅទាំងពីរក្បាលនេះ វាមានលក្ខណៈខុសគ្នា ។ សៀវភៅ "ប្រតិទិនទស្សនៈ ២២២ថ្ងៃ" គឺជាស្នាដៃដែលខ្ញុំប្រឹងសម្រឹតសម្រាំងនិងបង្កើតគោលការណ៍សម្រាប់អនុវត្តជាក់ស្តែង ជាពិសេសសម្រាប់យុវជនតែម្តង ។ ហេតុអ្វីខ្ញុំនិយាយពីរឿង "ប្រឹង", ហេតុអ្វីខ្ញុំនិយាយពីរឿង "សាសនា", និងហេតុអ្វីខ្ញុំនិយាយពីរឿង "ភាពជាអ្នកដឹកនាំ" ? ចម្លើយទី១. មនុស្សដែលមិនប្រឹង នឹងនាំអំពល់ទុក្ខដល់គេឯង ហើយជនសង្គមដែលមិនប្រឹង គឺនឹងធ្វើឱ្យសង្គមមិនទៅ

មុខ ។ ចម្លើយទី២. សាសនាដែលគ្មានសេចក្តីស្រឡាញ់ គឺនឹងធ្វើឱ្យមានការរើសអើងគ្នា ។ ចម្លើយទី៣. គោលបំណងចុងក្រោយបង្អស់នៃភាពជាអ្នកដឹកនាំ គឺ “រួបរួមសាមគ្គី និងរីកចម្រើនទៅមុខជាមួយគ្នា” ។

បើឆ្លុះបញ្ចាំងមកសង្គមវិញ យុវជនខ្លះបានប្រើប្រាស់សក្តានុពលខ្លួនឯងយ៉ាងខ្ជះខ្ជាយ មិនដឹងថាខ្លួនជាមនុស្សខ្លាំង ហើយមិនព្រមប្រឹងទាល់តែសោះ ដោយចាំតែបន្ទោសដាក់បន្ទុកចំពោះសង្គម ។ បើឆ្លុះបញ្ចាំងរឿងសាសនាវិញ អ្នកសាសនាខ្លះបំបែកមនុស្ស, អ្នកសាសនាខ្លះខ្វះចិត្តស្ងប់ ហើយម្នាក់ៗពូកែតែខាងទ្រឹស្តី តែការអនុវត្តន៍មិនបានល្អជាប្រក្រតី ។ បើឆ្លុះបញ្ចាំងក្នុងរឿងនយោបាយវិញ អ្នកចេះដឹងខ្លះនាំគ្នាប្រឹងមូលបង្កាច់សច្ចភាព, ខ្វះចិត្តជា

អ្នកសម្រុះសម្រួល និងបង្រួបបង្រួមមនុស្សឱ្យស្រឡាញ់គ្នា, ចរិតទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី, រហូតដល់ថា "ដំរីជល់គ្នា ងាប់ស្រមោច" ។ និយាយដោយខ្លី សៀវភៅ "ប្រតិទិនទស្សនៈ ២២២ថ្ងៃ" នេះ គឺពង្រឹងជំហរមនុស្សឱ្យប្រឹង អនុវត្តមាគ៌ាសុខក្នុងសាសនាឱ្យបានច្រើនជាងទ្រឹស្តី និងចូលរួមចំណែកជួយដោះស្រាយបញ្ហាសង្គមតាមវិធីសាស្ត្រផ្សេង ៗ គ្នា និងតាមលទ្ធភាពរៀង ៗ ខ្លួនដែលអាចធ្វើទៅបាន ។ ទស្សនៈ និងគំនិតក្នុងសៀវភៅ "ប្រតិទិនទស្សនៈ ២២២ថ្ងៃ" គឺសុទ្ធតែជាទ្រឹស្តីអ្នកប្រាជ្ញខ្មែរផងនិងបរទេសផង ដែលខ្ញុំបានយកមកប្រើប្រាស់ធ្វើជាអំណះអំណាងគាំទ្រដោយឈរលើមូលដ្ឋានកាលៈទេសៈផ្នត់គំនិតសង្គម តាមរយៈបទពិសោធការងារខ្លះជាមួយអង្គការក្រៅរដ្ឋាភិបាលភាគច្រើន ដែលខ្ញុំបានឆ្លងកាត់

ផ្ទាល់។ សរុបចុងក្រោយ សៀវភៅទាំងពីរក្បាលនេះមិនដូចគ្នាឡើយ។

# ប្រតិទិនទស្សនៈ ៧៧៧ថ្ងៃ




បោះពុម្ពផ្សាយលើកទី១ ខែកុម្ភៈ ឆ្នាំ ២០១៩

ខ្នាតសៀវភៅ ១៤.៥ x ២១.៥ សង់ទីម៉ែត្រ

ប្រភេទក្របរឹង (Hard Cover)

កម្រាស់ ៤០០ទំព័រ

# ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ




បោះពុម្ពផ្សាយលើកទី២ ខែមីនា ឆ្នាំ ២០១៩

ខ្នាតសៀវភៅ ១៤.៥ x ២១.៥ សង់ទីម៉ែត្រ

កម្រាស់ ៤៤២ទំព័រ

## អំពីខ្ញុំ

បច្ចុប្បន្ន ខ្ញុំជាកសិករធ្វើស្រែសម្រាប់តែមួយគ្រពះ និងសល់ពេលវេលាខ្លះ ធ្វើការងារសហគមន៍បន្តិចបន្តួចជាមួយយុវជន ។ ប៉ុន្តែ បើនិយាយពីមុនវិញ គឺពីឆ្នាំ២០០៩ រហូតដល់ឆ្នាំ២០១៧ ខ្ញុំធ្លាប់បានបម្រើការងារនៅតាមអង្គការក្រៅរដ្ឋាភិបាល, សមាគម, និងគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ។ ទំនួលខុសត្រូវការងាររបស់ខ្ញុំភាគច្រើនពាក់ព័ន្ធនឹងការងារជាមួយយុវជន យុវវ័យ និងក្មេង ៗ ក្រីក្រនៅតាមសហគមន៍តំបន់ដាច់ស្រយាល ។ ថ្វីត្បិតតែខ្ញុំមានកំណើត និងរស់នៅក្រុងអង្គរ សម្បូរប្រាសាទបុរាណ

ច្រើនកុះករ ព្រមទាំងមានភៀវទេសចរច្រើនដេរដាស តែខ្ញុំពុំមានបទពិសោធការងារទាក់ទងនឹងវិស័យឯកជន ឬបដិសណ្ឋារកិច្ចអ្វីនោះឡើយ ។

ដោយសារតែខ្ញុំបម្រើការងារពាក់ព័ន្ធនឹងវិស័យអប់រំជាមួយអង្គការក្រៅរដ្ឋាភិបាល ការងារជាមួយយុវជន ទើបធ្វើឱ្យខ្ញុំបានជួបប្រទះនូវទិដ្ឋភាពលំបាក ៗ ជាច្រើននៅតាមទីជនបទ ។ ខ្ញុំចាប់ផ្ដើមការងារអង្គការក្រៅរដ្ឋាភិបាលដំបូងនៅឆ្នាំ២០០៩ ក្នុងវេលាដែលខ្ញុំជាសិស្សថ្នាក់ទី១១នៅឡើយ ។ ខ្ញុំសកម្មជាមួយការងារ និងស្រែចម្ការច្រើនជាងការសិក្សា ដ្បិតខ្ញុំកើតក្នុងគ្រួកូលកសិករ និងរស់ពឹងអាស្រ័យដោយសារតែស្រែចម្ការ ។ ពេលខ្ញុំបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិភ្លាម ខ្ញុំមានជម្រើសរើសយកការសិក្សាថ្នាក់ឧត្ដម

តែស្ថានភាពគ្រួសារបង្ខំខ្ញុំឱ្យបន្តដំណើរជីវិតជួយជ្រោមជ្រែងគ្រួសារ រហូតដល់ចប់ចុងចប់ដើមត្រឹមចុងឆ្នាំ ២០១៦។ និយាយរួម ខ្ញុំយកការងារជាក់ស្ដែងជាគ្រូរបស់ខ្ញុំ និងយកថៅហ្វាយនាយជាគ្រូបង្វឹកផ្ទាល់។ ថ្វីបើខ្ញុំគ្មានពេលវេលារៀននៅសាលា តែខ្ញុំមានគ្រូបរទេសចំណាស់ម្នាក់ដែលមានខួរក្បាលឆ្លាត និងមានបទពិសោធជីវិតល្អៗ បានបង្វឹកខ្ញុំផ្ទាល់, ធ្វើជាគ្រូខ្ញុំ, និងបង្រៀនមេរៀនជាក់ស្ដែងជាច្រើនដល់រូបខ្ញុំ។ បើគ្មានគាត់ទេ ខ្ញុំក៏ប្រហែលគ្មានថ្ងៃនេះដែរ។

បើសួរខ្ញុំថា "តើខ្ញុំមានបំណងប្រាថ្នាអ្វី?" សំណួរនេះខ្ញុំពិបាកឆ្លើយ ពីព្រោះក្រែងវាខុសពីចម្លើយដែលសង្គមមនុស្សទូទៅបានកំណត់។ ជោគជ័យរបស់ខ្ញុំ គឺជាអត្ថន័យនៃជីវិត និងឈ្នះលើខ្លួនឯង។ ជីវិតដែលអាចស្វែងរកអត្ថន័យបាន

លុះត្រាណាតែមានចំណេះវិជ្ជា និងឧស្សាហ៍ប្រើពេលវេលាពិចារណាលើខ្លួនឯងជាប្រចាំញឹកញាប់ ។ តាមរយៈបទពិសោធជីវិតជាក់ស្តែង ខ្ញុំបានរៀនសូត្រនូវមេរៀនជាច្រើនដែលគ្មានបង្រៀននៅសាលា ។ តាមរយៈការអានសៀវភៅបន្ថែម ខ្ញុំកាន់តែយល់បន្ថែមពីខ្លួនឯងនិងពិភពខាងក្រៅ ។ ក្នុងការអនុវត្តន៍ សៀវភៅដែលខ្ញុំបានអាន វាពុំបានបង្រៀនខ្ញុំច្រើន ដូចបទពិសោធជីវិតរបស់ខ្ញុំឡើយ ។

ទស្សនៈអំពីជីវិតទាំងអស់ដែលខ្ញុំបានហែលឆ្លងកាត់ផ្ទាល់ វាធ្វើឱ្យខ្ញុំចង់ខ្ចាក់ចេញ និងចង់ចែករំលែកដល់យុវជនក្រោយៗ ។ ខ្ញុំហ៊ាននិយាយថា “ជីវិត គឺលំបាក ហើយវារឹតតែលំបាកខ្លាំង បើយើងមិនប្រឹងប្រែងទាល់តែសោះ” ។ បទពិសោធដែលខ្ញុំទទួលបាន វាប្រៀបបាននឹងការដកដង្ហើម

ចូល តែសំណេរដែលខ្ញុំអត់ធ្មត់សរសេរចែករំលែកបន្ត វាប្រៀបដូចជាការដកដង្ហើមចេញ ។ សំណេររបស់ខ្ញុំ គឺមានគោលបំណងចែករំលែកទស្សនៈអំពីការប្រឹងប្រែងជួយខ្លួនឯង ជួយសង្គម ដោយរស់នៅយ៉ាងណាកុំធ្វើជាបន្ទុករបស់សង្គម ព្រមទាំងត្រូវចេះរស់នៅសាមគ្គីគ្នាក្នុងនាមជាមនុស្សដែលមានឈាមជ័រជាបងប្អូនខ្មែរ ៕


| | | |
|---|---|---|
| អ៊ីម៉ែល | : | lamlem01@gmail.com |
| ហ្វេសប៊ុក | : | https://www.facebook.com/lamlem01 |
| ទូរសព្ទទំនាក់ទំនង | : | ០៩៦ ២៤ ០៧ ១៦២ |

ស្មៀនភៅឌីជីថល

# បើយើងពូកែអាន...

ការអានច្រើន គឺមិនអាចធ្វើឱ្យមនុស្សគ្រប់គ្នាពូកែទេ តែអ្នកដែលពូកែ គឺតែងចូលចិត្តអាន។ អ្នករៀនគណនេយ្យ ហើយបើពូកែអានថែមទៀត គឺពូកែជាងគណនេយ្យករធម្មតា។ អ្នករៀនច្បាប់ ហើយបើពូកែអានថែមទៀត គឺពូកែជាងអ្នកច្បាប់ធម្មតា។ អ្នករៀនព័ត៌មានវិទ្យា ហើយបើពូកែអានថែមទៀត គឺពូកែជាងអ្នកព័ត៌មានវិទ្យាធម្មតា។ មិនថាយើងរៀនជំនាញបច្ចេកទេសអ្វីទេ ហើយបើពូកែអានថែមទៀត គឺយើងនឹងពូកែជាងមនុស្សចេះជំនាញបច្ចេកទេសធម្មតា។